សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីស្តារឡើងវិញដោយ
មានជំនួយពីសហគមន៍អឺរ៉ុប
កម្មវិធីជំនួយសិក្សាធិការផ្នែកបឋមសិក្សានៅកម្ពុជា

# ទស្សនាវដ្ដី

លេខ ៩

# គ្រូបង្រៀន




ខែ មករា កុម្ភៈ មីនា ឆ្នាំ ១៩៩៨

ផ្សាយចេញរាល់ត្រីមាស ជាទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨ B មហាវិថីព្រះនរោត្តម ( ភ្នំពេញ )

ទូរស័ព្ទ : ០១៥ ៩១៨ ១២៥

**I- គណៈកម្មការគ្រប់គ្រងទិស- អំណាន និង តាមដាន**

| | | |
|---|---|---|
| ១- លោក | យ៉ង់ ធី | ប្រធាន |
| ២- លោក | ណាត ប៊ុនរឿន | សមាជិក |
| ៣- លោក | ធ សោ | សមាជិក |
| ៤- លោក | ជា ជាតិ | សមាជិក |
| ៥- លោក | ស៊ុង វ៉ាន់ថុន | សមាជិក |
| ៦- លោកស្រី | ហួរ ស៊ីរ | សមាជិក |
| ៧- លោក | ឡូអ៊ុច ឡឺប៊ីរស | សមាជិក |
| ៨- លោក | សោភ រិន្ទ | សមាជិក |

**II- គណៈកម្មការតែងអត្ថបទ**

១- លោក យ៉ង់ យ៉ាណុ
២- លោក ឆយ យីហ៊ាង
៣- លោក អ៊ឹម កុប
៤- លោក កង ឱម
៥- លោក ពត សុត
៦- លោក ជិន សុកហេង
៧- អ្នកស្រី ផាន់ សំអោ
៨- អ្នកស្រី អ៊ិច សារុ
៩- លោក សំអាន សាយ
១០-លោក ប្រាក់ ព្រុំ
១១-លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត-ក្រុងបណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យ

# មាតិកាអត្ថបទ

* * * * *

ទំព័រ


១- បញ្ហាសំនេរ និង បញ្ហាវិធីសាស្ត្រគរុកោសល្យ ........ ១

២- ពត៌មាន
- អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ........ ៣

៣- វប្បធម៌ទូទៅ - ការអប់រំ
- សីលធម៌ (ការស្គាល់ និង ការគោរពខ្លួនឯង) ........ ១៥
- ភ្នំជួនពេញ ........ ១៧
- ប្រព័ន្ធអប់រំ ........ ២១

៤- គរុកោសល្យ
- វិធីតែងកាព្យ (ត) ........ ២២
- តើខេត្តនៅភូមិភាគឧត្តរ និង ពាយ័ព្យ ត្រូវបានប្រគល់មកអោយប្រទេសកម្ពុជាវិញ ដោយរបៀបណា ? ........ ២៧
- បុរេប្រវត្តិនៃកម្ពុជា (ត) ........ ២៩
- សេចក្តីពន្យល់បន្ថែមពីសម័យបុរេប្រវត្តិនៅកម្ពុជា ........ ៣៣

៥- ទេសិកាសិរិន
- បញ្ហាអក្សរមូល ........ ៣៦
- សំនួរ-ចំលើយ (នៅក្នុងទស្សនាវដ្តីលេខ ៧,៨ ) ........ ៣៩
- តើការបង្រៀន និង រៀនគឺជាអ្វី ? ........ ៤៧

៦- កំណាព្យ
- វប្បធម៌ទូទៅ និង សីលធម៌វិជ្ជាជីវៈ ........ ៤៩
- សៀវភៅសិក្សាថ្មី ........ ៥០

៧- ដំណឹងមរណភាព ( កំណើនសព )


ទស្សនាវដ្តីនេះ បោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និង ហិរញ្ញវត្ថុ
ពី កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប
Revue publiée avec le concours technique et financier du Programme d’Appui au Secteur de l’Education Primaire au Cambodge (PASEC) de l’Union Européenne.

# បញ្ហាសំនេរ និង បញ្ហាវិធីសាស្ត្របង្រៀន

---*---

មិត្តអ្នកអានជាទីមេត្រី !

ទស្សនាវដ្ដីគ្រូបង្រៀនបានចេញផ្សាយជាហូរហែ តាំងពីចុងឆ្នាំ ១៩៩៥ រហូតមកទល់សព្វថ្ងៃ ហើយមានអ្នកចូលចិត្តអានជាច្រើនណាស់ដែរ ។ កន្លងមកនេះ មានអ្នកអានមួយចំនួន បានធ្វើសំណូមពរដោយផ្ទាល់មាត់ និង មានបំភ្លេចខ្លះៗ តែមិនជាពុំអ្វីទេ ។ ទីមួយ ពីបញ្ហាអក្ខរាវិរុទ្ធ គឺ **ទំនាញសូរក្នុងសំនេរ** និង ទីពីរ គឺ **បញ្ហា វិធីសាស្ត្របង្រៀន** ។

## ១- បញ្ហាអក្ខរាវិរុទ្ធ :

យើងខ្ញុំក្នុងនាមជាប្រធានសមាគមគ្រូបង្រៀនសូមសារភាពថា ទស្សនាវដ្ដីគ្រូបង្រៀនមិនទាន់បានគោរពមួយរយភាគរយនូវទំនាញសូរក្នុងសំនេរ ដូចសៀវភៅសិក្សាបោះពុម្ពផ្សាយចេញពីក្រសួងអប់រំ យុវជន និង កីឡានោះឡើយ ។ បញ្ហានេះយើងខ្ញុំដែលជាអ្នកទទួលខុសត្រូវមួយចំណែក សូមធ្វើការពន្យល់ និង ដោះស្រាយដូចតទៅ ៖

- ទស្សនាវដ្ដីគ្រូបង្រៀន ជាទស្សនាវដ្ដីរបស់សមាគមគ្រូបង្រៀន ដែលមានទិសដៅជួយគ្នាទៅវិញទៅមកផ្នែកស្មារតី និង ជួយលើកតំកើងបំនេះដឹងផ្នែកអប់រំទូទៅ ។

លោកគ្រូ-អ្នកគ្រូមួយចំនួនបានចោទថា ខ្ញុំជាអ្នកអភិរក្សនិយម មិនជួយចូលបែរ ដើម្បីអោយមានទំនើបកម្មដើរទៅមុខ គឺគិតតែពីទាញថយក្រោយ ពោលគឺ មិនអើពើនឹងបញ្ហាទំនាញសូរសោះ ។ មតិនេះ ខ្ញុំសូមបកស្រាយថា វាត្រូវបំពោះអស់លោកមួយចំនួន តែក៏វាមិនទាន់ជាមតិឯកច្ឆ័ន្ទក្នុងទូទាំងប្រទេសដែរ ។ ខ្ញុំចេះដែរ ពីបញ្ហាទំនាញសូរក្នុងសំនេរខ្មែរ ។ វាផុសឡើងក្នុងពេលដែលខ្ញុំនៅជាគ្រូបង្រៀន និង ជាអធិការបឋមសិក្សា ។ គេចោទសួរថា បើខ្ញុំចេះហើយ ម្ដេចខ្ញុំមិនអនុវត្ត ? ខ្ញុំសូមបញ្ជាក់ថា បរិការណ៍ (contexte) សង្គមមិនទាន់ចុះសម្រុងគ្នា និង យើងពុំទាន់មានបណ្ឌិតសភាអក្សរសាស្ត្រ ។ ប្រសិនជាទស្សនាវដ្ដីគ្រូបង្រៀនសរសេរតាមទំនាញសូរអោយបានមួយរយភាគរយនោះ អ្នកអភិរក្សមុខជាចោទថា ទស្សនាវដ្ដីគ្រូបង្រៀនមានឥរិយាបថជ្រុលទៅមុខខ្លាំងក្នុងសំនេរអក្សរខ្មែរ ។ ខ្ញុំសូមបញ្ជាក់បន្ថែមថា ទស្សនាវដ្ដីនេះ មិនគ្រាន់តែសំរាប់លោកគ្រូ-អ្នកគ្រូប៉ុណ្ណោះទេ វាថែមទាំងសំរាប់ផ្សាយទៅមជ្ឈដ្ឋាននយោបាយថ្នាក់លើ និងអ្នកនៅក្រៅពីក្រសួងអប់រំថែមទៀត ។ ដូចនេះយើងខ្ញុំសុំប្រកាន់អាកប្បកិរិយាកណ្ដាល តាមការណែនាំរបស់ក្រសួងអប់រំ ដែលបានអនុគ្រោះអោយសរសេរបានពីរយ៉ាងជាបណ្ដោះអាសន្ន ដូចជា កំណាច រឺ កំនាច, កំណើន រឺ កំនើន , តំណ រឺ តំន , ក្រឡ រឺ ក្រល, សម្លាញ់ រឺ សំលាញ់ ។ល។

យើងខ្ញុំសូមជំរាបថា ក្នុងកាលៈទេសៈដែលបរិការណ៍សង្គមខ្មែរមិនទាន់ចុះសម្រុងគ្នា ការកែប្រែអក្ខរាវិរុទ្ធទាក់ទិននឹងបញ្ហាទំនាញសូរក្នុងសំនេរ មិនមែនជាការងាយស្រួលទេ ។ ទោះបីក្រសួងអប់រំ យុវជន និង កីឡា បានបោះពុម្ពផ្សាយអក្ខរាវិរុទ្ធថ្មីតាមទំនាញសូរក៏ដោយ ក៏មជ្ឈដ្ឋានក្រៅសាលារៀនមិនទាន់ឯកភាពទាំងស្រុងនៅឡើយដែរ ។ អាស្រ័យហេតុនេះ ទើបសារពត៌មាន និង ទស្សនាវដ្ដីផ្សេងៗ តែងរក្សាសំនេរតាមវចនានុក្រមខ្មែរជាគោល ។

សូមមិត្តអ្នកអាន លោកគ្រូ-អ្នកគ្រូពិចារណាលើគោលការណ៍ប្រជាធិបតេយ្យដែលអ្នកនយោបាយ អ្នកដឹកនាំប្រទេសត្រូវតែអនុវត្ត ៖

១- គំរោងជាតិ រឺបញ្ហាសង្គមអ្វីមួយ ត្រូវតែបំផុសអោយប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់យល់បាន ជ្រួតជ្រាបពីគោលបំណងនៃគំនែទំរង់ ទុកពេលវេលាមួយដ៏សមស្របអោយគេមានមតិយោបល់ ដោយមានការថ្លឹងថ្លែងជាមុនសិន ។

២- ការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ រឺជាងពាក់កណ្ដាលលើគំរោងជាតិនេះ ចាត់ទុកជាបានការ ព្រោះប្រជាពលរដ្ឋភាគច្រើនទទួលស្គាល់ថា គំរោងនេះ មានប្រយោជន៍ដល់សង្គមជាតិ ។

៣- កាលណាប្រជាពលរដ្ឋបានជ្រួតជ្រាបលើបញ្ហានេះហើយ គេប្តេជ្ញាចិត្តនឹងអនុវត្តតាម ។

*គំរោងនេះ ត្រូវក្លាយជាច្បាប់ក្រោយពីរដ្ឋសភាពិភាក្សា និង អនុម័ត ។*

សរុបមកឃើញថា សំនេរក្នុងទស្សនាវដ្តី ច្បាស់ជាពុំទាន់គោរពតាមទាំងស្រុងនៃទំនាញសួរឡើយ ។ ប្រការនេះ ក៏សូមអ្នកអានទាំងឡាយអធ្យាស្រ័យផងចុះ ។

## ២- បញ្ហាវិធីសាស្ត្របង្រៀន

លោកគ្រូមួយចំនួនធ្វើសំណូមពរអោយសមាគមបុគ្គលិកសិក្សាខ្មែរ ធ្វើប្លង់មេរៀនគ្រប់មុខវិជ្ជានៅបឋមសិក្សា ហើយចុះផ្សាយក្នុងទស្សនាវដ្តីគ្រូបង្រៀន ដោយបង្ហាញវិធីសាស្ត្របង្រៀននៅគ្រប់មុខវិជ្ជាទាំងនោះផង ។ យើងខ្ញុំសូមបញ្ជាក់ជូនថា ៖

- ទស្សនាវដ្តីគ្រូបង្រៀន មិនមែនជាទស្សនាវដ្តីរបស់រដ្ឋ ឬ របស់ក្រសួង អ.យ.ក ឡើយ ។ មតិក្នុងអត្ថបទចុះផ្សាយជាមតិឯកជន គ្រាន់តែត្រូវពិនិត្យ កែសំរួលដោយគណៈកម្មការគំរង់ទិស អំនាន និង តាមដាន ដូចមានឈ្មោះលើក្របទស្សនាវដ្តីខាងក្នុង ។

- សព្វថ្ងៃនេះ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធំ បានជួយប្រទេសកម្ពុជាខាងវិស័យអប់រំ ក្នុងគោលបំណងតំកើងបំនេះធ្វើរបស់គ្រូបង្រៀន ដោយបំប៉នវិធីសាស្ត្របង្រៀននៅតាមខេត្តមួយចំនួន ។ អង្គការទាំងអស់នោះ បានបង្ហាត់បង្រៀនវិធីសាស្ត្របង្រៀន ទៅតាមបំនេះដឹងដែលគេរៀនចាំពីប្រទេសរបស់គេរៀងៗខ្លួន ព្រោះអ្នកបង្ហាត់បង្រៀននោះ ជាគ្រូបង្រៀនដែរ ។ ឧទាហរណ៍: អង្គការរ៉េតបាណា នៃប្រទេសណរវែល ( Norvège ) អង្គការស៊ីតា ( បារាំង ) អង្គការអែសសេអេហ្វអា ( SCFA ) ( អូស្ត្រាលី ) អង្គការចាំសិប ( សហគមន៍អឺរ៉ុប ) អង្គការខេប ( CAPE ) អង្គការយូណេសេហ្គូ យូណេស្កូ ( UNESCO ) យូអេនអេហ្វភីអេ ( UNFPA ) និងអង្គការមួយចំនួនទៀត ខ្លះបានជួយធ្វើវគ្គគរុកោសល្យលើវិធីសាស្ត្របង្រៀនភាសា និង គណិតវិទ្យា ខ្លះទៀត ជួយនិពន្ធរៀបរៀងបោះពុម្ព និង ចែកផ្សាយនូវមុខវិជ្ជា វិទ្យាសាស្ត្រពិត និង វិទ្យាសាស្ត្រសង្គម ។ ក្រសួងអប់រំ យុវជន និង កីឡា បានអនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅទាំងអស់នោះ ដើម្បីប្រើប្រាស់នៅតាមសាលារៀនបំនេះទូទៅរួចអស់ហើយ និង បានធ្វើសិក្ខាសាលាណែនាំអោយយល់ពីវិធីបង្រៀនថែមទៀតផង ។

ដូចខ្ញុំបានជំរាបខាងលើហើយថា អង្គការក្រៅរដ្ឋាភិបាលប្រទេសណា វិធីសាស្ត្របង្រៀនមុខវិជ្ជាទៅតាមប្រទេសនោះហើយ ដែលគេបានអនុវត្តនៅស្រុកគេ ។ គេយល់ឃើញថាល្អនៅស្រុកគេ បានជាគេយកមកបង្ហាត់បង្រៀនយើង ។ ម្នាក់ៗចង់អោយយើងអនុវត្តតាម ។ ប៉ុន្តែ សូមលោកគ្រូ-អ្នកគ្រូយល់ថា ល្អនៅស្រុកគេពិតមែន តែមិនមែនល្អទាំងអស់សំរាប់ស្រុកយើងឡើយ ។ ដូចនេះ ត្រូវយល់ថា មិនមានវិធីសាស្ត្របង្រៀនសកលទេ ។ គ្មានវិធីសាស្ត្រណាមួយល្អបណ្តាច់ឡើយ ។ វិធីសាស្ត្រណា សុទ្ធតែមានចំណុចខ្លាំង និង ចំណុចខ្សោយរបស់ខ្លួន ។ ប្រការដែលសំខាន់នោះ គឺលោកគ្រូ-អ្នកគ្រូ ត្រូវចេះជ្រើស និង ចេះអនុវត្តវិធីសាស្ត្របង្រៀន ដោយគំនិតច្នៃប្រឌិត និង សមស្រប ។ ប្រសិនបើគេធ្វើគំរូមួយអោយលោកគ្រូ-អ្នកគ្រូ អនុវត្តតាមនោះ ការបង្ហាត់បង្រៀនក្លាយជាការអនុវត្តតាមបែបរូបមន្តនិយម ឬ គម្ពីរនិយម ។ ករណីបែបនេះ លោកគ្រូ-អ្នកគ្រូ ទាំងឡាយ នឹងក្លាយទៅជាម៉ាស៊ីនគ្មានគំនិតច្នៃប្រឌិត ។ វិធី គឺជាមាគ៌ាដើរឆ្ពោះទៅរកទិសដៅ ។ ដូចនេះ របៀបបង្រៀនដែលយើងយកតាមវិធីនេះ ឬ វិធីនោះ វាអាស្រ័យទៅតាមទិសដៅនៃការអប់រំ ខ្លឹមសារនៃមេរៀននីមួយៗ និងវាអាស្រ័យទៅតាមការិតទទួលបានរបស់សិស្ស ។

នាពេលបច្ចុប្បន្ននេះ គរុកោសល្យទំនើប បានយកសិស្សជាមជ្ឈមណ្ឌល គឺ « ផ្តើមចេញពីសិស្សដើម្បីសិស្ស និង អោយសិស្ស» ដែលគេហៅថា វិធីសាស្ត្រយកសិស្សជាមជ្ឈមណ្ឌល ។ វិធីសាស្ត្រយកសិស្សជាមជ្ឈមណ្ឌល បានតំរូវអោយលោកគ្រូ-អ្នកគ្រូមានគំនិតច្នៃប្រឌិត គឺរៀបចំសកម្មភាពបង្រៀនខ្លួនឯងផង និង រៀបចំសកម្មភាពអោយសិស្សទៀតផង ពោលគឺ សកម្មភាពគ្រូដើម្បីសកម្មភាពសិស្ស គឺដើម្បីអោយសិស្សត្រិះរិះពិចារណា ធ្វើសកម្មភាព ។

**យ៉ង់ ធី**




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * *

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២១ អនក្រ-បក
* * * *

## អនុក្រឹត្យ
## ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ
## របស់ក្រសួងអប់រំ យុវជន និង កីឡា

* * * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ : ០២ ន.ស. ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ..........................................................................................................
- ..........................................................................................................
- ..........................................................................................................
- ..........................................................................................................
- ..........................................................................................................
- ..........................................................................................................

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** អនុក្រឹត្យនេះ រៀបចំបង្កើតអង្គភាពនៃក្រសួងអប់រំ យុវជន និង កីឡា កំណត់បេសកកម្មរបស់ក្រសួង និង មុខងារនៃអង្គភាពក្រោមឱវាទ និង ចាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ :** ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យអប់រំ យុវជន និង កីឡា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** ក្រសួងអប់រំ យុវជន និង កីឡា មានមុខងារ និង ភារកិច្ចដូចតទៅ ៖

- កំណត់នយោបាយអប់រំ យុវជន និង កីឡា ដោយផ្អែកលើមូលដ្ឋានកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅអភិវឌ្ឍន៍ធនធានមនុស្ស ។
- ធ្វើផែនការអនុវត្ត ត្រួតពិនិត្យ និងវាយតំលៃនយោបាយអប់រំ យុវជន និង កីឡា ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងលើកឡើងនូវទិសដៅ និងវិធានការកែលំអជាបន្តបន្ទាប់តាមគ្រប់មុខជំនាញ ។
  លើកកំពស់វិស័យអប់រំ យុវជន និង កីឡា ទាំងគុណភាព ទាំងបរិមាណ ដោយអភិវឌ្ឍន៍កម្មវិធីសិក្សា សំភារៈឧបទេស និងឯកសារគរុកោសល្យគ្រប់កម្រិតសិក្សា អោយសមស្របទៅនឹងដំណាក់កាលនីមួយៗ នៃការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និង អន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សីលធម៌ និងបេះដូងរស់ជាមួយគ្នា ក្នុងក្របខ័ណ្ឌជាតិ និង អន្តរជាតិ ។
- កសាងគោលការណ៍គ្រប់គ្រងអង្គភាពរដ្ឋបាល គ្រប់លំដាប់ថ្នាក់ ។
- កសាងគោលការណ៍គ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជនគ្រប់កំរិតសិក្សា ។
- គ្រប់គ្រង និង អភិវឌ្ឍន៍ ការស្រាវជ្រាវដើម្បីរួមចំណែកលើកកំពស់វិស័យអប់រំ យុវជន និង កីឡា ។
- ពិនិត្យសំណើបង្កើតទទួលស្គាល់សាលារៀន ថ្នាក់រៀន សាលា និង ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈឯកជនគ្រប់ប្រភេទ និង គ្រប់កំរិត ។
- គ្រប់គ្រង ត្រួតពិនិត្យ និង វាយតំលៃការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និង ឯកសារសិក្សាផ្សេងៗ ។
- គ្រប់គ្រង ត្រួតពិនិត្យ និង វាយតំលៃដំណើរការសិក្សាអប់រំនៃគ្រប់គ្រឹះស្ថានសិក្សា រដ្ឋ និង ឯកជន ដោយរាប់បញ្ចូលទាំងវគ្គសិក្សាដែលបើកដោយអង្គការនានាផង និងដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ។
- រៀបចំ ណែនាំ គ្រប់គ្រង ត្រួតពិនិត្យការប្រលងនៅកម្រិតសិក្សានានា និងដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ។
- អភិវឌ្ឍន៍ការងារយុវជន ដោយមានវិធានការគ្រប់គ្រង អប់រំបណ្តុះបណ្តាលបំប៉នវិជ្ជាជីវៈ ។

- អភិវឌ្ឍន៍ការងារអប់រំកាយ និង កីឡា ក្នុងជួរសិស្សនិស្សិត និង មហាជន ។ បំផុស និងពង្រីកសកម្មភាពកីឡាគ្រប់ប្រភេទ ទាំងកីឡាទំនើប និង កីឡាប្រពៃណី ។
- យកចិត្តទុកដាក់បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិ និង អន្តរជាតិ ។
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ចលនវត្ថុ និង អចលនវត្ថុ ហិរញ្ញវត្ថុ ពត៌មាន និង ធនធានមនុស្ស ត្រួតពិនិត្យការប្រើប្រាស់អោយបានសមស្រប ។

មាត្រា ៤ : ក្រសួងអប់រំ យុវជន និង កីឡា មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ថ្នាក់កណ្ដាល :

- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុរួមមាន ៖
    - នាយកដ្ឋានរដ្ឋបាល
    - នាយកដ្ឋានបុគ្គលិក
    - នាយកដ្ឋានហិរញ្ញវត្ថុ
    - នាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ
    - នាយកដ្ឋានផែនការ
    - នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍
- អគ្គនាយកដ្ឋានអប់រំរួមមាន ៖
    - នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា
    - នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
    - នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
    - នាយកដ្ឋានសុខភាពសិក្សា
    - នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ
    - គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយមានឋានៈស្មើនាយកដ្ឋាន
- អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេស និង វិជ្ជាជីវៈរួមមាន ៖
    - នាយកដ្ឋានឧត្តមសិក្សា
    - នាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ
    - នាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ
    - នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ
- អគ្គនាយកដ្ឋានយុវជន និង កីឡា រួមមាន ៖
    - នាយកដ្ឋានយុវជន
    - នាយកដ្ឋានអប់រំកាយ និង កីឡា
    - វិទ្យាស្ថានជាតិអប់រំកាយ និង កីឡា មានឋានៈស្មើនាយកដ្ឋាន
- ខុទ្ទកាល័យ

២- អង្គភាពមូលដ្ឋាន :

- មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និង រាជធានី

- អង្គភាពអប់រំវប្បធម៌ប្រចាំក្រៅប្រទេស

៣- <u>គ្រឹះស្ថានសិក្សា និង វិទ្យាស្ថាន ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា</u>

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានឋានៈស្មើអគ្គនាយកដ្ឋាន រួមមានមហាវិទ្យាល័យ និងវិទ្យាស្ថាន មានឋានៈស្មើនាយកដ្ឋានដូចខាងក្រោម ៖
    - + មហាវិទ្យាល័យវិទ្យាសាស្ត្រ
    - + មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ
    - + មហាវិទ្យាល័យគរុកោសល្យ
    - + មហាវិទ្យាល័យពាណិជ្ជសាស្ត្រ
    - + មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
    - + វិទ្យាស្ថានភាសាបរទេស
- វិទ្យាស្ថានជាតិភាសាខ្មែរមានឋានៈស្មើនាយកដ្ឋាន

៤- <u>គ្រឹះស្ថានសិក្សាដែលបណ្ដុះបណ្ដាលនិស្សិតក្នុងក្របខ័ណ្ឌអនុសញ្ញា បកិច្ចព្រមព្រៀងថ្នាក់រដ្ឋាភិបាល</u>

- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- សាកលវិទ្យាល័យវេទមហាឫស្សីនៅខេត្តព្រៃវែង

៥- <u>គ្រឹះស្ថានសិក្សា និង មជ្ឈមណ្ឌលផ្សេងៗទៀត ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា មានចែងក្នុងឧបសម្ព័ន្ធជូនភ្ជាប់</u>

អង្គការលេខរបស់ក្រសួងអប់រំ យុវជន និង កីឡា ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គាធិការដ្ឋាន

<u>មាត្រា ៥</u> : អគ្គាធិការដ្ឋានទទួលបន្ទុក :

- អគ្គាធិការដ្ឋានមានភារកិច្ចត្រួតពិនិត្យ ដើម្បីអោយអង្គភាពរដ្ឋបាលកណ្ដាល អង្គភាពខាងក្រៅ (បំណុះក្រសួង) មានដំណើរការល្អ ។
- ធ្វើរបាយការណ៍ជូនក្រសួងពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច និង លើកសំណើវិធានការកែលំអ ។
- ប្រតិបត្តិភារកិច្ចតាមការបែងចែកដែលក្រសួងបានប្រគល់ជូន ។

អគ្គាធិការដ្ឋាន ត្រូវបានដឹកនាំដោយអគ្គាធិការមួយរូប និង អមដោយអគ្គាធិការរងជាជំនួយការ តាមការចាំបាច់ ។

អគ្គាធិការដ្ឋាន មានអធិការដ្ឋានអប់រំ និង អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ៖

ក- <u>អធិការដ្ឋានអប់រំមានភារកិច្ច</u> :

- សិក្សាស្រាវជ្រាវ វិភាគវាយតំលៃប្រសិទ្ធភាពប្រព័ន្ធអប់រំ ត្រួតពិនិត្យការអនុវត្តជាទូទៅ នូវកម្មវិធីសិក្សា ឯកសារសិក្សានានា ត្រួតពិនិត្យការអនុវត្តបទបញ្ញត្តិ គោលការណ៍រដ្ឋបាលសិក្សាគរុកោសល្យ ដឹកនាំគ្រប់គ្រងគ្រឹះស្ថានសិក្សារដ្ឋ ឯកជន និង ប្រសិទ្ធភាពនៃការកសាងផ្លូវគ្រូបង្រៀន ។
- ត្រួតពិនិត្យលើការអនុវត្តជំនាញយុវជន និង កីឡា ។

- ត្រួតពិនិត្យ និង លើកសំណើរដោះស្រាយករណីមិនប្រក្រតីនានា ។

**ខ- អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុមានភារកិច្ច ៖**

- ត្រួតពិនិត្យដំណើរការទូទៅនៃប្រព័ន្ធគ្រប់គ្រង និង ដំណើរប្រព្រឹត្តជាទូទៅនៃស្ថាប័ន និងគ្រឹះស្ថានសិក្សាទាំងឡាយ លើផ្នែកគ្រប់គ្រងបុគ្គលិក ទំនាក់ទំនងគ្រប់គ្រងរដ្ឋបាល ផែនការគ្រប់គ្រងហិរញ្ញវត្ថុ បរិក្ខារ និងទ្រព្យសម្បត្តិរដ្ឋ ។
- ត្រួតពិនិត្យ និង លើកសំណើរដោះស្រាយករណីទាំងឡាយពាក់ព័ន្ធទៅនឹងការងាររដ្ឋបាល និង ហិរញ្ញវត្ថុ ។

## ជំពូក ៤

## អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ៦** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួលគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ សំភារៈបរិក្ខារ និងសារពើភ័ណ្ឌ ផែនការ និងទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ។

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករង ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានមាននាយកដ្ឋានចំនួន ៦ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ៧** : នាយកដ្ឋានរដ្ឋបាល ទទួលបន្ទុក :

- សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន
- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង ។
- សរុប និង ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

**មាត្រា ៨** : នាយកដ្ឋានបុគ្គលិក ទទួលបន្ទុក :

- គ្រប់គ្រងផ្នែកក្របខ័ណ្ឌ និងផ្នែករដ្ឋបាលលើមន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំការងារបៀវត្សពលកម្ម ប្រាក់កំរៃ និង របបឧបត្ថម្ភផ្សេងៗ ។
- រៀបចំការងារនីតិកម្មក្នុងវិស័យអប់រំ យុវជន និង កីឡា ។

**មាត្រា ៩** : នាយកដ្ឋានហិរញ្ញវត្ថុ ទទួលបន្ទុក :

- លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ ។
- ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។
- ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។
- តាមដានរំលឹកពីការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

**មាត្រា ១០ :** នាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋទទួលបន្ទុក :
- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌ ។
- គ្រប់គ្រងយានដ្ឋាន និង យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និង បែងចែកប្រេងឥន្ធនៈ និង គ្រឿងបន្លាស់ ។
- ទទួល និង បែងចែកសំភារៈបរិក្ខារជូនដល់បណ្តាអង្គភាព ខេត្ត-ក្រុងនានា ។
- កាន់បញ្ជីជាប្រចាំនូវសាលាប័ត្រ និង គណនេយ្យបជាតុ ។
- គ្រប់គ្រងការប្រើប្រាស់ឧបករណ៍ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និង បន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- ត្រួតពិនិត្យការអនុវត្ត ការជួសជុលសាងសង់អាគារសិក្សារបស់រដ្ឋ ។

**មាត្រា ១១ :** នាយកដ្ឋានផែនការទទួលបន្ទុក :
- កសាងផែនការគោលលើគ្រប់ផ្នែក ។
- រៀបចំ និង គ្រប់គ្រងប្រព័ន្ធទិន្នន័យពត៌មានរបស់ក្រសួង ។
- កសាងផែនទីសិក្សា ។
- ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និង ក្រៅប្រទេសលើវិស័យអប់រំ យុវជន និង កីឡា ។
- សំរបសំរួលជំនួយពីបរទេស និង គ្រប់គ្រងវាយតម្លៃ និង ត្រួតពិនិត្យការអនុវត្តគំរោងការនានា ទាំងផ្នែកបច្ចេកទេស ទាំងផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ១២ :** នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍ទទួលបន្ទុក :
- ទំនាក់ទំនងជាមួយក្រសួងនានា អង្គការនានាក្នុងតំបន់ និង លើសកលលោក ដើម្បីបុព្វហេតុអភិវឌ្ឍន៍វិស័យអប់រំ យុវជន និង កីឡា ។
- សំរបសំរួលការងារក្រៅក្រសួង និង ការងារអន្តរជាតិ ។
- រៀបចំឯកសារ និង ពិធីការក្នុងកិច្ចសហប្រតិបត្តិការ ជាមួយបរទេស ។
- គ្រប់គ្រងរាល់ឯកសារសហប្រតិបត្តិការ ។
- ជ្រើសរើស និង គ្រប់គ្រងសិស្ស និស្សិតអាហារូបករណ៍ និង កម្មសិក្សាការីនៅបរទេស ។

## ជំពូក ៥

## អគ្គនាយកដ្ឋានអប់រំ

**មាត្រា ១៣ :** អគ្គនាយកដ្ឋានអប់រំទទួលបន្ទុកគ្រប់គ្រង និង អភិវឌ្ឍបឋម និង មត្តេយ្យសិក្សា មធ្យមសិក្សាចំណេះទូទៅអប់រំក្រៅប្រព័ន្ធ កម្មវិធីសិក្សា និង សៀវភៅសិក្សា និង សុខភាពសិក្សា ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និង អគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋានអប់រំនេះ មាននាយកដ្ឋានចំនួន ៥ និង គ្រឹះស្ថាន ១ ដូចមានក្នុងមាត្រាខាងក្រោម ។

<u>មាត្រា ១៤</u> : នាយកដ្ឋានបឋម និង មត្តេយ្យសិក្សាទទួលបន្ទុក :

- អភិវឌ្ឍ និង គ្រប់គ្រងបច្ចេកទេស គ្រឹះស្ថានមត្តេយ្យសិក្សា និង បឋមសិក្សារដ្ឋ ។
- ត្រួតពិនិត្យដំណើរការសិក្សាអប់រំ នៅគ្រប់គ្រឹះស្ថាន បឋមសិក្សា និង មត្តេយ្យសិក្សារដ្ឋ និង ឯកជន និង បំផុសលើកទឹកចិត្ត ការអភិវឌ្ឍគ្រឹះស្ថាន មត្តេយ្យសិក្សា និង បឋមសិក្សាឯកជន ។
- អធិការកិច្ចការងារគរុកោសល្យ និង ការងារគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និង បឋមសិក្សារដ្ឋ និង ឯកជន ។
- សិក្សាសំណើសុំបង្កើត បើក និង ទទួលស្គាល់គ្រឹះស្ថានមត្តេយ្យសិក្សា និង បឋមសិក្សារដ្ឋ និង ឯកជន ។

<u>មាត្រា ១៥</u> : នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅទទួលបន្ទុក :

- អភិវឌ្ឍន៍ និង គ្រប់គ្រងបច្ចេកទេសគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋ ។
- ត្រួតពិនិត្យដំណើរការសិក្សាអប់រំនៅគ្រប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋ និង ឯកជន ។
- គ្រប់គ្រងការវាយតំលៃលទ្ធផលសិក្សាប្រចាំឆ្នាំ និងការប្រលងដំណាច់ភូមិសិក្សានីមួយៗ នៃមធ្យមសិក្សាចំណេះទូទៅ ។
- កំណត់និយាមគរុកោសល្យ និងមូលដ្ឋានសំភារៈសំរាប់អភិវឌ្ឍន៍គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ រដ្ឋ និង ឯកជន ។
- គ្រោងលទ្ធភាពទទួលសិស្សសំរាប់ឆ្នាំសិក្សានីមួយៗ ។
- អធិការកិច្ចការងារគរុកោសល្យ និងការងារគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋ និង ឯកជន ។
- សិក្សាសំណើសុំបង្កើត បើក និង ទទួលស្គាល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅរដ្ឋ និង ឯកជន ។

<u>មាត្រា ១៦</u> : នាយកដ្ឋានអប់រំក្រៅប្រព័ន្ធទទួលបន្ទុក :

- បំផុសចលនាអក្ខរកម្ម និង បំពេញវិជ្ជាដោយផ្តល់ចំណេះដឹងទូទៅ វិជ្ជាជីវៈ និង ពត៌មាន ។
- រៀបចំកម្មវិធី និង សៀវភៅសិក្សាអក្ខរកម្ម និង បំពេញវិជ្ជា ។
- ត្រួតពិនិត្យដំណើរការសិក្សាអប់រំក្នុងសាលារៀន-ថ្នាក់រៀនក្រៅប្រព័ន្ធ រៀបរយពាក់កណ្តាលរៀបរយ និង ក្រៅម៉ោង ។
- សំរបសំរួលសកម្មភាពអប់រំក្រៅប្រព័ន្ធជាមួយក្រសួង ស្ថាប័ន និង អង្គភាពនានា ។

<u>មាត្រា ១៧</u> : នាយកដ្ឋានសុខភាពសិក្សាទទួលបន្ទុក :

- អប់រំសុខភាព និង អនាម័យរបស់សិស្ស និស្សិត ។
- ថែទាំ ត្រួតពិនិត្យសុខភាព និង អនាម័យរបស់សិស្ស និស្សិត ។
- គ្រប់គ្រងសាខាគិលានដ្ឋាននៅតាមគ្រឹះស្ថានសិក្សា ។

<u>មាត្រា ១៨</u> : នាយកដ្ឋានស្រាវជ្រាវគរុកោសល្យទទួលបន្ទុក :

- អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សា និង ឯកសារផ្សេងៗបំរើអោយការអប់រំចំណេះទូទៅ ។
- ត្រួតពិនិត្យការនិពន្ធ ការផ្សាយ និង ការនាំចូលសៀវភៅសិក្សា និង ឯកសារផ្សេងៗ ។
- សិក្សាស្រាវជ្រាវខ្លឹមសារ និង កម្មវិធីសិក្សាចំណេះទូទៅ ដើម្បីអភិវឌ្ឍវិស័យអប់រំអោយទាន់សម័យ ។

<u>មាត្រា ១៩</u> : គ្រឹះស្ថានបោះពុម្ព និង ចែកចាយទទួលបន្ទុក ៖

- រៀបរៀង និង បោះពុម្ពកម្មវិធីសិក្សា សៀវភៅសិក្សា ឯកសារគរុកោសល្យ ផលិតសំភារៈឧបទេស ឯកសារ

ផ្សេងៗរបស់ក្រសួង និង ចែកផ្សាយអោយប្រើប្រាស់សំរាប់ការអប់រំចំណេះទូទៅ និង អប់រំក្រៅប្រព័ន្ធ ។
- ត្រួតពិនិត្យការប្រើប្រាស់សៀវភៅសិក្សា ឯកសារគរុកោសល្យ សំភារៈឧបទេសអោយសមស្របតាមគោលការណ៍របស់ក្រសួង ។

## ជំពូក ៦

## អគ្គនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេស និង វិជ្ជាជីវៈ

**មាត្រា ២០ :** អគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួលគ្រប់គ្រងការងារឧត្តមសិក្សា បច្ចេកទេស និង វិជ្ជាជីវៈ បណ្តុះបណ្តាលគរុកោសល្យ និង ស្រាវជ្រាវវិទ្យាសាស្ត្រក្រោមក្រសួងអប់រំ យុវជន និង កីឡា ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកដ្ឋានមួយរូប និង អគ្គនាយករងជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានមាន នាយកដ្ឋានចំនួន ០៤ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ២១ :** នាយកដ្ឋានឧត្តមសិក្សាទទួលបន្ទុក :
- គ្រប់គ្រងការសិក្សានៃគ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួង និង ឯកជន ។
- សំរបសំរួលការងារឧត្តមសិក្សានៃគ្រឹះស្ថានឧត្តមសិក្សា របស់ក្រសួង និង ក្រសួងផ្សេងទៀត ។
- ត្រួតពិនិត្យ និងវាយតំលៃគុណភាពការងារឧត្តមសិក្សារបស់គ្រឹះស្ថានសិក្សា ក្នុងក្រសួង និងក្រសួងផ្សេងៗ ។

**មាត្រា ២២ :** នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈទទួលបន្ទុក :
- គ្រប់គ្រងការសិក្សានៃគ្រឹះស្ថានសិក្សាបច្ចេកទេសវិជ្ជាជីវៈ ក្រោមឱវាទក្រសួង និង ឯកជន ។
- សំរបសំរួលការងារអប់រំបច្ចេកទេស និង វិជ្ជាជីវៈនៃគ្រឹះស្ថានសិក្សារបស់ក្រសួង និង ក្រសួងផ្សេងទៀត ។
- ត្រួតពិនិត្យ និង វាយតំលៃគុណភាពការងារអប់រំបច្ចេកទេស និង វិជ្ជាជីវៈនៃគ្រឹះស្ថានសិក្សាបច្ចេកទេស និង វិជ្ជាជីវៈរបស់ក្រសួង និង ក្រសួងផ្សេងទៀត ។
- ត្រួតពិនិត្យសាលា ឬថ្នាក់បច្ចេកទេស ឬបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ២៣ :** នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការទទួលបន្ទុក :
- រៀបចំផែនការបណ្តុះបណ្តាលដំបូងនូវក្របខ័ណ្ឌគ្រូបង្រៀន និង អធិការបឋមសិក្សា អធិការមធ្យមសិក្សា និង ការបណ្តុះបណ្តាលបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ និងអនុវត្តនយោបាយនេះ ។
- រៀបចំកម្មវិធីសិក្សាសំរាប់បណ្តុះបណ្តាល វិក្រឹតការ និង សុក្រឹតការ ។
- គ្រប់គ្រងបច្ចេកទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យខេត្ត-ក្រុង ។
- តាមដាន និង វាយតំលៃសមត្ថភាពវិជ្ជាជីវៈបុគ្គលិកសិក្សា ។

**មាត្រា ២៤ :** នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រទទួលបន្ទុក :
- រៀបចំនយោបាយសំរាប់ការស្រាវជ្រាវ និងបណ្តុះបណ្តាល ព្រមទាំងលើកទឹកចិត្តអ្នកស្រាវជ្រាវគ្រប់ផ្នែក ។
- រៀបចំសំរបសំរួល សហប្រតិបត្តិការស្រាវជ្រាវវិទ្យាសាស្ត្រ ជាមួយស្ថាប័នស្រាវជ្រាវនានាក្នុង និងក្រៅប្រទេស ។

- លើកតំលៃលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និង បច្ចេកទេស ។

## ជំពូក ៧

## អគ្គនាយកដ្ឋាន យុវជន និង កីឡា

**មាត្រា ២៥** : អគ្គនាយកដ្ឋានយុវជន និង កីឡា ទទួលបន្ទុកគ្រប់គ្រង និងអភិវឌ្ឍការងារយុវជនការងារអប់រំកាយ និងកីឡា នៅក្នុងក្របខ័ណ្ឌក្រសួង និង ក្នុងសង្គមជាតិ ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានមាន នាយកដ្ឋានចំនួន ២ និងវិទ្យាស្ថានជាតិអប់រំកាយ និង កីឡា ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ២៦** : នាយកដ្ឋានយុវជនទទួលបន្ទុក :

- អភិវឌ្ឍវិស័យយុវជនកម្ពុជា ។
- បំផុសការបង្កើតសមាគមយុវជនក្នុង និង ក្រៅសាលារៀន ។
- ជួយកុមារ និង យុវជនក្នុង និងក្រៅសាលារៀន ដើម្បីអោយទទួលបានការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬផ្តល់មុខរបរ ។
- គ្រប់គ្រងមជ្ឈមណ្ឌលយុវជនខេត្ត-ក្រុង ដើម្បីផ្តល់ការអប់រំ និងពត៌មានដល់យុវជន ។

**មាត្រា ២៧** : នាយកដ្ឋានអប់រំកាយ និង កីឡា ទទួលបន្ទុក :

- អភិវឌ្ឍការអប់រំកាយក្នុង និង ក្រៅសាលារៀន ដើម្បីថែទាំសុខភាពសិស្ស-និស្សិត ប្រជាពលរដ្ឋ ។
- បំផុសសកម្មភាពអប់រំកាយ និង កីឡា ក្នុងសាលារៀន ដើម្បីអភិវឌ្ឍកីឡា និងលើកផែនការបណ្តុះបណ្តាលយុវកីឡាករ ។
- អភិវឌ្ឍសកម្មភាពកីឡាគ្រប់ប្រភេទ ។
- សិក្សាស្រាវជ្រាវការអភិវឌ្ឍវិស័យអប់រំកាយ និង កីឡា ។
- រៀបចំកម្មវិធីសិក្សាអប់រំកាយ និង កីឡា សំរាប់គ្រឹះស្ថានសិក្សា ។
- ត្រួតពិនិត្យ តាមដានបច្ចេកទេសកីឡានានា ។

**មាត្រា ២៨** : វិទ្យាស្ថានជាតិអប់រំ និង កីឡា មានឋានៈស្មើនាយកដ្ឋានទទួលបន្ទុក :

- លើកផែនការបណ្តុះបណ្តាល និង វិក្រឹតការគ្រូអប់រំកាយ និង កីឡា ។
- សំរបសំរួល និង សហការជាមួយគណៈកម្មាធិការជាតិអូឡាំពិចកម្ពុជា និងសហព័ន្ធកីឡាជាតិ ដើម្បីសិក្សា និងរៀបចំផែនការហ្វឹកហ្វឺន ។
- សិក្សាស្រាវជ្រាវការអភិវឌ្ឍវិស័យកីឡាតំបន់ និងអន្តរជាតិ ដើម្បីត្រៀមលក្ខណៈចូលប្រកួត ។
- ហ្វឹកហ្វឺនកីឡាករជាតិ និងលើកកំពស់កំរិតបច្ចេកទេស ដើមបីចូលរួមក្នុងការប្រកួតនៅគ្រប់កំរិត ក្នុងប្រទេស និងអន្តរជាតិ ។
- វិក្រឹតការ និងសុក្រឹតការ គ្រូបង្វឹក និង អធិការកិច្ចលើការបង្ហាត់ ។

## ជំពូក ៨

### ខុទ្ទកាល័យ

**មាត្រា ២៩ :** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំនត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៩

### អង្គភាពមូលដ្ឋាន

**មាត្រា ៣០ :** នៅតាមខេត្ត-ក្រុងនីមួយៗ មានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌ និងសាលារៀនទទួលបន្ទុកអនុវត្តទិសដៅ និងភារកិច្ចរបស់ក្រសួង ។

ចំពោះអង្គភាពអប់រំវប្បធម៌ប្រចាំក្រៅប្រទេស ការអនុវត្ត និងការសំរបសំរួលសកម្មភាពរបស់ក្រសួង ត្រូវអនុលោមទៅតាមបទបញ្ញត្តិអនុក្រឹត្យស្តីពីអំណាចរបស់ឯកអគ្គរាជទូត និងការរៀបចំអង្គភាពរដ្ឋនៅក្រៅប្រទេស ។

## ជំពូក ១០

### គ្រឹះស្ថានសិក្សាក្រោមការគ្រប់គ្រង

**មាត្រា ៣១ :** គ្រឹះស្ថានសិក្សាដែលមានចែងក្នុងចំណុច III នៃមាត្រាទី ៤ មានមុខងាររៀបចំបណ្តុះបណ្តាលនិស្សិតកំរិតឧត្តម លើកលែងតែវិទ្យាស្ថានជាតិភាសាខ្មែរ ដែលមានបេសកកម្មអភិវឌ្ឍភាសាខ្មែរសំរាប់ការសិក្សា ស្រាវជ្រាវ និងការផ្សព្វផ្សាយ ។

ការរៀបចំ និងប្រព្រឹត្តទៅរបស់គ្រឹះស្ថានសិក្សា និងវិទ្យាស្ថានទាំងនេះ អោយទៅជាគ្រឹះស្ថានសាធារណៈឧបនិស្ស័យរដ្ឋបាល ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូក ១១

### អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣២ :** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមលក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១២

### អវសានបញ្ញត្តិ

**មាត្រា ៣៣ :** ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣៤ :** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

__មាត្រា ៣៥__ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

__មាត្រា ៣៦__ : អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨

ហត្ថលេខា និង ត្រា

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

**អ៊ុង ហួត** **ហ៊ុន សែន**

__បានជំរាបជូន__

- នាយករដ្ឋមន្ត្រីទី ១
- សម្តេចនាយករដ្ឋមន្ត្រីទី ២

ជ- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**គា សាឃាន**

__ចំលងជូន__ :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- គ្រប់ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ, កាលប្បវត្តិ

លេខ : __០៤ អយក.ចល__

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៨

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ប៊ុន សុខ**

-----------------------------------

**ឧបសម្ព័ន្ធអនុក្រឹត្យលេខ : __២១ អនក្រ.បក__**

**ចុះថ្ងៃទី ២៣ មីនា ១៩៩៨**

## គ្រឹះស្ថានសិក្សា និង មជ្ឈមណ្ឌលផ្សេងៗទៀត ក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា

* * * * * *

- មជ្ឈមណ្ឌលបច្ចេកទេស និង វិជ្ជាជីវៈព្រះកុសុមៈ
- សាលាមធ្យមសិក្សាអប់រំកាយ និង កីឡា
- សាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម
- សាលាមធ្យមសិក្សាឯកទេសឧស្សាហកម្ម
- សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត បាត់ដំបង
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត សៀមរាប
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និង ធនធានបច្ចេកវិទ្យា ខេត្តកណ្តាល

# អង្គការលេខរបស់ក្រសួងអប់រំ យុវជន និង កីឡា

ឧបសម្ព័ន្ធអនុក្រឹត្យលេខ : ២១ អនក្រ.បក
ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨






# សីលធម៌

## ការស្គាល់ និង ការគោរពខ្លួនឯង

## La connaissance et le respect de soi

* * * * *

នៅក្នុងទស្សនាវដ្ដីលេខ ៨ ខ្ញុំបានតាក់តែងអត្ថបទមួយ ស្ដីពីការស្គាល់ខ្លួនឯងដោយខ្លួនឯង ។ តាមការទឹកស្មានរបស់ខ្ញុំ ខ្ញុំជឿជាក់ថា លោកគ្រូ-អ្នកគ្រូមានគំនិតទូលាយទៅលើអត្ថបទសីលធម៌នេះ ។ ខ្ញុំសូមសួរថា ហេតុអ្វីបានជាមនុស្សគ្រប់រូប ត្រូវតែស្គាល់ខ្លួនឯងដោយខ្លួនឯង ? សូមរកអោយឃើញផលប្រយោជន៍នៃការស្គាល់ខ្លួនឯងដោយខ្លួនឯង មកលើរូបរាងកាយ និងចិត្តគំនិត ។

បន្ទាប់ទៅនេះ ខ្ញុំតាក់តែងអត្ថបទមួយទៀត ស្ដីពីការគោរពខ្លួនឯង (le respect de soi) ភ្ជាប់ជុំនឹងអត្ថបទមុន ។

សូមសញ្ជឹងគិតជាមួយខ្ញុំទៅលើកិរិយាស័ព្ទគោរព ។ យើងទាំងអស់គ្នាច្រើននិយាយថា កូនត្រូវគោរពមាតាបិតា សិស្សត្រូវគោរពគ្រូ អ្នកបើកបរត្រូវគោរពច្បាប់ចរាចរ ប្រជាពលរដ្ឋត្រូវគោរពច្បាប់នៃប្រទេសរបស់ខ្លួន ។ល។ ពាក្យគោរពខ្លួនឯង ឬគោរពខ្លួនផ្ទាល់ (se respecter) ហាក់ដូចជាគេមិនសូវប្រើ ។ តើពាក្យនេះមានន័យដូចម្ដេច ? ដើម្បីអោយបានជ្រួតជ្រាប យើងគួរតែស្វែងយល់អត្ថន័យនៃពាក្យបារាំង se respecter ព្រោះពាក្យគោរពខ្លួនឯង បកប្រែពីពាក្យបរទេសនេះឯង ។

Se respecter តាមវចនានុក្រម Le Petit Larousse មានន័យថា " se comporter avec la décence qui convient " ប្រែថា ប្រព្រឹត្តសមរម្យតាមឋានៈរបស់ខ្លួន ។

វចនានុក្រម Le Robert អោយន័យនៃពាក្យ se respecter ថា " agir de manière à conserver l'estime de soi-même " ប្រែថា ប្រព្រឹត្តយ៉ាងណារក្សាអោយបាននូវសេចក្ដីថ្លៃថ្នូររបស់ខ្លួន ឬតំលៃរបស់ខ្លួន ។

តាមន័យទាំងពីរនេះ តើលោកគ្រូ-អ្នកគ្រូយល់យ៉ាងណា ? ចំពោះពាក្យគោរពខ្លួនឯង ។ ដើម្បីបន្ថែមទៅលើន័យនេះ ខ្ញុំសូមលើកឧទាហរណ៍ដូចតទៅ ៖

នៅពេលសន្និបាតមួយ វាគ្មិនកំពុងតែខិតខំពន្យល់អ្នកស្ដាប់ ។ បុរសម្នាក់អញ្ជើញមកយឺតពេល ហើយមានសំលៀកបំពាក់មិនសមរម្យ ព្រមទាំងសក់មិនសិតថែមទៀត ដើរចូលមកអង្គុយធ្វើបែបហ៊ឺ ។ អ្នកឯទៀតក្រឡេកមើលបុរសនេះទាំងអស់គ្នា ។

**សំនួរ** : តើលោកយល់យ៉ាងដូចម្ដេច ទៅលើការប្រព្រឹត្តនៃបុរសនេះ ? តើគាត់គោរពខ្លួនគាត់ឬទេ ? តើគាត់គោរពអ្នកដទៃឬទេ ? សេចក្ដីថ្លៃថ្នូរកើតមកដោយសារអ្វី ? សូមអស់លោកគ្រូ-អ្នកគ្រូ ពិចារណាខ្លួនឯងចុះ ។ ខ្ញុំមិនបាច់ធ្វើអត្ថាធិប្បាយអោយវែងឆ្ងាយតទៅទៀតទេ ។

នេះជាបញ្ហាមួយនៃរូបកាយខាងក្រៅ មានការរៀបចំខ្លួនប្រាណ (សំលៀកបំពាក់, អនាម័យខ្លួនប្រាណ) ។ ប៉ុន្តែមនុស្សគ្រប់រូប ត្រូវមានការគោរពខ្លួនឯងក្នុងការនិយាយស្តី ការបញ្ចេញមតិ ការប្រព្រឹត្តអំពើមួយអោយមានភាពថ្លៃថ្នូរ ។

ខ្ញុំសូមលើកឧទាហរណ៍មួយទៀត ដើម្បីបង្ហាញពីភាពថ្លៃថ្នូរក្នុងពេលប្រជុំ ពេលសំនេះសំនាល ។ល។

នៅក្នុងសាលារៀនមួយ លោកនាយកអញ្ជើញសហការីមកប្រជុំ ដើម្បីដោះស្រាយបញ្ហាសិក្សាអ្វីមួយ ។ សហការីមកជួបជុំអស់ហើយ ។ លោកប្រធានអង្គប្រជុំបានបើកសម័យប្រជុំដូចធម្មតា និង លើកបញ្ហាម្តងមួយៗមករាយការណ៍បង្ហាញរឿង ដើម្បីសុំមតិយោបល់សំរេចពីសហការី ។ អង្គប្រជុំបានប្រុងស្មារតីត្រងត្រាប់ស្តាប់លោកនាយកនឹងពិចារណារកហេតុផល ដើម្បីជូនមតិយោបល់តាមការយល់ដឹងរបស់ខ្លួន ។ នៅពេលនោះ មានសហការីពីរបីនាក់ បានអោយយោបល់ដោយចាកប្រធាននិយាយស្រែកខ្លាំងៗ មិនមានមតិអ្វីជាខ្លឹមសារសោះឡើយ គឺនិយាយអោយតែលឺ ។

សូមពិចារណា តើសហការីនេះគោរពខ្លួនឯងឬទេ ? ឬមួយគាត់ស្រែកឡូឡានេះ ដើម្បីបញ្ចេញថា គាត់ជាអ្នកក្លាហាន អ្នកមានវោហារ ។ សហការីម្នាក់ទៀតជាអ្នកគោរពខ្លួនជាអ្នករម្យទម ថ្លៃថ្នូរ ។ គាត់ប្រុងស្តាប់ គាត់ជញ្ជឹងគិត ដើម្បីរិះរកមតិដោះស្រាយ ហើយគាត់សុំមានមតិ ឬទស្សនៈរបស់គាត់ ដោយនិយាយមានលក្ខណ៍ត្រឹមត្រូវល្អ មិនរិះគន់គេ មិនបន្ទាបបន្ថោកនរណា ។ មតិដ៏មានខ្លឹមសាររបស់គាត់ អាចយកមកអនុម័ត យកជាសេចក្តីសំរេចនៃអង្គប្រជុំ ។

តើសហការីនេះ ទទួលការសរសើរពីអង្គប្រជុំឬទេ ? តើគាត់ជាមនុស្សថ្លៃថ្នូរឬទេ ? ពីព្រោះអ្វី ?

ជាការសន្និដ្ឋាន ការស្គាល់ខ្លួន និងការគោរពខ្លួនឯងដោយខ្លួនឯង នាំអោយអ្នកប្រព្រឹត្តទទួលបានភាពថ្លៃថ្នូរ (La dignité personnelle) និងសេចក្តីរាប់អានពីអ្នកជិតខាង ។ សេចក្តីថ្លៃថ្នូរបានមកពីការហាត់ពត់លត់ដំអោយមានគុណធម៌អោយបានជាមនុស្សល្អ ជាមនុស្សពិត ។ នៅទីនេះ ខ្ញុំលើកតែវប្បធម៌សីលធម៌ (culture morale) ពីរមកជូនជ្រាប គឺស្គាល់ខ្លួនឯង និង គោរពខ្លួនឯងដោយខ្លួនឯង (se connaître et se respecter) ដើម្បីស្នើសុំលោកគ្រូ-អ្នកគ្រូបង្ហាត់បង្រៀនកូនខ្មែរអោយស្គាល់តំលៃខ្លួនជាមុនសិន ។

**យ៉ង់ ឌី**

*កុំស្លាប់ដូចពស់រស់ដូចកង្កែប*
*ត្រូវប្រឹងគប់សេពសិល្បៈវិជ្ជា*
*កុំបណ្តោយតាមយថាកម្មា*
*កុំចាំវាសនាលើកបាយបញ្ចុក ។*

# រឿងព្រេងនិទាន ភ្នំដូនពេញ

----- * -----

នៅខាងចុងសតវត្សទី ១៤ មានយាយចាស់ម្នាក់ជាអ្នកមានសម្បត្តិស្ដុកស្ដមឈ្មោះ **យាយពេញ** ។ គាត់មានលំនៅស្ថានលើទួលមួយពីខាងកើតកូនភ្នំមួយនាក្បែរច្រាំងទន្លេ ។ ថ្ងៃមួយ នៅពេលទឹកទន្លេឡើងជន់ជោរ យាយពេញបានទៅកាន់មាត់ច្រាំង ហើយបានឃើញដើមគគីរមួយដើម អណ្ដែតវិលវល់ក្នុងទន្លេមិនឆ្ងាយប៉ុន្មានពីរូបគាត់ ។ លោកយាយក៏បានពឹងពាក់អ្នកជិតខាងមកកុះករ ដើម្បីទាក់ទាញដើមគគីរនេះមកលើគោក ។ ក្រោយពីការលាងសំអាតដែលប្រឡាក់ជាប់នឹងដើមគគីរនោះ លោកយាយក៏បានប្រទះឃើញនៅក្នុងរន្ធនៃដើមឈើនោះ នូវព្រះពុទ្ធរូបអំពីសំរិទ្ធចំនួន ០៤ អង្គ និងបដិមាមួយទៀតធ្វើអំពីថ្ម ។ បដិមាថ្មនេះ ជាទេវរូបឈរ មានសក់ខ្ពស់ឡើងលើចងជាកំពោយ ដៃម្ខាងកាន់ដំបង និងដៃម្ខាងទៀតកាន់ស័ង្ខ ។ យាយពេញនិងអ្នកជិតខាងគាត់មានចិត្តត្រេកអរជាខ្លាំង ដោយបានប្រទះនូវបដិមាទាំងអស់នេះ ។ ពួកគាត់ទាំងអស់គ្នា នាំគ្នាជញ្ជូនទៅកាន់លំនៅស្ថានយាយពេញ ហើយបានសាងជាជំរកបណ្ដោះអាសន្នមួយសំរាប់តំកល់រូបទាំងនោះ ។ យាយពេញបានពឹងពាក់អ្នកជិតខាង អោយជួយជញ្ជូនដីចាក់បំពេញ ហើយទីនោះ ក៏ក្លាយទៅជាភ្នំមួយ ដែលយើងឃើញសព្វថ្ងៃនេះ ។ ក្នុងឆ្នាំ ១៣៧២ យាយពេញបានអោយគេអាជ្រៀកដើមគគីរនោះ ហើយក៏សាងព្រះវិហារមួយនៅភ្នំនេះ ដើម្បីតំកល់ព្រះពុទ្ធរូបសំរិទ្ធទាំង ៤ អង្គ ។ ចំណែកឯទេវរូបអំពីថ្ម គាត់បានតំកល់ទុកនៅជើងភ្នំទិសខាងកើត ។ ដោយសាររូបនេះ អណ្ដែតតាមទឹកមកពីប្រទេសលាវ យាយពេញក៏ហៅរូបថ្មនេះថា «**អ្នកតាព្រះចៅ** » ជារហូតមក ។ ក្រោយពីកិច្ចការទាំងឡាយបានរួចរាល់អស់ហើយ គេក៏និមន្តព្រះសង្ឃអោយមកគង់នៅជើងភ្នំពីទិសខាងលិច ហើយបានអោយឈ្មោះថា « **វត្តភ្នំដូនពេញ**» ។ ទាំងព្រះពុទ្ធរូបសំរិទ្ធ ៤អង្គ ទាំងអ្នកតាព្រះចៅ មានមហិទ្ធិឫទ្ធិពូកែសក្ដិសិទ្ធិណាស់ តាមការបួងសួង បន់ស្រន់ផ្សេងៗ អ្នកផងទាំងពួងតែងបានទទួលផលតាមបំណងប្រាថ្នា ធ្វើអោយគេមានជំនឿគ្រប់ៗគ្នា ។ ឯឈ្មោះរាជធានីសព្វថ្ងៃដើមឡើយជា «**ភ្នំដូនពេញ**» ។



*ជណ្ដើរឡើងព្រះវិហារ*

## រឿងរ៉ាវតាមព្រះរាជពង្សាវតា : ( La Chronique royale )



រូបសំណាក យាយពេញ

ព្រះមហាក្សត្រខ្មែរ «**ព្រះបរមរាជាធិរាជរាមាធិបតី ព្រះស្រីសុរិយោពណ៌**» នាម «**ព្រះចានពញាយ៉ាត**» សំរេចបោះបង់ចោលទួលបាសាន ហើយមកតាំងរាជវាំងនៅភ្នំដូនពេញ ឯត្រើយខាងលិចនៃទន្លេ «**ច្រាបឈាម**» ។ ព្រះអង្គចាត់បញ្ជូនចៅពញាកែ និង ឧកញ៉ាហោរាធិបតីខៀវ អមដំណើរដោយមន្ត្រី ដែលចេះពិនិត្យកន្លែងសុខល្អ អោយមកកាន់ភ្នំដូនពេញ ។ មន្ត្រីទាំងនោះ ក្រោយពីការពិនិត្យជាក់ស្ដែងនៅកន្លែងនានាតាមក្បួនហោរាសាស្ត្ររួចហើយក៏សំរេចថា មានតែតំបន់ទិសអគ្នេយ៍ នៃភ្នំទេដែលសមរម្យ ហើយក៏នាំដំណឹងនេះទៅទូលព្រះរាជា ។ ព្រះរាជាក៏ត្រាស់បញ្ជាអោយចៅហ្វាយខេត្តទាំងឡាយលើកគ្នាមក ដើម្បីកសាងព្រះរាជស្ថានលើកដីធ្វើកំពែងការពារកសាងរាជវាំង និងរាជដំណាក់ផ្សេងៗ ក្នុងពេលដ៏ឆាប់បំផុត ។ ការងារទាំងឡាយក៏បានរួចរាល់ហើយស្រេច តាមរាជបញ្ជាត្រាស់បង្គាប់រួចនៅឆ្នាំ ១៤៣៤ នៃគ្រិស្តសករាជ នាថ្ងៃ អង្គារ ៩ រោជ ខែ ពិសាខ ឆស័ក ព្រះមហាក្សត្រទ្រង់យាងចេញចោលក្រុងបាសាន ដោយទូកអមព្រះដំណើរដោយមន្ត្រីរាជបរិពារដ៏ច្រើន ឆ្ពោះមកកាន់ភ្នំដូនពេញ ។ ព្រះអង្គត្រាស់បង្គាប់ឧកញ៉ាតេជោស្រី ជាចៅហ្វាយខេត្តសំរោងទងអោយកេណ្ឌកម្លាំងមកជីកដីពីខាងត្បូងភ្នំ ហើយយកអាចម៍ដីនោះ លប់បំពេញជើងភ្នំពីខាងត្បូង ពីខាងកើត និងក្នុងរាជវាំង ។ ព្រះអង្គបញ្ជាអោយលប់បំពេញដីតំបន់នោះ រហូតដល់មាត់ទន្លេ ។ ចាប់ពីនោះមក តំបន់មាត់ទន្លេមានឈ្មោះថា «**កំពង់រាប**» ។ កន្លែងដែលគេជីកយកអាចម៍ដីក៏ ក្លាយទៅជាបឹងមានឈ្មោះថា «**បឹងតេជោ**» តាមងាររបស់អ្នកឧកញ៉ាតេជោ ។

តមក ព្រះរាជាត្រាស់បញ្ជាអោយឧកញ៉ាផ្នូងជាចៅហ្វាយខេត្តបាទី កេណ្ឌកម្លាំងជីកព្រែកមួយ ដើម្បីនាំទឹកពីទន្លេ មកស្តុកនៅស្រះមួយក្នុងរាជស្ថាន សំរាប់តម្រូវការប្រើប្រាស់របស់ប្រជាជន ។ ព្រះអង្គអោយក្រាលថ្មពីលើព្រែកនោះ ដោយទុកដូបជាអូរមួយក្រោមដី ព្រែកនោះគេអោយឈ្មោះថា «**ព្រែកឧកញ៉ាផ្នូង**» ។ ព្រះរាជាត្រាស់បញ្ជាអោយគេជីកព្រែកយកដីមកលើកជាកំពែងការពារក្រុងថ្មី ហើយព្រែកទាំងនោះគេអោយឈ្មោះដូចតទៅ ៖

- ខាងត្បូង «**ព្រែកតាកែវ**»
- ខាងលិច «**ព្រែកអូរគ**»
- ខាងជើង «**ព្រែកពុំពាយ**» តែដោយតំបន់នេះ មានចិនរស់នៅច្រើន ប្រកបរបរដំដែក ធ្វើឧបករណ៍ប្រើប្រាស់

ផ្សេងៗ ទើបគេហៅថា «**វត្តភ្នំដែក**» វិញ ។

តាមបណ្ដោយដងទន្លេ ព្រះរាជាបញ្ជាអោយគេចាក់ដីទប់ ការពារទឹកជំនន់លិចទីក្រុង ។ តំបន់ខាងលិច ជាវាល សំរាប់ធ្វើស្រែ ។

ព្រះរាជាទ្រង់ប្រទានចាមថ្មីថា «ក្រុងចតុមុខ មង្គលសកល កម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរី រដ្ឋរាជសេមា មហានគរ» ។ ឯទន្លេ «ច្រាបឈាម» ទ្រង់អោយគេហៅថា «ទន្លេចតុមុខ» វិញ ។ ច្រើនឆ្នាំកន្លងមក «ព្រះធរាយណ៍រាជា» ជារាជបុត្រច្បង បានទទួលឋានៈជាឧបរាជ ។ ទ្រង់សាងដំណាក់នៅជ្រោយរលួស ។ នៅពេលនោះដែរ ព្រះ «ស្រីរាជា» រាជបុត្រទី ២ ក៏បានតាំងរាជស្ថាននៅខាងលិចព្រែកអូរេក ដែលកន្លែងនោះគេហៅថា «ទួលព្រះស្រី» (ទួលព្រះស្រីរាជា) ។

ពេលនោះ ព្រះវិហារដែលដូនពេញបានកសាងមកអស់កាលជ័យូរមកហើយ ក៏មានសភាពចាស់ទ្រុឌទ្រោម ។ ព្រះមហាក្សត្រក៏សំរេចព្រះរាជបំណងរើសាងសង់ជាថ្មី និងកែប្រែទិដ្ឋភាពនៃភ្នំ ។ ព្រះអង្គអោយគេចាក់ដីពង្រីក និងបន្ថែមកំពស់ភ្នំ រួចហើយកសាងចេតិយធំមួយនៅទីនោះ ។ ចេតិយធំនេះ មានបន្ទប់ពីរ លើក្រោម ក្នុងបន្ទប់នីមួយៗមានអាសនៈមួយ ។ បន្ទប់ខាងលើគឺភាគខាងក្នុងនៃតួចេតិយ ។ បន្ទប់ខាងក្រោមមានទ្វារចេញមកក្រៅគ្រប់ទិសទាំង ៤ ។ កាលនោះ ព្រះអង្គបានកសាងវត្តជាច្រើន មានទីតាំងផ្សេងគ្នា គឺវត្តបំរួនពីរនៅខាងកើតភ្នំ វត្តមួយនៅខាងត្បូងព្រែកចិនដំដែក វត្តមួយនៅមាត់ទន្លេត្រង់ច្រកចូលព្រែកឧកញ៉ាផ្លុង វត្តមួយនៅត្រង់ចេតិយឧណ្ណាលោម និងវត្តមួយទៀតនៅតំបន់ខ្លួបតាយ៉ង ។ រួចហើយព្រះអង្គត្រាស់បញ្ជាអោយគេទៅប្រមូលពុទ្ធរូបសិរីទ្ធពីប្រាសាទនគរវត្ត និងរូបគោថ្មជាច្រើនមកតំកល់នៅលើភ្នំ ។ ពិធីបុណ្យបានប្រព្រឹត្តទៅអស់រយៈពេល ៣ថ្ងៃ ។ ពុទ្ធរូបសិរីទ្ធទាំង ៤ ដែលដូនពេញបានរកឃើញក្នុងរន្ធឈើគគីរ ត្រូវបានតំកល់នៅបន្ទប់លើនៃចេតិយធំ ឯពុទ្ធរូបដែលយកមកពីអង្គរដាក់ទុកនៅជាន់ក្រោមនៃចេតិយ ។ ក្នុងពិធីបុណ្យនេះ ព្រះរាជាបានប្រកាសឈ្មោះវត្តទាំងឡាយដូចតទៅ ៖

- វត្តនៅលើភ្នំឈ្មោះថា «វត្តព្រះចេតិយបពិត» តែអ្នកស្រុកតែងហៅថា «វត្តភ្នំ» ដដែល ។
- វត្តពីរដែលនៅពីខាងកើតភ្នំគឺ : វត្តខាងត្បូងឈ្មោះ «វត្តកោះ» ឯវត្តនៅខាងជើងឈ្មោះ «វត្តលង្កា» គេតំកល់គម្ពីរសាសនានៅទីនេះ ។
- វត្តខាងត្បូងព្រែកចិនដំដែកឈ្មោះ «វត្តពុទ្ធឃោសា» ។

ឈ្មោះវត្តទាំង ៣ ខាងលើនេះ មានប្រពៃណីមាក់ទងទៅនឹងព្រះភិក្ខុ «ពុទ្ធឃោសា» ហើយនឹង «កោះសេរីលង្កា» ។

- វត្តដែលនៅមាត់ច្រកចូលព្រែកឧកញ៉ាផ្លុងឈ្មោះ «វត្តពាមផ្លុង» ហើយព្រះពុទ្ធរូបមាសនៅក្នុងវត្តនោះគេអោយឈ្មោះថា «ព្រះស្រកាលេញ» ។
- «វត្តឧណ្ណាលោម» យកឈ្មោះតាមចេតិយដែលព្រះភិក្ខុអស្សជិ (Assaji) បានតំកល់ព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើមរបស់ព្រះពុទ្ធ ។ នៅពីមុខវត្តឧណ្ណាលោម ព្រះរាជាបានដាំដើមពោធិមួយដើមហៅ «ទេពារក្ស ឬអ្នកតាប្រប» គឺរូបអ្នកតាឃ្លាំងមឿង ។
- «វត្តខ្លួបតាយ៉ង» យកឈ្មោះ «ខ្លួប» ដែលជាមាត់អូរប្រកបដោយដីមានជីវជាតិ ។ អូរនេះគឺតាម្នាក់ឈ្មោះយ៉ងជាអ្នកជីក ។



រូបសំណាក អ្នកតាព្រះចៅ

# កំណត់សំគាល់

- នៅសតវត្សមុននេះ លោក AYMONIER បានឮអ្នកស្រុកនិយាយតៗគ្នាមកថា ឧកញ៉ាតេជោក្រហមកជាអ្នកទទួលសំអាតរៀបចំភ្នំ និងជាអ្នកសាងសង់ចេតិយធំក្នុងគ.ស. ១៦០៥ គឺនៅដើមសតវត្សទី ១៧ ។ គឺចេតិយធំនេះ ដែលគេបញ្ចុះព្រះអដ្ឋិធាតុ ព្រះបាទពញាយ៉ាត ។ រីឯព្រះវិហារត្រូវបានជួសជុលក្នុងរាជ្យព្រះបាទនរោត្តម ។

- ព្រះបាទពញាយ៉ាត គឺព្រះបរមរាជាធិរាជ រាមាធិបតី ព្រះស្រីសុរិយោពណ៍ ទ្រង់គ្រងរាជ្យនៅអង្គរនាគ.ស.១៤៣២ ។ ទ្រង់បោះបង់ចោលធានីអង្គរនៅឆ្នាំ ១៤៣២ មកគង់នៅទួលបាសាន «ខេត្តកំពង់ចាម» ដើម្បីអោយឆ្ងាយពីការឈ្លានពានរបស់កងទ័ពសៀម ដោយទួលបាសានត្រូវទឹកជន់លេច ក៏ប្តូររាជធានីមកភ្នំពេញ នាគ.ស ១៤៣៤ ។

- ទន្លេ «ប្រាបឈាម» សព្វថ្ងៃគឺទន្លេសាប ។
- «បឹងតេជោ» «សព្វថ្ងៃគឺផ្សារធំថ្មី» ចន្លោះមហាវិថីព្រះមុនីវង្ស មហាវិថីព្រះនរោត្តម វិថីតេជោដំឌិននឹងវិថីក្រមួនសរ ។
- រាជស្ថាន «វាំង» កាលនោះប្រហែលនៅត្រង់អគារ អតីតសាលាក្រុងជិតសួនកុមារវត្តភ្នំ ។
- ព្រែកឧកញ៉ាផ្លុង សព្វថ្ងៃជាសួនច្បារពីផ្សារចាស់ទៅសាក្យមុនីចេតិយ «ចន្លោះវិថីកុសុមៈ និងវិថី ឧកញ៉ាផ្លុង» ។
- ព្រែកតាកែវ សព្វថ្ងៃត្រង់ម្តុំផ្សារកាប់គោ ។
- ព្រែកអូរគ ត្រង់ម្តុំពហុកីឡាជាតិអូឡាំពិក ។
- ព្រែកចិនដំដែក ខាងជើងវិថីឧកញ៉ាអ៊ុំ និងវត្តចិនដំដែក ។
- ជ្រោយរលួស គឺអតីតសង្កាត់ផ្សារស្នួន
- ទួលព្រះស្រី ម្តុំខាងជើងវត្តព្រះពុទ្ធត្រង់ប៊ុរីកីឡា
- វត្តកោះ កាលនោះ នៅត្រង់កន្លែងដែលសព្វថ្ងៃជាវិមានរាជរដ្ឋាភិបាល មានសំណល់ចេតិយខ្លះនៅរហូតដល់សព្វថ្ងៃ ។
- វត្តលង្កា កាលនោះស្ថិតនៅត្រង់ចន្លោះភ្នំ និង ទន្លេសាប
- វត្តពុទ្ធឃោសា នៅកន្លែងដដែល ។
- វត្តពាមផ្លុង វត្តនេះត្រូវបានបំបាត់ចោលនៅពាក់កណ្តាលសតវត្សទី ១៩ ដើម្បីរៀបចំអោយទៅជាផ្សារលក់ផ្លែឈើ គឺផ្សារចាស់សព្វថ្ងៃ ។ ឯព្រះស្រកាលេញត្រូវបានយកទៅតំកល់នៅវិហារវត្តឧណ្ណាលោមសព្វថ្ងៃ ។
- អ្នកតាឃ្លាំងមឿង តាមភាសាថៃ គឺអ្នកតាដែលការពារក្រុង ឬរាជធានី សព្វថ្ងៃគ្មានទេ ។
- វត្តខ្ពបតាយ៉ង គឺវត្តបទុមវតី សព្វថ្ងៃ ។ ឯអូរដែលតាយ៉ងជីក គឺត្រង់ស្រះដែលមានបាញ់ទឹកជិតវិមានមិត្តភាពកម្ពុជា-វៀតណាម ។

រៀបចំចងក្រងឯកសារដោយលោក **ពេជ កែម**

«បុរាណវិទ្យា» អគ្គនាយករងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

# ប្រព័ន្ធអប់រំ
## ( Le système éducatif )

ប្រព័ន្ធអប់រំ គឺជាចង្កោម រឺ គឺជាការផ្សុំនៃវត្ថុធាតុជាច្រើន ដែលមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ហើយដោយអន្តរកម្មរួមគ្នា ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ។ ឧទាហរណ៍ : ទីស្តីការក្រសួងអប់រំ យុវជន និង កីឡា ជាអង្គការចាត់តាំងរបស់រាជរដ្ឋាភិបាល ដើម្បីទទួលបេសកកម្មអភិវឌ្ឍន៍ធនធានមនុស្ស ។ បេសកកម្មនេះ នឹងសំរេចបានលទ្ធផលល្អ លុះត្រាតែក្រសួងអ.យ.ក មានការប្រាស្រ័យទាក់ទងយ៉ាងស្វិតល្មួតជាមួយរចនាសម្ព័ន្ធថ្នាក់លើ និង រចនាសម្ព័ន្ធថ្នាក់ក្រោម ។ ក្រៅពីនេះ ក្រសួង អ.យ.ក ត្រូវមានទំនាក់ទំនងនឹងក្រសួងពាក់ព័ន្ធមួយចំនួននៃរាជរដ្ឋាភិបាល នឹងត្រូវមានទំនាក់ទំនងល្អ នឹងបណ្តាប្រទេសដែលស្ម័គ្រមកជួយក្រសួងអប់រំកម្ពុជា ។

ប្រព័ន្ធអប់រំ ប្រមូលផ្តុំជាចង្កោម ដែលមានក្រសួងជាអង្គការដឹកនាំអង្គភាពនៅក្រោមឱវាទ : អគ្គនាយកដ្ឋាន និង នាយកដ្ឋាន អង្គភាពមូលដ្ឋាន គ្រឹះស្ថាន និង វិទ្យាស្ថានថ្នាក់ឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សាមានកិច្ចព្រមព្រៀងថ្នាក់រដ្ឋាភិបាល គ្រឹះស្ថានសិក្សាចំនេះទូទៅ និង មជ្ឈមណ្ឌលផ្សេងៗទៀត ។

ប្រព័ន្ធអប់រំ ប្រសិនជាបង្រួមអោយស្រួលយល់ គឺផ្តុំជាប្រព័ន្ធបី គឺ ១- រដ្ឋបាល និង ហិរញ្ញវត្ថុ, ២- ការសិក្សា, ៣- អធិការកិច្ច ។ ប្រព័ន្ធទាំងបីនេះ ត្រូវបានត្រួតពិនិត្យវាយតំលៃលើការអនុវត្តន៍និងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំ ដោយអគ្គាធិការ (Inspecteur Général ) ។

ខ្ញុំសូមជំរាបថា ប្រព័ន្ធសិក្សា (système d'enseignement)[១] ចែកជាអនុប្រព័ន្ធបីមាន ៖

ក- ចំនេះទូទៅ ( មត្តេយ្យ + បឋម + មធ្យម)

ខ- ឧត្តមសិក្សា

គ- បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

រីឯប្រព័ន្ធអធិការកិច្ចមានបីថ្នាក់ រឺ អនុប្រព័ន្ធ ។ ថ្នាក់កំពូល គឺអគ្គាធិការកិច្ច ។ ថ្នាក់បន្តបន្ទាប់ គឺអធិការកិច្ចការងារគរុកោសល្យ និង ការងារគ្រប់គ្រងគ្រឹះស្ថាន **មធ្យមសិក្សា** ចំនេះទូទៅ និង ឯកជន និង គ្រឹះស្ថាន **មត្តេយ្យសិក្សា** និង **បឋមសិក្សា** រដ្ឋ និង ឯកជន ។

ជាទីបញ្ចប់ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ ឈប់មានវាចា និង សរសេរតទៅទៀត ពាក្យថា ប្រព័ន្ធអប់រំ ១២ ឆ្នាំ ដើម្បីចៀសវាងការភ័ន្តច្រលំប្រព័ន្ធអប់រំ និង ប្រព័ន្ធសិក្សា ដែលខ្ញុំបានពន្យល់រួចមកហើយ ។ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ និយាយ និង សរសេរថា ប្រព័ន្ធសិក្សាចំនេះទូទៅមាន ១២ ឆ្នាំ ។

**យ៉ង់ ធី**

(១)- Enseignement scolaire ក៏បាន




# វិធីតែងកាព្យ ( ត )

-----*-----

ខាងក្រោមនេះ យើងបានលើកយកវិធីតែងកាព្យ បទព្រហ្មគីតិ, បទពំនោល, បទបន្ទោលកាក និង បទភុជង្គលីលា មកជូនលោកគ្រូ-អ្នកគ្រូ បន្តពីលេខមុន ។ វិធីទាំងអស់នេះ យើងបានដកស្រង់ចេញអំពីសៀវភៅតែងកាព្យរបស់បណ្ឌិតៀមប្បង ទាំងឡាយ ដែលមានពីមុនៗមក ។

## **<u>អំពីបទ ព្រហ្មគីតិ</u>**

**មេពាក្យ ៥ និងពាក្យ ៦**

បទព្រហ្មគីតិ ជាបទកំណាព្យមួយរបស់ខ្មែរយើង ដែលមានតាំងពីយូរយារណាស់មកហើយ ។ បទនេះ គេប្រើនសូត្រ រីសរសេរដើម្បី អប់រំ ទូន្មាន ដល់មនុស្សទាំងឡាយ ។ កាលណា គេសូត្របទកំណាព្យនេះ សូរសំលេងបានធ្វើអោយអ្នកស្ដាប់ទាំងឡាយ លន្ធង់លន្ងោច និងធ្វើការត្រិះរិះពិចារណា ។

បទព្រហ្មគីតិមួយល្បះ មានបួនឃ្លា ។

| ឃ្លាទី ១ | ឃ្លាទី ២ | ឃ្លាទី ៣ | ឃ្លាទី ៤ ។ |
|---|---|---|---|
| 00000 | 000000 | 00000 | 000000 ។ |
| 00000 | 000000 | 00000 | 000000 ។ |

ឃ្លាទី ១ និង ឃ្លាទី ៣ មានប្រាំពាក្យ ឬ ប្រាំព្យាង្គ ។

ឃ្លាទី ២ និង ឃ្លាទី ៤ មានប្រាំមួយពាក្យ ឬ ប្រាំមួយព្យាង្គ ។

<u>ឧទាហរណ៍</u> :

ក្មេងកាលពីព្រេងព្រឹទ្ធ សាងសុចរិតទៀងទុកនៅ
សេដ្ឋីផ្ដាំប្រដៅ បុត្រសង្សារទុកក្រោយហោង ។
កូនអើយក្មេងមេបា ចូររក្សាគន់គិតត្រង
ថែទាំចាំរួសរង ប្រុងប្រយ័ត្នប្រយោជន៍យូរ ។
ធម្មតាអ្នកជាជាតិ កាលគេអាថិអោយគិតគូរ
កុំខ្ជិលដេកទទូរ ដល់ថ្ងៃរះពេញពន្លឺ ។
គាក់តែងខ្ញុំកំដរ ចេញទៅរកធ្វើស្រែភ្លឺ

ចិញ្ចឹមគោក្របី　　　　រកខ្សែវល្លិចោះក្រោលឃ្លង ។

( ស្រង់ចេញពីច្បាប់ផ្សេងៗ. ទំព័រ ៨ )

+ **អំពីចំណាប់ចុងចួន ៖**

ពាក្យចួនក្នុងល្បះទី ១ :
- ព្យាង្គទី ៣ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៥ នៃឃ្លាទី ១ ( ចុងឃ្លា )
- ព្យាង្គទី ៥ នៃឃ្លាទី ៣ (ចុងឃ្លា) ចួននឹងព្យាង្គទី ៦ នៃឃ្លាទី ២ ( ចុងឃ្លា )
- ព្យាង្គទី ៣ នៃឃ្លាទី ៤ ចួននឹងព្យាង្គទី ៥ នៃឃ្លាទី ៣ ( ចុងឃ្លា )




- ល្បះទី ១ :




- ល្បះទី ២ :




+ **ពាក្យចួនក្នុងល្បះទី ២ ឬល្បះបន្ទាប់តទៅ ៖**

ពាក្យចួនក្នុងល្បះទី ២ ឬល្បះបន្តបន្ទាប់តទៅ ដូចគ្នានឹងពាក្យចួនក្នុងល្បះទី ១ ដែរ ។ តែបណ្ដាល្បះបន្តបន្ទាប់ទាំងអស់នោះ ត្រូវមានពាក្យ ឬ ព្យាង្គចួនឆ្លងល្បះ គឺព្យាង្គ ឬពាក្យទី ៦ នៃឃ្លាទី ២ នៃល្បះបន្តបន្ទាប់ ត្រូវចួននឹងព្យាង្គ ឬពាក្យទី ៦ ឃ្លាទី ៤ នៃល្បះមុនបន្ទាប់ ។

## អំពីបទ ពំនោល

**( មេពាក្យ ៦ និង ៤ )**

បទពំនោល គឺជាបទប្រៀបបានទឹងការរៀបរាប់ ។ ពំនោលមកពីពាក្យថា «**ពោល**» ។ ពោលគឺ ការរៀបរាប់និយាយ ។

បទពំនោលមួយល្បះ ឬ មួយបទមាន ៣ ឃ្លា ។ ឃ្លាទី ១ មាន ៦ ពាក្យ ឬ ប្រាំមួយព្យាង្គ ។ ឃ្លាទី ២ មាន ៤ ពាក្យ ឬ ៤ ព្យាង្គ ។ ឃ្លាទី ៣ មាន ៦ ពាក្យ ឬ ៦ ព្យាង្គ ។

ឧទាហរណ៍ :
ទិកូនប្រុសស្រីចំណាប់　វិជ្ជាឈើចាប់　ជាច្បាប់ជាទ្រព្យសីរ ។
ដូច្នេះចូរកូនប្រុសស្រី　ថិតផ្ចង់ស្មារតី　រៀនក្តីឈើចាប់កុំអាក់ ។
ឈើជាតិឈើវណ្ណៈ　ពុះពារគ្រោះថ្នាក់　ឧបសគ្គចុះញ៉មពិសី ។
បើកូនឈើទាំងប្រុសស្រី　ជាតិមានសើរ　ទឹកដីរុងរឿងថ្កើងថ្កាន ។
( ស្រង់ចេញពីសិល្បៈតែងកំណាព្យ ពេជទុំក្រវិល. ទំព័រ ៣៥ )

ឧទាហរណ៍ :
កូនខ្លះមិនសំពះម្ដាយ　អ្នកក្រៅនៅឆ្ងាយ　លុតថ្វាយបង្គំនិងក្រាប ។
សម្លាប់សត្វផងមានបាប　ពេលចាយធុំធ្លាប　ត្រីចាបជ្រូកមាន់ទា ។
( ស្រង់ចេញពីមេកាព្យរបស់លោក អៀង សាយ. ទំព័រ ៣ )




នៅក្នុងឧទាហរណ៍ទី ២ យើងសង្កេតឃើញថាពាក្យ «ម្ដាយ» ចួននឹងពាក្យ«ឆ្ងាយ» ដែលស្រៈនឹងតួប្រកបដូចគ្នា ។ ឯពាក្យ «ក្រាប».«ចាប».«ឆ្នាប» និង «ចាប» ក៏មានស្រៈ និង តួប្រកបដូចគ្នាទៀត ។ ដូចនេះ យើងគួរចងចាំថា ពាក្យកាព្យដែលចួនជាប់ពិរោះនោះ គឺគេប្រើព្យញ្ជនៈដដែល។ ។ ស្រៈ និង តួប្រកបដដែល។ផ្ទួនគ្នាក្នុងមួយល្បះ ដោយគេមិនអោយប្លែកខ្យល់សំលេងអក្សរទេ តែគេត្រូវប្រយ័ត្នមិនអោយកប់ពាក្យ បាត់ន័យសេចក្ដីទេ ក្រែងអ្នកអាន ស្ដាប់ មិនដឹងជានិយាយថាម៉េច ។

( មេកាព្យលោក អៀង សាយ. ទំព័រ ៣ )

\+ **អំពីចំណាប់ចុងចួន** :

\- ពាក្យទី ៤ ចុងឃ្លាទី ២ ចួន និង ពាក្យ ឬ ព្យាង្គទី ៦ នៃឃ្លាទី ១ ។ ពាក្យ ឬ ព្យាង្គទី ២ នៃឃ្លាទី ៣ ចួន និង ពាក្យ ឬ ព្យាង្គទី ៤ នៃឃ្លាទី ២ ។

\- ចំណាប់ចុងចួនក្នុងល្បះទី ២ ឬ ល្បះបន្តបន្ទាប់ក៏មានចំនាប់ចុងចួនដូចក្នុងឃ្លាទី ១ ដែរ តែល្បះបន្តបន្ទាប់ ត្រូវមានចំណងចាប់ចុងចួនពីមួយទៅមួយ គឺពាក្យទី ៦ នៃឃ្លាទី ១ នៃល្បះទី ២ ឬ បន្ទាប់ត្រូវមានចំណាប់ចុងចួនទៅនឹងពាក្យទី ៦ នៃ ឃ្លាទី ៣ នៃល្បះមុនបន្ទាប់ ។

## បទបន្ទោលកាក

**( មេកាព្យ ៤ និង ពាក្យ ៦ )**

បទបន្ទោលកាកមួយល្បះមាន ៤ ឃ្លា ។

ឃ្លាទី ១ និងឃ្លាទី ៣ មានបួនពាក្យ ឬ បួនព្យាង្គ ។ រីឯឃ្លាទី ២ និងឃ្លាទី ៤ មាន ៦ ពាក្យ ឬ ៦ ព្យាង្គ ។ បទនេះខ្លះគេហៅថា បទ ពំនោលកាក ។

| | | | | |
|---|---|---|---|---|
| - <u>ល្បះទី ១</u> : | 0000 | 000000 | 0000 | 000000 ។ |
| | ៤ ពាក្យ | ៦ ពាក្យ | ៤ ពាក្យ | ៦ ពាក្យ |
| - <u>ល្បះទី ២</u> : | 0000 | 000000 | 0000 | 000000 ។ |
| | ៤ ពាក្យ | ៦ ពាក្យ | ៤ ពាក្យ | ៦ ពាក្យ |

<u>ឧទាហរណ៍</u> :

| | |
|---|---|
| កំពូលសត្វខ្លា | ហ៊ុងពាលមំសាហារសត្វ |
| គោងប្រុងប្រយ័ត្ន | កុំកាត់ចិត្តជឿថាស្លូត ។ |
| កំពូជលាក់ពុត | គំនិតស៊ុតទ្រុតរហូត |
| ពេលខ្សោយធ្វើស្លូត | បួកពាស្រងូតរាបសារ ។ |

ផែនអនទទន់ភ្លន់ កាន់សីលសូត្រមន្តធម៌អាថ៌
ខុះពិចារណា មនុស្សទន់ចិត្តជឿស៊ប់ ។
ខ្វាឃ្លានសាច់ស្រស់ សាហាវទាំងអស់ពុំឈប់
ឃើញយើងជឿស៊ប់ សង្គ្រប់កាច់កខាំស៊ី ។

( ស្រង់ចេញពីសិល្បៈតែងកាព្យ-ទំព័រ ៣៧ )

+ **<u>ចំណាប់ចុងចួនក្នុងល្បះ</u>** ៖

0000 000000 0000 000000 ។

ពាក្យ ឬ ព្យាង្គទី ៤ នៃឃ្លាទី ២ ចួននឹងពាក្យ ឬ ព្យាង្គទី ៤ នៃឃ្លាទី ១ ។ ពាក្យ ឬ ព្យាង្គទី ៤ នៃឃ្លាទី ៣ ចួននឹងពាក្យ ឬ ព្យាង្គទី ៦ នៃ ឃ្លាទី ២ ។ ពាក្យ ឬ ព្យាង្គទី ២ នៃឃ្លាទី ៤ ចួននឹងពាក្យទី ៤ នៃឃ្លាទី ៣ ។

+ **<u>ចំណាប់ចុងចួនឆ្លងល្បះ</u>** ៖

ល្បះទី ១ : 0000 000000 0000 000000 ។

ល្បះទី ២ : 0000 000000 0000 000000 ។

ចំណាប់ចុងចួនពីល្បះមួយទៅល្បះបន្តបន្ទាប់ មានចំណាប់ចុងចួនក្នុងល្បះដូចឃ្លាទី ១ ដែរ តែចំណាប់ចុងចួនឆ្លងល្បះគឺ ពាក្យ រឺ ព្យាង្គទី ៦ នៃឃ្លាទី ២ នៃល្បះទី ២ ត្រូវចួននឹងពាក្យទី ៦ នៃឃ្លាទី ៤ នៃល្បះមុន ។

## បទភុជង្គលីលា

( មេកាព្យ ៦ និង ៤ )

បទភុជង្គលីលាមួយល្បះ មាន ៣ ព្យាង្គ ។ ឃ្លាទី ១ មានពាក្យប្រាំមួយពាក្យ ឬ ព្យាង្គឃ្លាទី ២ បួនព្យាង្គ ឬបួនពាក្យ. និងឃ្លាទី ៣ មានបួនព្យាង្គ ឬបួនពាក្យដែរ ។

<u>ឧទាហរណ៍</u> :

នេះបទកំណត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី
កាលនាងឥន្ទវតី ចរចាកតាមប្ដី គឺបុណ្ណកយក្សា ។
នាងវិមលាជាព្រះមាតា លើកបន្ទូលថា ហៃកូនពិសី
នាងនឹងត្រាច់ត្រង់តាមប្ដី ចេញចាកអំពី ពិភពនាគនេះ ។
នៅឋានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បំរើស្វាមី
ធ្វើវត្តប្រតិបត្តិប្រក្រតី កុំអោយស្វាមី អាក់អន់ចិត្តា ។
នាងអើយកម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ

( ស្រង់ចេញច្បាប់ស្រី-ច្បាប់ផ្សេងៗ.ទំព័រ ២០ )

+ <u>ចំណាប់ចុងចួន</u> :

ក- <u>ចំណាប់ចុងចួនក្នុងល្បះ</u>




ព្យាង្គទី ៤ នៃឃ្លាទី ២ ចួននឹងព្យាង្គទី ៦ នៃឃ្លាទី ១ ។

ព្យាង្គក្នុងឃ្លាទី ៣ បើមិនចួននឹងព្យាង្គណាមួយក្នុងឃ្លាទី ១ ឬទី ២ ក៏ឥតទាស់ទេ តែបើល្អ ដើម្បីអោយពិរោះរណ្ដំគ្នា ត្រូវអោយព្យាង្គទី ២ ក្នុងឃ្លាទី ៣ ចួននឹងចុងឃ្លាទី ២ ។




+ <u>ចំណាប់ចុងចួនឆ្លងល្បះ</u> ៖

ចំណាប់ចុងចួនឆ្លងល្បះ ពីល្បះមួយទៅល្បះមួយទៀតជាបន្តបន្ទាប់ មានចំណាប់ចុងចួនក្នុងល្បះ ដូចជាល្បះទី ១ ដែរ តែចំណាប់ចុងចួនឆ្លងល្បះ គឺព្យាង្គទី ៦ នៃល្បះទី ២ ឬល្បះបន្ទាប់ ត្រូវចួននឹងព្យាង្គទី ៤ នៃឃ្លាទី ៣ របស់ល្បះខាងដើមបន្ទាប់ ឬចុងឃ្លាទី ៣ នៃល្បះមុនបន្ទាប់ ។




( នៅមានត )

* * *

*កើតមកជាមនុស្សកុំរវល់តែលេង*
*ត្រូវខំប្រឹងប្រែងអោយបានឈ្នះគេ*
*បើមិនបានឈ្នះចូរខំរិះរេ*
*អោយបានស្មើគេក៏ល្អដោយយ៉ាង ។*

# តើខេត្តនៅភូមិភាគឧត្តរ និង ពាយ័ព្យ ត្រូវបានប្រគល់មកអោយប្រទេសកម្ពុជាវិញដោយរបៀបណា ?

* * * * * *

ខេត្តនៅភូមិភាគឧត្តរ និង ពាយ័ព្យនៃប្រទេសកម្ពុជា មានព្រំប្រទល់ជាប់នឹងប្រទេសសៀម ។ ប្រទេសខ្មែរនិងសៀម ធ្លាប់មានទំនាក់ទំនងនឹងគ្នាតាំងពីសម័យអង្គរ គឺចាប់តាំងពីការកកើតរាជាណាចក្រសុខោទ័យ នាសតវត្សទី ១៣ មកម្ល៉េះ ។ ប៉ុន្តែ ទំនាក់ទំនងទាំងនេះ ភាគច្រើនជាជំលោះដែលបណ្ដាលមកពីបញ្ហាទឹកដី ។ បន្ទាប់ពីតាំងរាជធានីនៅអយុធ្យានៅគ.ស ១៣៥១ សៀមចាប់ផ្ដើមធ្វើការវាយលុកមកលើក្រុងអង្គរជាញឹកញាប់ រហូតដល់ព្រះបាទពញាយ៉ាតបោះបង់ចោលក្រុងអង្គរនៅឆ្នាំ ១៤៣២ ។ ការវាយលុក និង ការជ្រៀតជ្រែករបស់សៀម បានបន្តរហូតដល់សម័យលង្វែក សម័យឧដុង្គទៀត ដែលធ្វើអោយខ្មែរបាត់បង់អស់មួយភាគធំ ។ នៅចុងសម័យឧដុង្គ ដោយអំពើក្បត់របស់មន្ត្រីខ្មែរឈ្មោះបែន ដែលយកខេត្តដែលខ្លួនត្រួតត្រាទៅចុះចូលនឹងសៀម ធ្វើអោយសៀមអាចកាន់កាប់ខេត្ត បាត់ដំបង ស៊ីសុផុន និង អង្គរ នៅក្នុងឆ្នាំ ១៧៩៥ ។ បន្ទាប់មកនៅឆ្នាំ ១៨១៣ សៀមយកបានបន្ថែមទៀត នូវខេត្តមង្គលបុរី ទន្លេរពៅ និង ស្ទឹងត្រែង ។

នៅរវាងឆ្នាំ ១៨៥០ បារាំង និង អង់គ្លេស ចាប់ផ្ដើមពង្វាតការត្រួតត្រាមកលើតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែប្រទេសសៀម មិនដែលស្ថិតនៅក្រោមអាណានិគមកម្មរបស់ប្រទេសអឺរ៉ុបណាមួយឡើយ ។ រីឯប្រទេសកម្ពុជាវិញ ដែលបានទៅពឹងបារាំងអោយជួយការពារ តាំងពីឆ្នាំ ១៨៥៣ នោះ ទីបំផុតបានធ្លាក់ទៅក្រោមអាណាព្យាបាលបារាំង តាមរយៈសន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី ១១ ខែ សីហា ១៨៦៣ ។ ទោះបីជាសន្ធិសញ្ញានេះ បានផ្ដល់ផលប្រយោជន៍យ៉ាងច្រើនចំពោះប្រទេសកម្ពុជាក្ដី ក៏ទន្ទឹមគ្នានេះ បានផ្ដល់នូវផលអាក្រក់ផងដែរ ដោយពុំបានធានានូវបូរណភាពដែនដីខ្មែរ នៅក្នុងព្រំដែនជនជាតិ និង នីតិសាស្ត្រឡើយ ។ ហេតុដូច្នេះហើយ បានជាបាត់ដំបង អង្គរ មង្គលបុរី ទន្លេរពៅ ស្ថិតនៅក្រោមរដ្ឋបាលសៀម ។ បន្ទាប់មកទៀត សន្ធិសញ្ញាបារាំង-សៀម ថ្ងៃទី ១៥ កក្កដា ១៨៦៧ ព្រះរាជាសៀមបានទទួលស្គាល់ជាឱឡារិក នូវរបបអាណាព្យាបាលនៃអធិរាជបារាំងមកលើប្រទេសកម្ពុជា ហើយបារាំងបានទទួលស្គាល់ខេត្តទាំងឡាយ ដែលសៀមកាន់កាប់ពីមុន ។

នៅក្រោមរបបអាណាព្យាបាលបារាំង ខ្មែរមានសមត្ថកិច្ចតែនយោបាយក្នុងប្រទេសប៉ុណ្ណោះ ឯបារាំងវិញ មានតួនាទីខាងផ្នែកនយោបាយក្រៅប្រទេស ហេតុដូច្នេះហើយ បានជាសន្ធិសញ្ញាផ្សេងៗជាមួយប្រទេសសៀម បារាំងជាអ្នកចុះហត្ថលេខា ។ ចាប់តាំងពីបារាំងត្រួតត្រាមក គោលបំណងដំបូងរបស់បារាំង គឺការពង្រីកទឹកដី ដែលកិច្ចការនេះចាប់ផ្ដើមពីពេលបង្កើតសហភាពឥណ្ឌូចិន នៅឆ្នាំ ១៨៨៧ ហើយដំណាក់កាលចុងក្រោយនៃការវាទយកទឹកដីរបស់បារាំង គឺនៅឆ្នាំ ១៩០៧ ហើយក៏ជាឆ្នាំដែលបង្កើតសហភាពឥណ្ឌូចិនពេញលេញដែរ ។ ក្នុងឆ្នាំ ១៨៩៣ សន្ធិសញ្ញាបារាំង-សៀមមួយលើកទៀត ដែលសៀមព្រមបោះបង់ទឹកដីត្រើយខាងឆ្វេងទន្លេមេគង្គ គឺខេត្តស្ទឹងត្រែងមកអោយខ្មែរវិញ ។ ប៉ុន្តែនៅឆ្នាំ ១៨៩៩ ទឹកដីខេត្តស្ទឹងត្រែង ត្រូវភ្ជាប់ទៅនឹងអង្គភាពរដ្ឋបាលឡាវ រហូតមកទល់ថ្ងៃទី ១ មករា ១៩០៥ ទើបខេត្តស្ទឹងត្រែងត្រូវប្រគល់មកអោយខ្មែរវិញ ។ បន្ទាប់មក នៅថ្ងៃទី ៧ តុលា ១៩០២ មានសន្ធិសញ្ញាបារាំង-សៀម ដែលតំរូវអោយសៀមប្រគល់ខេត្តមង្គលបុរី និងទន្លេរពៅមកអោយខ្មែរវិញ ដែលមានផ្ទៃក្រឡា ២០.០០០គម២ ស្មើនឹងមួយភាគប្រាំបួននៃទឹកដីខ្មែរបច្ចុប្បន្ន ។

បារាំងមិនបានបញ្ចប់ការទាមទារទឹកដីពីសៀមឡើយ ព្រោះនៅមានខេត្តខ្មែរជាច្រើនទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម ។ នៅថ្ងៃទី ១៣ កុម្ភៈ ១៩០៤ មានអនុសញ្ញាមួយរវាងបារាំង និង សៀម ។ តាមអនុសញ្ញានេះ បារាំងយល់ព្រមដកទ័ពចេញពីខេត្តចន្ទបុរី តែសៀមត្រូវប្រគល់ខេត្តត្រាត និង ដានសាយទៅអោយបារាំងវិញ ។ លុះមកដល់ខែ មិថុនា ១៩០៦ វរសេនីយឯក ប៊ែរណា (Bernard) បានស្នើទៅរដ្ឋាភិបាលបារាំង អោយប្រគល់ខេត្តត្រាត និង ដានសាយទៅអោយសៀម ដោយប្ដូរមកវិញនូវខេត្ត បាត់ដំបង និង អង្គរ ។ សន្ធិសញ្ញាដែលចុះហត្ថលេខានៅថ្ងៃទី ២៣ មីនា ១៩០៧ រវាងបារាំងនិងសៀម បានចែងថា រដ្ឋាភិបាលសៀម ត្រូវប្រគល់មកអោយបារាំងនូវទឹកដីនៃខេត្តបាត់ដំបង សៀមរាប និង ស៊ីសុផុន ចំណែក រដ្ឋាភិបាលបារាំងត្រូវប្រគល់មកអោយសៀមវិញ

នូវទឹកដីដានសាយ និង ត្រាត ព្រមទាំងកោះទាំងអស់ស្ថិតនៅខាងត្បូងជ្រោយលែមលីង រហូតដល់កោះគុត ដោយរាប់បញ្ចូលទាំងកោះនេះផង ។ ខាងថៃបានទាមទារយកកោះកុងជាច្រើនលើក ដោយសំអាងថា ខេត្តនេះមានជនជាតិថៃរស់នៅច្រើន តែការទាមទារនេះពុំបានសំរេចឡើយ ។ តាមអនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី ២៣ ធ្នូ ១៩០៧ បានប្រគល់ខេត្តបាត់ដំបង, សៀមរាប និង ស៊ីសុផុន ដែលសៀមបានគ្រប់គ្រងអស់រយៈពេល ១១៣ ឆ្នាំ មកអោយព្រះបាទស៊ីសុវត្ថិវិញ ។ សន្ធិសញ្ញា ២៣ មីនា ១៩០៧ នេះ ក៏មានត្រៀមយន្តការនៃការកំណត់ព្រំដែន ។ សំរាប់តំបន់ព្រះវិហារ ផែនទីមួយដែលដាក់ចំណងជើងថា « គណៈកម្មការកំណត់ព្រំដែន រវាងឥណ្ឌូចិន និង សៀម» ត្រូវបានបោះពុម្ពនៅទីក្រុងប៉ារីស ហើយបានបញ្ជូនមកអោយរដ្ឋាភិបាលសៀម និង រាល់សមាជិកសៀមនៅក្នុងគណៈកម្មការចំរុះ នៅឆ្នាំ ១៩០៨ ។ តាមរយៈផែនទីនេះ ខ្សែបន្ទាត់ព្រំដែនកាត់ខាងជើងប្រាសាទព្រះវិហារ ដូច្នេះ ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីខ្មែរ ។ ក្រោយមក សន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩២៥ និង ១៩៣៧ បានអះអាងជាថ្មីឡើងវិញ នូវព្រំដែនឆ្នាំ ១៩០៧ ។

ក្នុងសង្គ្រាមលោកលើកទី ២ រដ្ឋាភិបាលថៃ ស្ថិតនៅក្រោមការដឹកនាំរបស់លោក ភិបុលសង្គ្រាម ជាមួយអ្នកមានគំនិតជាតិនិយម ព្រះអង្គម្ចាស់វិចិត្រវាថកាន និងនៅក្រោមឥទ្ធិពលអ្នកដឹកនាំលំដាប់ខ្ពស់មួយរូប គឺឧត្តមសេនីយទោ ប្រះយូនភូមរ មន្ត្រីដែលមានសញ្ជាតិអាឡឺម៉ង់ ហើយបាននាំរដ្ឋាភិបាលថៃអោយមានសម្ព័ន្ធភាពជិតស្និទ្ធជាមួយប្លុកអាស៊ីស ។ ការឡើងកាន់អំណាចរបស់ជប៉ុននៅឥណ្ឌូចិន បានធ្វើអោយបារាំងចុះកិច្ចសត្យានុភាពយ៉ាងខ្លាំង ហើយទំនាក់ទំនងរវាងថៃ និងជប៉ុន បានធ្វើអោយបារម្ភដល់រដ្ឋាភិបាលបារាំង ដែលបានចុះកិច្ចសន្យាព្រមព្រៀង មិនឈ្លានពានគ្នាមួយ នៅថ្ងៃទី ១២ មិថុនា ១៩៤០ (មុនបារាំងចាញ់អាឡឺម៉ង់) ។ នៅចុងឆ្នាំ ១៩៤០ ក្នុងខណៈដែលប្រទេសបារាំងស្ថិតនៅក្រោមការកាន់កាប់របស់អាឡឺម៉ង់ និង គ្រប់គ្រងដោយរដ្ឋាភិបាលវីស៊ី ថៃយល់ឃើញថា បារាំងក៏កំពុងចុះខ្សោយដែរនៅក្នុងឥណ្ឌូចិន ។ ឆ្លៀតឱកាសនេះ រដ្ឋាភិបាលនិយមជប៉ុនរបស់ភិបុលសង្គ្រាម បានចាប់ផ្ដើមទាមទារមកវិញនូវទឹកដីខ្មែរ និងឡាវ ដែលថៃបានប្រគល់ទៅអោយបារាំងតាមអនុសញ្ញាឆ្នាំ ១៩០៤ និងសន្ធិសញ្ញាឆ្នាំ ១៩០៧ ។ ប្រទេសថៃបានធ្វើការទាមទារទឹកដីជាផ្លូវការ ដោយអនុស្សរណៈ ចុះថ្ងៃទី ១១ កញ្ញា ១៩៤០ ផ្ញើទៅរដ្ឋាភិបាលវីស៊ី ។ ដោយមិនបានលទ្ធផល ថៃបានលើកទ័ពចូលវាយលុកប្រទេសកម្ពុជានៅចុងឆ្នាំ ១៩៤០ ។ ប្រតិបត្តិការសឹកធំៗ បានប្រព្រឹត្តទៅក្នុងខេត្តបាត់ដំបង ។ ក្នុងពេលដែលមានការប្រយុទ្ធគ្នាមិនចាញ់មិនឈ្នះ ជប៉ុនក៏ចូលមកសំរបសំរួល ។ ក្រោយពីកិច្ចចរចាសន្តិភាពប្រព្រឹត្តទៅអស់រយៈពេល ៣៣ ថ្ងៃមក គេបានឈានទៅដល់កិច្ចព្រមព្រៀងបារាំង-សៀម នៅថ្ងៃទី១១ មីនា ១៩៤១ ។ តាមរយៈកិច្ចព្រមព្រៀងនេះ ប្រទេសកម្ពុជាត្រូវបាត់បង់ទឹកដីអស់ប្រហែល ៦០.០០០គម$^2$ និងប្រជាជនចំនួន ៣០០.០០០ នាក់ គឺបាត់បង់ខេត្តបាត់ដំបងទាំងមូល ខេត្តសៀមរាប (លើកលែងតែអង្គរ និងទឹកដីទាំងមូល ឬភាគខ្លះនៃស្រុកពួក សៀមរាប ស្ទូងទ្រនិគម និង ជីក្រែង) ព្រមទាំងភាគខាងជើងនៃខេត្តកំពង់ធំ (ស្រុកជាំក្សាន និង ឆែប) និងទឹកដីមួយភាគធំនៃខេត្តស្ទឹងត្រែង ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ។ សន្ធិសញ្ញាក្រុងតូក្យូ ថ្ងៃទី ៩ ឧសភា ១៩៤១ បានកំណត់ព្រំដែនថ្មី ។

សង្គ្រាមលោកលើកទី ២ បានផុតរលត់ទៅនៅថ្ងៃទី ២ កញ្ញា ១៩៤៥ បក្សសម្ព័ន្ធមិត្តបានឈ្នះក្នុងសង្គ្រាម ។ បារាំងបានទាមទារទឹកដីដែលប្រគល់ទៅអោយសៀមនៅឆ្នាំ ១៩៤១ នោះមកវិញ បើមិនដូច្នេះ ថៃមិនបានចូលជាសមាជិកអង្គការសហប្រជាជាតិទេ ។ បន្ទាប់ពីឧប្បត្តិហេតុនៅសៀមរាប (ថ្ងៃទី ៨ និងទី ១០ សីហា ១៩៤៦ ដោយមានការគាំទ្រពីនាយទាហានសៀម និងការផ្គត់ផ្គង់អាវុធពីប្រទេសសៀម) រដ្ឋាភិបាលបារាំងបានប្រកាសនៅថ្ងៃទី ២៦ សីហា ១៩៤៦ កាត់ផ្ដាច់ការចរចាដែលទើបនឹងផ្ដើមឡើង ដើម្បីប្រគល់ទៅអោយតុលាការអន្តរជាតិក្រុងឡាអេ (ហូឡង់) ធ្វើការសិក្សាលើជំលោះបារាំង-សៀម ហើយតុលាការនេះ នឹងទទួលភារកិច្ចពិនិត្យតំលៃខាងគតិយុត្តិនៃអនុសញ្ញាឆ្នាំ ១៩៤១ ។

កិច្ចព្រមព្រៀងក្រុងវ៉ាស៊ិនតោន ថ្ងៃទី ១៧ វិច្ឆិកា ១៩៤៦ បានចាត់ទុកជាមោឃៈ នូវអនុសញ្ញាឆ្នាំ ១៩៤១ និងបានត្រៀមគណៈកម្មការសំរុះសំរួលមួយ មានភារកិច្ចកំណត់ព្រំប្រទល់ទៅតាមខ្សែព្រំដែនឆ្នាំ ១៩០៧ ។ បីអាទិត្យក្រោយមក គឺខែ ធ្នូ កងទាហានបារាំងបានចូលកាន់កាប់ខេត្តបាត់ដំបង ។ តាមរយៈកិច្ចព្រមព្រៀងនេះ ថៃត្រូវប្រគល់ទៅអោយបារាំងវិញនូវទឹកដីខេត្ត សៀមរាប បាត់ដំបង ស៊ីសុផុន និងទឹកដីដែលស្ថិតនៅត្រើយខាងស្ដាំទន្លេមេគង្គ ។

ដោយក្រុមនិស្សិតប្រវត្តិវិទ្យានៅសាកលវិទ្យាល័យ II - ភ្នំពេញ

# បុរេប្រវត្តិនៃកម្ពុជា ( ត )

## វប្បធម៌ អារ្យធម៌ នាសម័យបុរេប្រវត្តិនៅកម្ពុជា

* * * * *



រូបទី១២ គំនូរលើថ្ម មនុស្សនៅកំស្រ បុរេប្រវត្តិ ស.វ.ទី៥-៣ មុន គ.ស

មុនដំបូងបង្អស់ គួរកត់សំគាល់ថា ខុសពីសត្វ មនុស្សចេះប្រើប្រាស់ឧបករណ៍គ្រប់ប្រភេទ ។ ការស្ថាបនា ឬការនិយមនូវគ្រឿងសំភារៈនេះ សអោយឃើញថា មនុស្សយើងចេះគិតគូរពិចារណា ពោលគឺប្រកបដោយបញ្ញា ឬ ប្រាជ្ញា ។ អាស្រ័យហេតុនេះហើយ បានជាក្នុងការស្រាវជ្រាវ រកប្រភពអរិយធម៌នៃសញ្ជាតិនីមួយៗ អ្នកប្រាជ្ញបុរេប្រវត្តិពឹងផ្អែកទៅលើវត្ថុបុរាណ ដែលជាផលិតកម្មរបស់មនុស្សសុទ្ធសាធ ។

ថ្វីបើបុរេប្រវត្តិប្រទេសកម្ពុជា មានអាយុតិចជាងបុរេប្រវត្តិនៃប្រទេសអាហ្វ្រិកខ្លះក៏ដោយ ជាពិសេស ប្រទេសតង់ហ្សានី ដែលមានអាយុប្រមាណ ១ លានឆ្នាំកន្លះ ក៏បុរេប្រវត្តិខ្មែរមានចំណាស់ស្មើប្រទេសនានាក្នុងសកលលោកដែរ ដោយសំភារៈថ្មដំបូងបំផុតដែលគេបានរកឃើញ មានអាយុប្រហែល ៦៨០.០០០ ឆ្នាំមុនគ្រីស្តសករាជ ។

អាងលើការរកឃើញនូវគ្រឿងឧបករណ៍ប្រើប្រាស់បុរាណច្រើនប្រភេទទាំងអស់នោះ យើងអាចសន្និដ្ឋានយ៉ាងប្រាកដថា នៅលើទឹកដីកម្ពុជាយើងនេះ មានមនុស្សរស់នៅតាំងពីសម័យមុនប្រវត្តិសាស្ត្រម៉្លេះ ហើយជនជាតិខ្មែរជាជនជាតិដែលកើតឡើងនៅលើជ្រោយសុវណ្ណភូមិនេះ ។



រូបទី១៣ គំនូរលើថ្ម រូបបុព្វបុរស ស.វ.ទី៥-៣ មុន គ.ស

ម្យ៉ាងវិញទៀត ដោយសារកំណាយជាច្រើនដែលគេបានរកឃើញនៅលើទឹកដីកម្ពុជានាបច្ចុប្បន្ននេះ គេអាចអះអាងថា បុរេប្រវត្តិខ្មែរមានការរីកចំរើនល្អគួរសម និងការវិវត្តន៍ពីយុគថ្មគ្រួស រហូតដល់យុគលោហធាតុដូចប្រទេសនានាក្នុងសកលលោកដែរ ។

ប្រភពវប្បធម៌អារ្យធម៌ខ្មែរ បានកើតឡើងមុនឥទ្ធិពលឥណ្ឌា ដែលជះកាំរស្មីលើសង្គមខ្មែរតូចៗ ដែលស្ថិតនៅក្រោមការដឹកនាំត្រួតត្រារបស់មេកន្ទ្រាញ ។ ដោយការប្រៀបសិក្សាប្រភេទគ្រឿងឧបករណ៍ប្រើប្រាស់ទាំងអស់នោះ ធ្វើឡើងក្នុងយុគសម័យថ្មបុរេប្រវត្តិវិទូខ្មែរចែកបុរេប្រវត្តិខ្មែរជា ៥ សម័យសំខាន់ ដែលមានដូចតទៅនេះ ៖

១- <u>សម័យថ្មគ្រួសបំបែក</u> :

អាយុពី ៦៨០.០០០ ឆ្នាំដល់ ១២០.០០០ មុនគ្រិស្តសករាជ យុគនេះអាចទុកជាដើមសម័យអារ្យធម៌ខ្មែរ ហើយការចងក្រងទំព័រប្រវត្តិសាស្ត្រកម្ពុជា ត្រូវស្ថិតទៅលើសំភារៈវប្បធម៌កម្ពុជាដំបូងបង្អស់នេះជាមូលដ្ឋាន ។

នៅក្នុងសម័យនោះ មនុស្សប្រើថ្ម ឬគ្រួសធំៗ មានទំហំប៉ុនកដៃ កជើង ធ្វើជាគ្រឿងអាវុធ ឬឧបករណ៍ដោយបំបែកអោយមានមុខមុតដូចជាពូថៅ ឬពន្លាកជាដើម ។ គ្រួសធំៗដែលគេយកមកធ្វើប្រដាប់ប្រដាប្រើប្រាស់ ភាគច្រើនជាគ្រួសសាមញ្ញដែលគេជួបប្រទះនៅតាមដងស្ទឹង ឬ មាត់ទន្លេផ្សេងៗ ។

ដោយសំអាងទៅលើអាវុធ ឬឧបករណ៍សម័យនោះដែលធ្វើឡើងដោយថ្មគ្រួសបំបែក គេក៏តាំងឈ្មោះថា ជាសម័យអារ្យធម៌គ្រួសបំបែក ។

វប្បធម៌នេះ ចាប់ផ្តើមឡើងពីសម័យក្រោយបំផុតនៃ **តតិយស័ក** (Pliocène)[១] ដល់សម័យចុងក្រោយបំផុត នៃ **ចតុត្ថស័ក** (ère quaternaire) ដែលចាប់ផ្តើមពី១.០០០.០០០ ឆ្នាំ ដល់សព្វថ្ងៃនេះ ។ នៅកម្ពុជាយើង វប្បធម៌គ្រួសបំបែកនេះផ្តើមនៅពាក់កណ្តាល **ប្លេអ៊ីស្តូសែន** ហើយបញ្ចប់នៅចុងសម័យនេះ រវាង ៦៨០.០០០ និង ១២០.០០០ ឆ្នាំ ។

សម័យនេះ មនុស្សពុំទាន់មានសេចក្តីចំរើនដូចសម័យក្រោយទេ ពោលគឺពុំទាន់ចេះដាំដើមឈើយកផ្លែស៊ី ឬក៏ចិញ្ចឹមសត្វពាហនៈ ដើម្បីយកសត្វធ្វើជាចំណីអាហារនៅឡើយទេ ។ គេគ្រាន់តែចេះចាប់សត្វព្រៃហែកស្បែកវាដោយធ្មេញទទេ ហើយបរិភោគឆៅតែម្តងប៉ុណ្ណោះ ឬក៏បេះស្លឹកឈើ ផ្លែឈើ ឬគាស់មើមឈើតាមព្រៃភ្នំ ។

ម្យ៉ាងទៀត បុព្វបុរសយើងប្រហែលជាពុំទាន់ជាចេះប្រើភ្លើងនៅឡើយទេ ពីព្រោះរហូតដល់ពេលនេះ ឯកសារវប្បធម៌ដែលគេជួបប្រទះទាំងប៉ុន្មាន ពុំអាចជំរុញអោយយើងហ៊ានសន្និដ្ឋានអំពីបញ្ហានេះអោយបានច្បាស់លាស់ដែរ ។

លោកបុរេប្រវត្តិវិទូ **សេតមុខសុវាំង** បានជួបប្រទះឧបករណ៍នេះជាដំបូងបំផុតនៅឆ្នាំ ១៩៦៣ នៅលើទឹកដីកម្ពុជាសព្វថ្ងៃនេះ នៅក្នុងភូមិភាគដែលស្ថិតនៅតាមដងទន្លេមេគង្គ រវាងស្ទឹងត្រែង និងសំបោរ ជាពិសេស នៅភូមិស្បូវ ឬភូមិឫស្សី ។ល។



- រូបទី ១៤ របៀបធ្វើឧករណ៍ នាសម័យបុរេប្រវត្តិសាស្ត្រ



១



២

**រូបទី១៥ របៀបធ្វើឧបករណ៍ នាសម័យបុរេប្រវត្តិសាស្ត្រ**

(១)- ភូគព្ភសាស្ត្រ ប្រើស័ក (ère) ដើម្បីកំនត់ការបែងចែកប្រវត្តិផែនដីរៀងតាមកាល : បឋមស័ក ទុតិយស័ក តតិយស័ក ចតុត្ថស័ក ។

តាមអ្នកស្រាវជ្រាវបារាំងសែសនោះ វត្ថុបុរាណទាំងអស់នោះ មានអាយុប្រហែល ៦៨០.០០០-៥០០.០០០ឆ្នាំ មុនគ្រិស្តសករាជ ។ សូមបញ្ជាក់ថា អ្នកប្រាជ្ញដដែលនេះ ក៏បានរកឃើញនូវឧស្សាហកម្មថ្មបំបែកបែបនេះ ក្នុងប្រទេសយួនខាងត្បូង ឬ កម្ពុជាក្រោមនៅតាមដងស្ទឹងដូនណៃ ។

ម្យ៉ាងវិញទៀត យើងអាចសំគាល់ឃើញថា យួនខាងជើង (នៅតំបន់ឈើដូ) ប្រទេសឡាវ (នៅថាំហោង) ប្រទេសភូមា (នៅតាមដងទន្លេអៀរ៉ាក្វាឌី) ប្រទេសឥណ្ឌូណេស៊ី (នៅកោះជ្វាហ្សារ៉ា) ប្រទេសទាំងអស់នេះ ក៏មានឧស្សាហកម្ម ថ្មបំបែកដូចគ្នានឹងកម្ពុជាដែរ រីឯអាយុវិញក៏ប្រហាក់ប្រហែល នឹងឧបករណ៍ដែលគេរកឃើញនៅកម្ពុជា និង កម្ពុជាក្រោមដែរ ។

## ២- យុគថ្មបុរាណ :

មានអាយុប្រមាណ ១២០.០០០ ដល់ ១២.០០០ឆ្នាំ មុនគ.ស.ក្នុងសម័យនេះ មនុស្សមានការរីកចំរើនផ្នែកវប្បធម៌ ហើយដូចជាការរកឃើញធាតុភ្លើងសំរាប់ចំអិនប្រចាំថ្ងៃ និងការស្ថាបនាឧបករណ៍ប្រើប្រាស់ជាសក្តិភាព ។

ខុសពីសម័យមុន ដែលគេគ្រាន់តែរើសយកថ្មធម្មជាតិមកពុះជាពីរ ឬជាបី ដើម្បីយកមុខមុតធ្វើជាអាវុធមុខតូចៗ ។ ដូចជាខ្នោសជាដើម សំរាប់កោសស្បែកសត្វ រួចនាគ្រឿងឧបករណ៍ផ្សេងៗ ឧស្សាហកម្មថ្មមានទ្រង់ទ្រាយល្អិតល្អន់ជាងមុន ។ «រូបភាព» ។ គេជួបប្រទះក្នុងសម័យនេះ នូវពូថៅថ្មមានរូបរាងត្រីកោណ ឬចតុកោណកែង ដែលមានលក្ខណៈល្អប្រណីត ។

ការរកឃើញឧបករណ៍ ព្រមទាំងសំណល់ម្ហូបអាហារដូចជា ឆ្អឹងសត្វជាដើម ភ្ជាប់ជាមួយនឹងខ្មោច បញ្ជាក់អោយឃើញថា មនុស្សនេះគោរពសព នេះសែនព្រេនបុព្វបុរសគេដែលបានចែកឋានទៅ ។ គួរបញ្ជាក់ថា មនុស្សនៅតាមរូងរាប តាមរានេ ឬក្នុងរូងភ្នំជាធា ។

ក្នុងវិស័យសេដ្ឋកិច្ច ការសិក្សាគ្រឿងសំភារៈប្រើប្រាស់ដែលគេរកឃើញបង្ហាញអោយយើងដឹងថា ក្នុងយុគសម័យនេះ មនុស្សពុំទាន់ចេះរំលីងថ្ម ក្បាញ បិញ្ចឹមសត្វ ឬ ដាំដើមឈើ ឬ ស្រូវនៅឡើយទេ ។



៣
ឧបករណ៍យុគវប្បធម៌ បុរមបុរាណ ស្ទឹងព្រែកត្រូច



- រូបទី ១៦ ឧករណ៍យុគថ្មបំបែក - យួនខាងត្បូង កម្ពុជាក្រោម -



- រូបទី ១៧ អាវុធថ្ម ថ្មនៅកម្ពុជាក្រោម និង នៅកញ្ចាណាប៊ុរី



រូបទី១៨ អាវុធថ្មយុគ បុរមបុរាណ បាត់ដំបង

## ៣- សម័យថ្មបំបែកក្លាយ

វប្បធម៌បំបែកក្លាយពី ១២.០០០ ដល់ ៨.០០០ ឆ្នាំ មុនគ.ស. វប្បធម៌នេះ មានដើមកំណើតចេញពីវប្បធម៌មុន ។ នៅតាមគុហារភ្នំខ្លះ គេបានជួបប្រទះនូវសំភារៈខ្លះៗ ដែលធ្វើអំពីថ្មក្នុងស្រទាប់ដី ដែលលាយឡំជាមួយសរីរាង្គមនុស្ស ។

លក្ខណៈនៃសម័យនេះ មិនខុសពីសម័យមុនទេ គ្រាន់តែមានរបៀបប្រសើរជាងមុន ។

គួរគប្បីបញ្ជាក់ថា ឆ្អឹងលលាដ៍មនុស្សដែលគេរកឃើញមានលក្ខណៈជាឥណ្ឌូណេស៊ីយ៉ាង មន ខ្មែរ មិនខុសពីពួកខ្មែរលើដែលជាបុព្វបុរសរបស់ជនជាតិខ្មែរសព្វថ្ងៃនេះទេ ។

តាមឯកសារដែលគេបានស្រាវជ្រាវ មនុស្សនេះស៊ីគ្រាប់ធម្មជាតិព្រៃចាប់ផ្ដើមចេះរំលីងថ្ម ឬផ្សាំងសត្វព្រៃ ។ លើសពីនេះទៅទៀត ការសិក្សាពីបុព្វប្រវត្តិនៃសម័យនេះ បង្ហាញអោយយើងដឹងថា ជនជាតិខ្មែរដើម ឬមន-ខ្មែរ នៅចុងយុគសម័យនេះបានចាប់ផ្ដើមធ្វើឆ្នាំង ចាន ដោយដីដុត ។ តែភាជន៍ដីទាំងអស់នោះ ពុំទាន់មានសភាពបំរើន ឬគុណភាពល្អប្រពៃដូចសម័យក្រោយទេ ។ ក្នុងសម័យនោះ ពុំទាន់មានការរំលីងថ្មនៅឡើយទេ ។

( នៅមានត )

ដោយលោក **មីសេល ត្រាណេ**



**រូបទី១៩ ពូថៅយុគបំបែកក្លាយ ប្រមាណ៨០០០ឆ្នាំ មុនគ.ស**



**រូបទី២០ ពូថៅថ្មរំលីង សៀមរាប ១៥០០ឆ្នាំ មុន គ.ស**

* * *

# សេចក្តីពន្យល់បន្ថែមពីសម័យបុរេប្រវត្តិនៅកម្ពុជា

ក្នុងគោលបំណងបំពេញបន្ថែមចំណេះដឹងទូទៅនៃបុគ្គលិកសិក្សាយើងពីបុរេប្រវត្តិកម្ពុជា ដែលទស្សនាវដ្តីគ្រូបង្រៀនលេខ ៨ បានចាប់ផ្សាយផ្នែកខាងដើមរួចមកហើយ និងបានចុះក្នុងលេខ ៩ បន្តទៀតនោះ ខ្ញុំសូមលើកយកពាក្យខ្លះមកពន្យល់ដូចតទៅ ៖

**ភ្លឺខ** : ( ទស្សនាវដ្តីលេខ ៨ ទំព័រ ៤៥ )

១- **ក្លឹង និង ឥណ្ឌា** :

ក្លឹងជានរណា ? <u>ចំលើយ</u> : ក្លឹង ជាឈ្មោះដែនមួយ (Kalinga) នៅក្នុងមជ្ឈិមនៃប្រទេសឥណ្ឌា ។ ប្រជាជនដែលរស់នៅក្នុងដែននោះ ហៅថា ក្លឹងដែរ ។ ក្លឹងមាននៅកម្ពុជាយើង មុនឆ្នាំ ១៩៧៥ ច្រើនជាអ្នកលក់គ្រណាត់សំពត់នៅខាងជើងផ្សារថ្មី ។ ដូចនេះ ក្លឹងគឺជាជនជាតិឥណ្ឌាភាគខាងត្បូង និងច្រើនមានសម្បុរខ្មៅ ។

ចំណែកពាក្យ ឥណ្ឌា គឺជាឈ្មោះប្រទេស និងប្រជាជនរស់នៅលើទឹកដីនៃប្រទេសនេះតែម្តង ។ ឥណ្ឌាហៅតាមអង់គ្លេស INDIA តាមបារាំងថា INDE ។ ប្រទេសឥណ្ឌា ជាសហព័ន្ធសាធារណរដ្ឋ មាន ២៥ រដ្ឋ និង អាណាខេត្ត ៧ ទៀតចូលរួម ។

* **សូមរកឯកសារដើម្បីអានអោយចេះចាំពីប្រទេសឥណ្ឌា ។**

**២- តាំងហ្សានី** : អត្ថបទក្នុងទស្សនាវដ្តីលេខ ៩ នេះ មានប្រទេសតាំងហ្សានី (TANZANIE) ដែលមានអាយុប្រមាណ ១ លានឆ្នាំកន្លះមកហើយ ។ តើប្រទេស Tanzanie នៅឯណា ?

សូមជំរាបថា ប្រទេស Tanzanie - Ethiopie - Kenya - Ouganda - Somalie ជាប្រទេសដែលសត្វស្វាមនុស្សចាប់កំនើតមុនគេ ។ ប្រភពកំនើតមនុស្ស គឺនៅលើទឹកដីអាហ្វ្រិកខាងកើត ។ សត្វស្វាមនុស្សវិវត្តក្នុង ៥ ដំណាក់កាល ។




ដល់ដំណាក់កាលទី ៣ (Homo érectus) គឺ ១ លានកន្លះឆ្នាំ មុនគ.ស ។ មនុស្សស្វាដែលបានឈរត្រង់ខ្លួន ហើយបានចាកចេញពីទីតាំងកំនើតរបស់ខ្លួន នាំគ្នាដើរជាពួកៗទៅភាគខាងត្បូងនៃប្រទេស អាស៊ី និង អឺរ៉ុប ។ ដល់ដំណាក់កាលទី ៥ គឺ Homo sapiens sapiens គេឃើញមនុស្សដើមនេះ មានអត្ថិភាពសាយភាយមកដល់ប្រទេសអូស្ត្រាលី អាស៊ីខាងជើង និង អាមេរិច ។ ហេតុអ្វីបានជាមនុស្សជំនាន់នោះ បានទៅដល់អាមេរិច ? ទៅតាមផ្លូវណា ? គឺតាមដែសមុទ្របេរិញ (Détroit de Béring) គឺជាដែសមុទ្រនៅចន្លោះអាស៊ី និង អាមេរិច ភ្ជាប់មហាសាគរប៉ាស៊ីហ្វិច និងមហាសាគរអាកទិច ។ សូមរកមើលក្នុងផែនទីពិភពលោកភាគខាងជើង ។ ម្តេចក៏ឆ្លងទៅបាន ? តើបានអ្វីឆ្លង ? គឺនៅពេលនោះ ប្រទេសអាស៊ី និង អាមេរិច ជាប់គ្នាត្រង់ដែសមុទ្របេរិញ ដោយសារទឹកកក (glaciation) ។

គេឆ្លងជាច្រើនលើកច្រើនសា ។ តាមឯកសារខ្លះថា តាំងពី ១០០.០០០ ឆ្នាំ មុនគ.ស ។ ឯកសារខ្លះទៀតថា តាំងពី

៤០.០០០ ឆ្នាំ មុនគ.ស. ។ អាស្រ័យហេតុនេះ បានជាយើងឃើញជនជាតិស្បែកក្រហម (Peaux Rouges) រស់នៅមកដល់សព្វថ្ងៃ ។

រីឯពួកមនុស្សដើម ដែលមកដល់ឥណ្ឌូណេស៊ីបែកចេញខ្លះទៅតាំងលំនៅដ្ឋាននៅប្រទេសអូស្ត្រាលី និង ណូវែលហ្គីណេ (Nouvelle Guinée) ប្រមាណជា ៥០.០០០ ឆ្នាំមកហើយ ។

មកដល់ត្រង់នេះ ដើម្បីកុំអោយអត្ថបទនេះវែងពេក ខ្ញុំសូមមិនបន្តនិយាយពីពួកមនុស្សដែលដើរភាគខាងត្បូងនៃទ្វីបអឺរ៉ុបឡើយ ។ ខ្ញុំទុកឱកាសអោយលោកគ្រូ-អ្នកគ្រូ ស្វែងយល់ដោយខ្លួនឯង ។

ខ្ញុំត្រលប់មកនិយាយពីខ្មែរយើងវិញ ។ ការសិក្សាអំពីបុរេប្រវត្តិសាស្ត្រខ្មែរបានចាប់ផ្តើមតាំងពីពាក់កណ្តាលទី ២ នៃសតវត្សទី ១៩ ។ ពួកអ្នកស្រាវជ្រាវបារាំងបានរកឃើញស្ថានីយ៍បុរេប្រវត្តិសាស្ត្រជាច្រើនកន្លែង នៅលើទឹកដីយើង ។ នៅឆ្នាំ ១៩៦៣ និង ១៩៦៦ លោកអេតម៉ុង សូរាំង (Edmond Saurin) បានរកឃើញស្ថានីយ៍យុគថ្មបំបែកដំបូងបង្អស់នៅក្នុងតំបន់ចន្លោះស្ទឹងត្រែង និង ស្នួល នៅត្រើយខាងឆ្វេងទន្លេមេគង្គ ដែលមានអាយុជាង ៥០០.០០០ ឆ្នាំមុនគ.ស ។ អ្នកស្រាវជ្រាវបានរកឃើញស្ថានីយ៍យុគថ្មរំលីង និងយុគលោហៈជាច្រើនកន្លែងទៀត (សូមមើលទីតាំង និងអាយុកាលនៃស្ថានីយ៍ទាំងនោះ ក្នុងផែនទីខាងក្រោម) ។ យើងអាចដឹងអំពីកាលសម័យបុរេប្រវត្តិសាស្ត្រខ្មែរ តាមរយៈការរកឃើញទាំងនោះ ។ យើងគប្បីស្វែងរកបន្តទៀត ដើម្បីអោយបានស្គាល់កាលសម័យនោះ កាន់តែប្រសើរឡើង ។




ផែនទីស្ថានីយ៍បុរាណវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ថតចំលងចេញពីសៀវភៅសិក្សាសង្គម «ភូមិវិទ្យា, ប្រវត្តិវិទ្យា, ទំព័រ ១០៥ ថ្នាក់ទី ៧» ។

៣- ជ្វា (JAVA) សូមអានសៀវភៅសិក្សាសង្គមថ្នាក់ទី ៧ ទំព័រ ១៦៦-១៦៧-១៦៨

* * *

**<u>គំនិតត្រិះរិះពិចារណា</u>** :

Homo-Erectus ធ្វើដំណើរចេញពីអាហ្វ្រិចខាងកើត នៅភាគខាងត្បូងទ្វីបអាស៊ី ត្រូវតែឆ្លងកាត់ប្រទេសមួយចំនួន អាប់ការនីស្ថាន, ឥណ្ឌា, ភូមា, ថៃ ទើបមកដល់កម្ពុជា ។ ក្រុមមនុស្សដើមនេះ តាំងលំនៅដ្ឋាននៅលើទឹកដីកម្ពុជាតែម្តង រឺមួយធ្វើដំណើរទៅរហូតដល់ប្រទេសម៉ាឡេស៊ី និង ឥណ្ឌូណេស៊ី ទើបត្រលប់មកនៅស្រុកខ្មែរវិញរឺ ?

**យ៉ង់ ឌី**

LES MIGRATIONS HUMAINES AUX TEMPS PRÉHISTORIQUES

ដំណើរផ្លាស់ប្តូរទីលំនៅរបស់មនុស្សនៅដំណាក់កាលបុរេប្រវត្តិ





## បញ្ហាអក្សរមូល រឺ អក្សរធំខ្មែរ

នៅក្នុងឆ្នាំ ១៩៦៩. កាលខ្ញុំជាសមណសិស្សថ្នាក់ឆ្នាំទីមួយ នៃពុទ្ធិកវិទ្យាល័យ**ព្រះសុរាម្រឹត** (ក្រុងភ្នំពេញ) ក្នុងម៉ោងសិក្សា ស្ដីពី «**ប្រវត្តិភាសា និង អក្សរខ្មែរ**» សមណសិស្សរួមថ្នាក់របស់ខ្ញុំជាច្រើនអង្គ បានលើកយកបញ្ហា **អក្សរមូល រឺ អក្សរធំខ្មែរ** មកពិភាក្សាគ្នាយ៉ាងតឹងសរសៃក ក្រោមការសំរបសំរួលរបស់សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរយើង ។

សមណសិស្សទាំងនេះ បានធ្វើការរិះគន់ចំពោះមតិខ្លះដែលថា គួរសរសេរ **អក្សរមូល ឬ អក្សរធំ** ក្នុងករណីដូចតទៅនេះ

១- នៅដើមឈ្មោះនីមួយៗតាមបែបអឺរ៉ុប

២- ចំពោះពាក្យអសាធារណ៍

ពួកយើងបានបញ្ចេញយោបល់ថា : «ទង្វើបែបនេះ នាំអោយបាត់លក្ខណះជាតិនៃសំនេរខ្មែរ » ។

លោកសាស្ត្រាចារ្យយើង បានសំរបសំរួលមតិរបស់សមណសិស្សទាំងអស់ ដោយបញ្ជាក់ថា លោកយល់ស្របនឹងមតិរិះគន់ចំពោះករណីទី ១ តែលោកមានសំនូមពរអោយពិចារណាឡើងវិញចំពោះករណីទី ២ ។ ដើម្បីជាឧទាហរណ៍ លោកបានលើកយករឿងតំនាលខាងក្រោមនេះមកបញ្ជាក់ ។

### លោកចៅឡាត់ខេត្តស្វាយមិន

ក្នុងសម័យអាណានិគមនិយមបារាំង នៅខេត្តក្រចេះ មានចៅឡាត់ខេត្តម្នាក់ឈ្មោះ **ស្វាយមិន** ។

ថ្ងៃមួយ ក្នុងឱកាសបុណ្យណូអែល លោករ៉េស៊ីដង់ (Résident) បារាំងនៅភ្នំពេញ បានចាត់លិខិតអញ្ជើញចៅហ្វាយខេត្តគ្រប់ខេត្តនៅទូទាំងប្រទេស អោយទៅចូលរួមពិធីនេះនៅភ្នំពេញរយៈពេលបីថ្ងៃ ។ លោករ៉េស៊ីដង់បានបង្គាប់អោយអស់លោកចៅហ្វាយខេត្ត ប្រគល់កិច្ចការខេត្តគ្រប់ផ្នែកអោយចៅឡាត់ខេត្តចាត់ការជាបណ្ដោះអាសន្ន (ផ្ទេរសិទ្ធិ) មុននឹងមកភ្នំពេញ ។ នៅពេលទៅដល់ភ្នំពេញ លោករ៉េស៊ីដង់បានសាកសួរអស់លោកទាំងនោះពីពត៌មានផ្សេងៗក្នុងខេត្ត ដោយសង្កត់ធ្ងន់លើការប្រគល់សិទ្ធិគ្រប់គ្រងខេត្តដល់ចៅឡាត់ខេត្ត ក្រែងមានបញ្ហាអ្វីចោទឡើង ។ ពេលនោះ លោកចៅហ្វាយខេត្តក្រចេះ បានជំរាបលោករ៉េស៊ីដង់ថា លោកបានប្រគល់កិច្ចការអោយចៅឡាត់ខេត្តរួចរាល់ហើយ តែលោកមិនសូវទុកចិត្តលោកចៅឡាត់ខេត្តនេះ សោះ ដោយសារគាត់ចូលចិត្តផឹកស៊ី និងលេងសើចច្រើនពេក ។ លោកសុំអោយលោករ៉េស៊ីដង់វាយខ្សែល្លួសសួរបញ្ជាក់លោកចៅឡាត់ខេត្តថែមទៀតផង ។ លោករ៉េស៊ីដង់ក៏ចាត់អោយវាយខ្សែល្លួសទៅលោកស្វាយមិនភ្លាមមួយរំពេច ។

ទទួលបានពត៌មានពីលោករ៉េស៊ីដង់ លោកចៅឡាត់ខេត្តក៏បារជាកូនលិខិតតូចមួយ ដែលមានសេចក្ដីតែមួយឈ្មះអោយប្ញង់តុងយកទៅជូនលោករ៉េស៊ីដង់ឯភ្នំពេញផ្ទាល់ដៃ ។ សេចក្ដីនៃលិខិតនោះគឺ ៖

«ខ្ញុំឈ្មោះស្វាយមិនព្រមទទួលងារជាចៅហ្វាយខេត្ត» ។

លោករ៉េស៊ីដង់បានអោយអ្នកបកប្រែបកសេចក្តីជាភាសាបារាំងអោយគាត់ស្តាប់ អ្នកបកប្រែពិនិត្យលិខិតនោះ រួចបកប្រែថា ៖

«Je soussigné SVAY ne pas adopter la fonction de CHAOVAY KHET».

ស្តាប់បានសេចក្តីនេះ លោករ៉េស៊ីដង់បារាំងដ៏មានអំនាច ក៏ខឹងក្រេវក្រោធ ហើយបង្គាប់អោយគេវាយខ្សែលួសហៅលោកស្វាយមិនមកជួបនៅភ្នំពេញជាបន្ទាន់ ។ សូមបញ្ជាក់ថា លោករ៉េស៊ីដង់ ពុំចាំឈ្មោះលោកស្វាយមិនទេ ហើយក៏ពុំបានសួរចៅហ្វាយខេត្តក្រចេះពីឈ្មោះរបស់ចៅឡាត់ខេត្តនេះដែរ ។ ដំណឹងនេះបានទៅដល់លោកចៅឡាត់ខេត្តក្រចេះ ស្របពេលដែលគាត់កំពុងរៀបចំចេញដំណើរទៅចូលរួមពិធីជប់លៀងដែលរៀបចំដោយមិត្តភក្តិរបស់គាត់ ។ គាត់ផ្អាកពុំបានទៅចូលរួមពិធីនោះទេ ហើយប្រញាប់ប្រញាល់ឡើងកប៉ាល់មកភ្នំពេញតាមបញ្ជារបស់លោករ៉េស៊ីដង់ ។ លោកស្វាយមិនមកដល់ភ្នំពេញនៅពេលព្រលប់ធំ ។ គាត់សំរាកនៅផ្ទះមិត្តភក្តិគាត់មួយយប់ ។

ព្រឹកឡើង គាត់ចូលទៅជួបលោករ៉េស៊ីដង់នៅសាលប្រជុំធំ ដែលនៅទីនោះ មន្ត្រី អ្នកមុខ អ្នកការគ្រប់ជាន់ថ្នាក់ កំពុងជួបជុំគ្នាល្ហណាស់ ។

គ្រាន់តែលេចមុខលោកស្វាយមិនទៅដល់ភ្លាម លោករ៉េស៊ីដង់គំហកសួរជាភាសាបារាំង អោយអ្នកបកប្រែបកសេចក្តីជាខ្មែរ ប្រាប់លោកចៅឡាត់ខេត្តភ្លាម ។

លោករ៉េស៊ីដង់ : - «មើល៍អាស្វាយ ! ហេតុអ្វីបានជាអាឯងមិនទទួលការងារជំនួសចៅហ្វាយខេត្ត ? »

ក្តាប់បានចំនុចខ្សោយរបស់ដៃគូ លោកស្វាយមិនដែលធ្លាប់មានចរិតមិនសូវខ្លាចនរណាផងនោះ ក៏តបទៅវិញខ្លាំងៗគ្មានសំចៃមាត់ ។

លោកស្វាយមិន ៖ « អាណាប្រាប់ថាអញមិនព្រមទទួលការជួសចៅហ្វាយខេត្ត ? លោកបារាំងឯងក៏ភ្លើ ! អាចឹបកក៏ឆ្កួត ! អញឈ្មោះស្វាយមិន. អញព្រមទទួលហើយតើ !»

អង្គប្រជុំទាំងមូលសើចគិលឡើង ធ្វើអោយលោករ៉េស៊ីដង់ និង ចឹបក ខ្មាស់គេសន្ធឹក ។

លោករ៉េស៊ីដង់ងាកមកសួរអ្នកបកប្រែ ៖ «យ៉ាងម៉េចរឿងនឹង ?»

ថៃបកមុខស្លុយប៉ៃ បែរទៅយកលិខិតដើមរបស់លោកស្វាយមិនមកមើលម្តងទៀត រួចតបថា «ខ្ញុំគិតថាគាត់ឈ្មោះស្វាយ... ដឹងអីគាត់ឈ្មោះស្វាយមិនសោះ ! នេះមកពីការយល់ច្រលំ» ។

លោករ៉េស៊ីដង់ត្រេកអរហួសចិត្ត ! គាត់សារភាពកំហុសនេះចំពោះលោក**ស្វាយមិន** ។ លោករ៉េស៊ីដង់ចាត់អោយរៀបចំទទួលបាយទឹក និងភេសជ្ជៈជូនលោកចៅឡាត់ខេត្តយ៉ាងចាស់ដៃ រួចផ្តល់ប្រាក់លួងចិត្ត និងសោហ៊ុយធ្វើដំណើរជូនគាត់មកក្រចេះវិញ ។

ចាប់ពីមានព្រឹត្តិការណ៍នោះមក លោករ៉េស៊ីដង់បានបង្គាប់អោយសរសេរពាក្យអសាធារណ៍ខ្មែរជាអក្សរធំ ក្នុងលិខិតបុគ្គល ឬផ្លូវការ ដើម្បីចៀសវាងការយល់ច្រលំ ។

តើលោកគ្រូ-អ្នកគ្រូយល់យ៉ាងណាដែរ ចំពោះរឿងនេះ សំរាប់សំនេរខ្មែរបច្ចុប្បន្ន ?

ខ្នុរដំបង. ថ្ងៃទី ១៣ ឧសភា ១៩៩៨

លោក **ខៀវ ស៊ិន**

នាយកសាលាបឋមសិក្សាខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

**<u>យោបល់របស់គណៈកម្មការអំនាន និង តំរង់ទិស</u> :**

រឿងតំណាលស្ដីពីបញ្ហា «**អក្សរមូល ឬ អក្សរធំខ្មែរ**» ដែលលោក **ខៀវ ស៊ន** នាយកសាលាបឋមសិក្សាខ្ទុរដំបង បានលើកឡើង គឺជារឿងមួយគួរអោយចាប់អារម្មណ៍ គួរអោយសប្បាយរីករាយ និងចង់ស្ដាប់ ។

អំពីបញ្ហាអក្សរធំ ឬ អក្សរមូល ដែលលោក **ខៀវ ស៊ន** បានលើកឡើងនោះ គឺដូនតាខ្មែរយើងពុំមានក្បួនច្បាប់ ឬ បង្ខិតបង្ខំអោយសរសេរនៅដើមឃ្លា ឬនៅចំណងជើងទេ ។ ពោលគឺ គេអាចសរសេរអក្សរធំនៅចំណងជើង ឬគេសរសេរអក្សរធម្មតាដើមឃ្លា ដោយគេគ្រាន់តែគូសបន្ទាត់ពីក្រោម ក៏គេអាចចាត់ទុកថាជាចំណងជើងផងដែរ ។ ចំពោះអក្សររបស់ជនជាតិដទៃ ក៏មិនខុសពីអក្សររបស់ជនជាតិយើងប៉ុន្មានទេ គឺគេអាចសរសេរអក្សរធំ ឬ អក្សរតូច គ្រាន់តែនៅដើមឃ្លា គេតំរូវអោយសរសេរអក្សរធំតែមួយតួអក្សរដែលសរសេរមុនគេប៉ុណ្ណោះ ។

គណៈកម្មការអំនាន និង តំរង់ទិស

| | |
|---|---|
| *មួយសោតឪពុកផ្ដាំ* | *ចូរចាំកុំផឹកស្រា* |
| *វានាំចិត្តពាលា* | *ពាលោលទន់ពន់ពេកក្រៃ ។* |
| *ផឹកស្រាជាអ្នកកាច* | *ពុំក្រែងខ្លាចអ្នកដទៃ* |
| *វានាំបាត់ស្មារតី* | *នឹងរកស៊ីបាត់ប្រាជ្ញា ។* |
| *នៅនាលោកិយហោង* | *អស់អ្នកផងគេនិន្ទា* |
| *លុះខ្លួនជួនមរណា* | *ទៅនរករងទុក្ខនៅ ។* |

# ចំលើយ-សំនួរ ក្នុងទស្សនាវដ្តីលេខ ៧

**ទី ១** :

**ក/** - ព្រះបាទអង្គឌួងឡើងសោយរាជ្យពីឆ្នាំ ១៨៤០[១] ហើយសោយទីវង្គតនៅឆ្នាំ ១៨៥៩[១] នៅរាជធានីឧដុង្គ ។

- នៅពេលមុន កំពុង និងក្រោយសោយរាជ្យ ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពដែលយើងប្រដូចបានទៅអ្នកជំងឺកំពុងឈឺខ្លាំង ស្ទើរស្លាំង ដោយខ្សោះអស់ឈាមពីខ្លួន ។

( សូមអានប្រវត្តិវិទ្យាថ្នាក់ទី ៧ ទំព័រ ១៣៣ ផ្សាយចេញពីក្រសួង អ.យ.ក. )

- ព្រះអង្គឌួង ចាត់អោយកសាងផ្លូវពីឧដុង្គមានជ័យទៅខេត្តកំពត ដោយហេតុមកពីផ្លូវទឹកពីឧដុង្គទៅវៀតណាមខាងត្បូង មានឧបសគ្គច្រើន ។ ផ្លូវគមនាគមន៍នេះ កាត់ខេត្តកំពង់ស្ពឺត្រង់បាត់ដឹង ថ្នល់ទទឹង ស្រុកគងពិសី ។

- ព្រះអង្គបានកសាងផ្លូវគមនាគមន៍មួយខ្សែទៀត ភ្ជាប់ពីរាជធានីឧដុង្គទៅកំពង់ហ្លួង ។

- កែទំរង់ស្ថាប័នសង្គម វប្បធម៌ នយោបាយ អោយបានល្អប្រសើរឡើងវិញ ។

## ស្នាព្រះហស្តព្រះអង្គឌួង[២]

**ព្រះបាទហរិរក្សរាមាឥស្សរាធិបតីអង្គឌួង** ជាព្រះរាជាមួយអង្គដែលប្រកបដោយទសពិធរាជធម៌ ។ ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់រៀបចំអោយមានសន្តិភាពក្នុងប្រទេស និងអោយមានរបៀបរៀបរយក្នុងរាជការ ។ យ៉ាងណាមិញ ការបែកបាក់សាមគ្គីរវាងខ្មែរ និងចំបាំងឈ្លានពានរបស់បរទេស ជាហេតុនាំអោយប្រទេសពើបប្រទះនឹងមហន្តរាយ ភូមិស្រុកត្រូវវិនាសបំផ្លាញ ស្រែចំការត្រូវបោះបង់ចោល ផ្លូវថ្នល់ត្រូវបំផ្លិចបំផ្លាញដោយវិច្ឆេទកម្ម និងដោយទឹកជំនន់ ស្ពានភាគច្រើនត្រូវខូចខាត ។ អសន្តិសុខកើតពាសពេញផ្ទៃប្រទេស ព្រោះរាស្ត្រដែលអត់ឃ្លាន បានក្លាយទៅជាចោរលួចចោរប្លន់ កាប់សំលាប់ឥតត្រាប្រណីសកម្មភាពខាងជំនួញឥតមានទាល់តែសោះ ។

គឺនៅក្នុងស្ថានភាពដុនដាបបែបហ្នឹងហើយ ដែលព្រះ**អង្គឌួង** ទ្រង់បានឡើងគ្រងរាជ្យ ។ ព្រះអង្គទ្រង់បានខិតខំរៀបចំប្រទេសជាតិឡើងវិញ និងលើកតំកើងជីវភាពប្រជារាស្ត្រ ។ រាជធានី**ឧដុង្គ** ត្រូវបានស្ថាបនាឡើងវិញ ។ ចំនួនខេត្តក្នុងព្រះរាជាណាចក្រត្រូវបន្ថយ ។ ខេត្តនិមួយៗ មានទំហំផ្ទៃប្រហាក់ប្រហែលគ្នា ហើយត្រូវបែងចែកជាស្រុក ។ ពីគ.ស. ១៨៥១ ដល់ ១៨៥៧ ព្រះអង្គបញ្ជាអោយលើកផ្លូវមួយពី **ឧដុង្គ** ទៅ **កំពត** ដែលជាកំពង់ផែសមុទ្រតែមួយរបស់ខ្មែរ ព្រោះកំពង់ផែ **ព្រៃនគរ** ត្រូវបានទៅយួនជាស្ថាពរទៅហើយ ។ នៅគ.ស. ១៨៥២ ព្រះអង្គទ្រង់អោយលើកផ្លូវមួយទៀត ភ្ជាប់រាជធានី **ឧដុង្គ** ទៅ **កំពង់ហ្លួង** ជាកំពង់ផែសំខាន់ៗមួយទៀតរបស់ខ្មែរក្នុងសម័យនោះ ។

ក្នុងរជ្ជកាលរបស់ព្រះ**អង្គឌួង** ព្រះអង្គបញ្ជាកុំអោយមានការតម្លើងនិងការបង្កើតពន្ធថ្មី និងជៀសវាងកុំកែនរាស្ត្រអោយបំពេញកិច្ចការសាធារណៈក្នុងរដូវធ្វើស្រែចំការ ។ ព្រះអង្គមានព្រះទ័យអាណិតអាសូរចំពោះរាស្ត្រដែលរងទុក្ខវេទនា ។ ដូច្នេះហើយ បានជានៅពេលដែលកើតជំងឺរាតត្បាត ព្រះអង្គទ្រង់យាងដោយផ្ទាល់ទៅចែកស្បៀងអាហារ និងសំលៀកបំពាក់អោយរាស្ត្រក្រីក្រ ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ហាមមិនអោយបរបាញ់សត្វ និងមិនអោយចាប់ត្រីដោយប្រើព្រួលរាំងពេញព្រែកទេ ។ ព្រះអង្គស្តីបន្ទោស និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់លើពួកជនប្រមឹក ជនជក់អាភៀន និងជនប្រព្រឹត្តល្បែងស៊ីសង ទ្រង់បង្ក្រាបដោយតឹងរ៉ឹង

---

(១)- ដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ត្រឹង ងា ទំព័រ ១៥៤ ។ ក៏ប៉ុន្តែ សៀវភៅរបស់លោក Adhemard Leclere ថា ១៨៤១-១៨៥៩ សៀវភៅលោក A. Dauphin Meunier (១៨៤៥-១៨៥៩)

(២)- ដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ត្រឹង ងា ទំព័រ ១៥៩

នូវអំពើចងការប្រាក់ដោយយកការធ្ងន់ហួសប្រមាណ ហើយក្នុងការខ្ចីបុលគ្នា ទ្រង់តម្រូវអោយមានកិច្ចព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ រវាងមេបំណុល និងកូនបំណុល ។ ជាពិសេសទៅទៀត ព្រះអង្គទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ ដើម្បីលោះពួកមនុស្សខ្ញុំគេអោយបានរួចខ្លួនវិញអស់ជាច្រើន ។

ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រះអង្គទ្រង់បានបោះប្រាក់រាងមូល ម្ខាងមានរូបប្រាសាទ **អង្គរវត្ត** ម្ខាងទៀតមានរូបសត្វហង្ស សំរាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រ និង ទ្រង់បានទាក់ទាញឈ្មួញចិន និង ឥណ្ឌា អោយចូលធ្វើពាណិជ្ជកម្មក្នុងប្រទេសខ្មែរទៀតផង ។

ឯពន្ធដាត្រូវបានដាក់អោយទារតាមរបបភាស៊ី ជាហេតុអោយរាជការមានលទ្ធភាពរៀបចំថវិកាមួយ ដែលមានតុល្យភាព ។

ក្នុងវិស័យវប្បធម៌ ព្រះអង្គទ្រង់បានបង្កើតសាលាតាមវត្តជាច្រើន ទ្រង់បានលើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិត កវី ហើយទ្រង់បានផ្តល់នូវលុយកាក់ និងមធ្យោបាយផ្សេងៗដល់ជនណាដែលចង់ធ្វើការសិក្សា ស្វែងរកចំណេះវិជ្ជា ។ ព្រះអង្គទ្រង់សព្វព្រះទ័យធ្វើការពិភាក្សាជាមួយព្រះសង្ឃពីបញ្ហាសាសនា និងអក្សរសាស្ត្រ និងទ្រង់បានបរិច្ចាគព្រះរាជទ្រព្យផ្តល់ចំពោះព្រះសង្ឃសំរាប់កសាងវត្តអារាម និងចំណាយផ្សេងៗតាមព្រះពុទ្ធបញ្ញត្តិ ។

នៅទីបញ្ចប់នេះ គួរគប្បីបញ្ជាក់ដែរថា **ព្រះអង្គឌួង** ជាអ្នកនិពន្ធមួយរូបយ៉ាងឆ្នើមដែរ ។ ស្នាព្រះហស្តរបស់ព្រះអង្គក្នុងវិស័យអក្សរសិល្ប៍គឺ ៖

- **ចម្បាំងចោរចិន** ( គ.ស. ១៨១០ )
- **ព្រេងភាសិត** ( គ.ស. ១៨១៥ )
- **ច្បាប់ស្រី** ( គ.ស. ១៨៣៧ )

**១/-** - ព្រះបាទនរោត្តមឡើងសោយរាជ្យនៅឆ្នាំ ១៨៦០

- ព្រះអង្គយាងចេញពីក្រុងឧដុង្គមានជ័យ មកគង់នៅទីក្រុងភ្នំពេញ នៅឆ្នាំ ១៨៦៥
- ព្រះបរមរាជវាំង ចាប់ផ្តើមសាងសង់នៅឆ្នាំ ១៨៦៦ សង់រួចរាល់នៅឆ្នាំ ១៨៧០ ហើយសម្ពោធអោយប្រើប្រាស់ជាផ្លូវការនៅថ្ងៃ ១៤ ខែ កុម្ភៈ ឆ្នាំ ១៨៧០ ។

លោក **ចែម ផាន**

អនុប្រធានមន្ទីរអប់រំ យុវជន និង កីឡា (ខេត្តកំពង់ចាម)

**ទី ២** :

មុននឹងឆ្លើយសំនួរនេះ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ អានឡើងវិញនូវអត្ថបទរបស់ខ្ញុំ ស្តីអំពីសំភារៈឧបទេសសំរាប់បង្រៀនភូមិវិទ្យា ចុះក្នុងទស្សនាវដ្តីគ្រូបង្រៀនលេខ ២ ទំព័រ ២៥ ។ សំនួរទី ២ ក្នុងទស្សនាវដ្តីលេខ ៧ ទំព័រ ៤៩ ជាសំនួរសាកល្បងចំនេះដឹងរបស់លោកគ្រូ-អ្នកគ្រូនៅលើមាត្រដ្ឋាន ។ ក៏ប៉ុន្តែ គួរអោយអស់សង្ឃឹម ព្រោះសំនួរនេះ មិនមានចំលើយចេញពីគ្រូយើងណាម្នាក់នៅឡើយ ។

ខ្ញុំសូមឆ្លើយសំនួរនេះដូចតទៅ និងសូមពន្យល់បន្ថែម ដើម្បីលើកកំពស់ចំនេះដឹងទូទៅ ។ ផែនទី ទី ១ មានទំហំធំជាងផែនទី ទី ២ ពីព្រោះអ្វី ? ពីព្រោះផែនទីទាំងពីរនេះមានមាត្រដ្ឋានខុសគ្នា ៖

- ផែនទី ទី ១ មានមាត្រដ្ឋាន **1/500 000**
- ផែនទី ទី ២ មានមាត្រដ្ឋាន **1/2 000 000**

បានសេចក្តីថា នៅលើផែនទី ទី ១. **1**ស.ម.លើផែនទី ស្មើនឹង **500 000** ស.ម. រឺ **5**គ.ម លើផ្ទៃដី ។ ឧទាហរណ៍: យើងចង់ដឹងថា ពីភ្នំពេញទៅកំពង់ចាមមានចំងាយប៉ុន្មានគីឡូម៉ែត្រ ? យើងដឹងថា ផែនទីនេះមានមាត្រដ្ឋាន **1/500 000** ។

តើយើងធ្វើដូចម្ដេច ទើបដឹងចំងាយ ? **<u>ចំលើយ</u>** : ត្រូវយកឧបដេស៊ីម៉ែតវាស់ផែនទីពីចំនុចភ្នំពេញ ទៅចំនុចខេត្តកំពង់ចាម តើឃើញប៉ុន្មានសង់ទីម៉ែត ? ឧទាហរណ៍ ឃើញ 24 ស.ម. ។ យក 24 ស.ម គុណនឹង 500.000 ស.ម ។ យើងឃើញថា ចំងាយពី ភ្នំពេញ ទៅកំពង់ចាម ប្រវែង 12.000.000 ស.ម រឺ 120 គ.ម ។

- ផែនទី ១- 1ស.ម ត្រូវនឹង 500 000 ស.ម. រឺ 5 គ.ម លើផែនដី
- ផែនទី ២- 1ស.ម ត្រូវនឹង 2 000 000 ស.ម. រឺ 20 គ.ម លើផែនដី

មាត្រដ្ឋានដែលលោកគ្រូ-អ្នកគ្រូឃើញនៅលើផែនទីមានពីរប្រភេទ មាត្រដ្ឋានប្រភេទទី ១ ដែលខ្ញុំបានសរសេរនៅក្នុងទស្សនាវដ្ដីលេខ ២ និងលេខ ៩ នេះ ជាមាត្រដ្ឋានជាលេខ ( Echelle numérique )[១] ។ ប្រភាគមានជានិច្ចនៅលេខ ១ ជាភាគយក ។ ភាគបែង **Dénominateur** ខុសគ្នា ។ **ផែនទីបង្ហាញផែនដីតូច មានភាគបែងតូច** ចំនែកផែនទីទ្វីបធំៗ មាន **ភាគបែងធំ** ។

$$\frac{1}{100} \qquad \frac{1}{10\,000} \qquad \frac{1}{500\,000} \qquad \frac{1}{2\,000\,000}$$

មាត្រដ្ឋានប្រភេទទី ២ ដែលខ្ញុំមិនទាន់បានជំរាបនៅឡើយ ហៅថា មាត្រដ្ឋានគំនូសតាង ( Echelle graphique ) ដូចនេះ សូមពិនិត្យនៅលើគ្រប់ផែនទី ។ គេគូសអង្កត់ត្រង់ ហើយកំណត់ប្រវែងបង្ហាញដូចខាងក្រោម ៖

ឧទាហរណ៍ : 0 100 200គ.ម

0 5 000គ.ម

ផែនទីទ្វីបអាមេរិច តំនាងវិសាលភាពធំធេងណាស់ ។ ប្រភាគត្រូវមានភាគបែងធំ ។ មាត្រដ្ឋានគឺ : $\frac{1}{80\,000\,000}$

នៅលើផែនទី គេដឹកអង្កត់ត្រង់ប្រវែង 2,5 ស.ម. ដែលតាងអោយប្រវែងបណ្ដោយ 2 000គ.ម ។

0 2 000គ.ម

1 ស.ម ត្រូវនឹង 2 000 : 2,5 = 800 គ.ម = 800 000 ម រឺ 80 000 000 ស.ម ។

**<u>ចងចាំ</u>** :

* ផែនទីដែលមាត្រដ្ឋាន $\frac{1}{500\,000}$ ដូចផែនទីកម្ពុជាសព្វថ្ងៃ ត្រូវបកស្រាយថា 1ស.ម លើផែនទី ត្រូវនឹងប្រវែង 5 គ.ម លើផ្ទៃដី ដែលជាចំងាយពិត ។

* ផែនទីទ្វីបធំៗ ( អាមេរិច-អាស៊ី-អឺរ៉ុប....។ល។ ) គេប្រើភាគបែងធំ ។

(១)- សៀវភៅសិក្សាសង្គមថ្នាក់ទី ៧ (ភូមិវិទ្យា-ប្រវត្តិវិទ្យា) ទំព័រ ១០៨ មេរៀន ២-២ អាណាចក្រភ្នំ (គ.ស ៦៨-៥៥០) ។
សូមពិនិត្យប្រភាគដែលមានភាគយក ៤ តើខុសរឺត្រូវ ?

**<u>លំហាត់</u>** :

+ **<u>ទី ១</u>**: ប្លង់បន្ទប់រៀនមានមាត្រដ្ឋាន $\frac{1}{100}$ ។ ក្រោយពីបានវាស់ប្លង់ខាងក្រោម សូមលោកគ្រូ-អ្នកគ្រូរក :

- វិមាត្រពិត ( Dimensions réelles ) បន្ទប់រៀន គឺ បណ្តោយ និង ទទឹង

- វិមាត្រពិត ទ្វារ និង បង្អួច កញ្ចក់




+ **<u>ទី ២</u>** : ទីក្រុងប៉ារីស និង ទីក្រុងញូយ៉ក ចំងាយ 5 830 គ.ម. (ចំងាយជាក់ស្តែង)
ចូររកចំងាយលើផែនទីដែលមានមាត្រដ្ឋាន 1/45 000 000

| | | |
|---|---|---|
| *យើងបានរស់* | *ព្រោះម៉ែឪ* | *លោកថែទាំ* |
| *នៀយហត់ទ្រាំ* | *ខំចិញ្ចឹម* | *មកជាយូរ* |
| *យើងបានរេះ* | *ចំណេះមក* | *ពីលោកគ្រូ* |
| *គួរតាំងខ្លួន* | *កតញ្ញូ* | *ចំពោះលោក ។* |

## ចំលើយសំនួរ ចុះក្នុងទស្សនាវដ្តីលេខ ៨ ទំព័រ ៤៩

**ចំលើយសំនួរទី ១** : លោកគ្រូ-អ្នកគ្រូធ្លាប់បានលឺ បានឃើញសំនៅនៃពាក្យ*សីលធម៌* និង *គុណធម៌* ។ ប៉ុន្តែ ន័យនៃពាក្យទាំងពីរម៉ាត់នេះ តាមការប៉ាន់ស្មានក្នុងចិត្តរបស់ខ្ញុំ ខ្ញុំអាចសន្និដ្ឋានថា លោកគ្រូ-អ្នកគ្រូភាគច្រើន យល់មិនទាន់បាន ស៊ីជំរៅនៅឡើយទេ ។ សូមអានល្បះនេះដោយផ្ចិតអារម្មណ៍ទៅលើពាក្យទាំងពីរ «ភាពស្រុតចុះដ៍ខ្លាំងក្លានៃសីលធម៌ និង គុណធម៌ ខាងផ្លូវចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ ដែលកើតមានតាំងពីសម័យសង្គ្រាមជាងពីរទសវត្សរ៍រហូតមកដល់ពេលនេះ ពុំទាន់ត្រូវបានស្តារ និង លើកកំពស់អោយបានជាទូទៅ និងជាប់ជាប្រចាំនៅឡើយ» ។

ជាដំបូង សូមលោកគ្រូ-អ្នកគ្រូ អោយនិយមន័យនៃពាក្យសីលធម៌ជាមួយខ្ញុំ ។ តាមវចនានុក្រមខ្មែរ **សីល** មានន័យច្រើនសំរាប់ភ្ជាប់ពីខាងដើមនៃសព្ទដទៃ ។ *សីលធម្ម* ឬ *សីលធម៌* សីលដែលជាធម៌ (របស់សត្វលោក) ឬ សីល និង ធម៌ កិរិយាមារយាទ, សណ្តាប់ធ្នាប់, ដំបូន្មានដែលនាំអោយចៀសវាងអំពើអាក្រក់ ហើយអោយប្រព្រឹត្តតែអំពើល្អ [១] ។

ដូចនេះ តាមនិយមន័យនៃសីលធម៌ខាងលើនេះ ល្បះដែលនិយាយថា ភាពស្រុតចុះនៃសីលធម៌ មិនទាន់បានស្តារឡើងវិញ តើបានសេចក្តីបកស្រាយថាដូចម្តេច ? ខ្ញុំមិនបកស្រាយទេ សូមលោកគ្រូ-អ្នកគ្រូ រកចំលើយខ្លួនឯង ។ ម្យ៉ាងទៀត ខ្ញុំមិនបន្តរាប់រៀបពីសីលខាងសាសនាទេ ។ ខ្ញុំគ្រាន់តែសួរថា សីលមួយម៉ាត់នេះ ប្រើក្នុងពុទ្ធសាសនា បានសេចក្តីថាដូចម្តេច ? ដូចជាពាក្យថា *រក្សាសីល ៥ ចាំសីល ៨* ជាដើម ។

ឥឡូវនេះ ខ្ញុំសូមបកស្រាយពីគុណធម៌ ។ យើងយកពាក្យ **គុណ** មួយម៉ាត់មកសិក្សាសិន ។ គុណមានន័យច្រើនណាស់ សំរាប់ភ្ជាប់ពីខាងដើមសព្ទដទៃ ។ ន័យដើម របស់ពាក្យគុណ គឺសេចក្តីចំរើនកើនឡើង ។

**គុណធម៌** : ( គុណ + ធម៌ ) ធម៌ដែលមានដំណើរចំរើនសេចក្តីសុខទុក្ខតាមជាន់តាមថ្នាក់ បានខាងអំពើល្អ អាក្រក់ គឺបុណ្យ បាប ដែលបុគ្គលធ្វើ ។ សេចក្តីល្អ, សេចក្តីបរិសុទ្ធ, សេចក្តីអាណិត ប្រណី[២] ។ តាមន័យនេះ លោកគ្រូ-អ្នកគ្រូយល់បានឬទេ ? តាមខ្ញុំប៉ាន់ស្មានថា អស់លោកនៅតែមិនទាន់ច្បាស់ គឺមិនទាន់កំនត់ថា គុណធម៌នោះយ៉ាងដូចម្តេច ? ចំរើនឡើងដូចលេខគុណ ឬចំរើនឡើងបែបណា ?

ភិក្ខុធម្មបាល **ខៀវ ជុំ** បានដាក់ពាក្យគុណធម៌ ស្មើនឹងពាក្យវឌ្ឍនធម៌ ដែលគេនិយមហៅថា *សម្បត្តិមនុស្សល្អ* ។ *វឌ្ឍនធម៌, វឌ្ឍនភាព* ផ្ទុយនឹង *ភាពអាប់ឱន ធុនដាប* ។ ខ្ញុំយកពាក្យបារាំងមកជាជំនួយបន្ថែមទៀត គឺពាក្យ Progrès ដែលមានន័យថា ដំណើរឈានឡើងជាលំដាប់ទៅរកអំពើជាកុសល ឬទៅរកភាពកាន់តែប្រសើរឡើងទៀត ។ តើធម៌អ្វីខ្លះ ដែលមានឈ្មោះថាជា **គុណធម៌** ? សូមសញ្ជឹងគិតមើល ។ ឃើញហើយ ឮហើយ ប៉ុន្តែ មិនដឹងថា អ្វីអោយបានជាក់ច្បាស់ ។ ខ្ញុំទុកអោយលោកគ្រូ-អ្នកគ្រូគិតសិន ។

លោកគ្រូ-អ្នកគ្រូបានយល់ន័យនៃពាក្យគុណធម៌ តាមការបកស្រាយចេញពីភាសាបាលី ។ ឥឡូវនេះ ដើម្បីអោយលោកគ្រូ-អ្នកគ្រូយល់រឹតតែបានស៊ីជំរៅ នូវពាក្យគុណធម៌ ដែលបកចេញពីពាក្យបារាំង «la vertu» ។ La vertu មានន័យចំបងពីរ គឺ ១: *គុណភាព* ឬ *ប្រសិទ្ធភាព* ។ ឧ: ថ្នាំនេះមានគុណភាពល្អណាស់ ។ រុក្ខជាតិនេះ ពូកែស័ក្តិសិទ្ធិណាស់ ក្នុងការព្យាបាលជំងឺ ។ ២ : ចរិតខ្ជាប់ខ្ជួនមិនប្រែប្រួលរបស់មនុស្សដែលចង់តែប្រព្រឹត្តអំពើល្អ ចៀសវាងអំពើអាក្រក់ ។ តាមវចនមូល (étymologie ) ពាក្យ «vertu» ប្រែថា គុណសម្បត្តិរបស់មនុស្សប្រុស ដែលបង្ហាញនូវកំលាំងកំហែងមាំមួន ក្លាហាន (បុរិសភាព) ។ តាមន័យនេះ យើងគួរយល់ថា «vertu» ជាកំលាំងចិត្ត កំលាំងឆន្ទៈរបស់មនុស្ស ក្នុងការបំពេញ ឬការប្រតិបត្តិអំពើជាកុសល ។ ដូចនេះ គុណធម៌ ជាគុណសម្បត្តិរបស់មនុស្ស ដែលទាក់ទងនិងកំលាំងចិត្ត និង ឆន្ទៈដែលត្រូវតែ

(១)- សូមអានវចនានុក្រមខ្មែរ ទំព័រ ១៣៩១

(២)- វចនានុក្រមខ្មែរ ទំព័រ ១៦០

ហាត់ពត់លត់ដំ ដើម្បីសំរេចគុណធម៌ ។ ឧទាហរណ៍ : **ខន្តី** ប្រែថា ការអត់ធន់ ជាគុណធម៌មួយក្នុងចំនោមគុណធម៌ដ៏ច្រើនទៀត ។ ប៉ុន្តែ ធ្វើម្តេចអោយគុណធម៌នេះមកស្ថិតនៅក្នុងខ្លួនយើងបាន ឬធ្វើម្តេចអោយយើងមានគុណធម៌នេះ ? កន្លែងត្រង់នេះហើយ ដែលយើងចាត់ទុកជាគន្លឹះ ។ ឧទាហរណ៍ : គ្រូបង្រៀនពីរនាក់មានចរិតខុសគ្នាត្រង់គុណធម៌ ខន្តី ។ គ្រូទី ១ មានចិត្តឆាប់ក្រេវក្រោធ ។ ថ្ងៃមួយ សិស្សម្នាក់បានហែកកិច្ចការដែលបានពិន្ទុអាក្រក់នៅក្រោយកំនែ នៅចំពោះមុខគាត់ ។ ខឹងឆេវ គ្រូនេះស្ទុះទៅវាយសិស្សអស់មួយទំហឹងដៃ ។

**សូមពិចារណា ?** ក- លោកគ្រូនេះ ទប់កំហឹងមិនបាន ដែលជាគុណវិបត្តិមួយធ្ងន់ណាស់ ចំពោះគ្រូបង្រៀន

ខ- លោកគ្រូនេះ ខ្វះធម៌ ខន្តី ដែលជាគុណធម៌ដ៏ប្រសើរក្នុងដំណើរជីវិត

គ្រូម្នាក់ទៀត មានចរិយាត្រឹមត្រូវ ស្លូតបូត តែមិនបណ្តោយអោយសិស្សធ្វើអ្វីបានតាមអំពើចិត្តវាទេ ។ ថ្ងៃមួយ សិស្សម្នាក់បានប្រព្រឹត្តទង្វើមួយដ៏ឃោរឃៅចំពោះមុខគាត់ គឺវាយមិត្តរួមថ្នាក់ម្នាក់ ។ គាត់ទៅចាប់ឃាត់វា វាស្រែកគំហកដាក់គ្រូនេះយ៉ាងគឃ្លើន ។ គាត់មិនបានវាយតបវាទេ គឺគ្រាន់តែបំបែកប្រដាល់ប្រតប់គ្នាប៉ុននោះ ។ លោកគ្រូនេះទប់កំហឹងបាន ។ គាត់មិនតបតវិញ ។ គាត់មានធម៌ ខន្តី គឺអត់ធ្មត់ ។ បីថ្ងៃក្រោយមក គាត់បានហៅសិស្សនេះមកប្រដែប្រដៅដោយសន្តិវិធីនៅចំពោះមុខលោកនាយកសាលា ។

រួមសេចក្តីមកវិញ **សីលធម៌** ជាកន្សោមនៃបទដ្ឋានដែលមនុស្សត្រូវប្រតិបត្តិតាម ឬការប្រព្រឹត្តកាយ វាចា អោយមានរបៀបរៀបរយ ។ **សុភាវធម៌** (សុ + ភាវៈ ភាវៈល្អ ដែលមានភាពល្អ) ទន់ភ្លន់ រាបទាប រៀបរយ ដែលមានឫកពារៀបរយ, ចុះបែបបទ ស្លូតបូត ចិត្តសុភាព សំដីសុភាព មនុស្សសុភាព[១] ។ រីឯ *សុជីវធម៌* គឺការចេះគួរសមក្នុងកិច្ចការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ។ ដូចនេះ យើងឃើញថា *សុភាវធម៌* និង *សុជីវធម៌* ជាកន្សោមសីលធម៌ ដែលយើងត្រូវប្រព្រឹត្តតាមជាប្រចាំដើម្បីអោយបានជាមនុស្សល្អ ក្នុងសហគមន៍មនុស្ស ។ ឧ: ការសំពះ, ការគោរពចាស់ទុំ ។ល។ រីឯគុណធម៌ ជាធម៌ដែលយើងត្រូវហាត់ពត់លត់ចិត្ត ដើម្បីអោយគុណធម៌មកស្ថិតជាប់នៅក្នុងខ្លួនយើង ។ ឧ: មនុស្សឆាប់ក្រោធ ។ ដើម្បីអោយមនុស្សនេះមានគុណធម៌ « *មិនក្រោធ* » វិញ តើមនុស្សនេះត្រូវតាំងចិត្តដូចម្តេច ? គឺតាំងចិត្តឈប់ខឹង ឈប់តប ។ វិធីមានច្រើន ដើម្បីហាត់ចិត្តកុំអោយឆាប់ក្រេវក្រោធ ។ ចាស់ៗប្រដៅថា បើប្តីប្រពន្ធឈ្លោះគ្នា ប្រកែកគ្នា ប្តី ឬ ប្រពន្ធ ត្រូវតែដើរចេញពីមុខមួយស្របក់សិន កុំនៅតែប្រកែក ជជែកយកឈ្នះចាញ់ រហូតដល់ទប់កំហឹងមិនបាន នាំអោយកើតការវាយតប់ ឬរហូតដល់ហ៊ានសំលាប់គ្នាថែមទៀតផងក៏មាន ។

ជាទីបញ្ចប់ ក្នុងឋានៈជារៀមច្បង សូមប្អូនៗទាំងបុរស និង ស្ត្រី ដែលស្ម័គ្រចិត្តមកប្រកបការងារជាអ្នកបង្ហាត់បង្រៀន និង អប់រំយុវជនជំនាន់ក្រោយ សូមប្រកាន់អោយបានខ្ជាប់ខ្ជួននូវចរិយាសម្បត្តិថ្លៃថ្នូរ សីលធម៌ខ្ពង់ខ្ពស់ គំនិតជាតិ ដើម្បីជាគំរូចំពោះយុវវ័យ ។

ដើម្បីសេចក្តីល្អថ្លៃថ្នូររបស់សង្គម ឬ វឌ្ឍនភាពនៃជីវិតរបស់មនុស្ស គ្រូម្នាក់ៗ ក្រៅពីបង្រៀនមុខវិជ្ជាដែលត្រូវបង្រៀនប្រចាំថ្ងៃ ត្រូវបង្ខំ ឬត្រូវអប់រំខ្លួនឯងអោយរស់នៅក្នុងសីលធម៌ និង គុណធម៌ជាមុន ទើបងាយស្រួលដល់ការបង្រៀនសិស្ស ។

**យ៉េង ឌី**

**<u>សំនួរបន្ថែម</u>** : សូមពន្យល់ និង អធិប្បាយឃ្លាខាងក្រោមនេះ ៖

លោក អេមីល ឌៀរខេម មានប្រសាសន៍ថា « ឥទ្ធិពលសីលធម៌ ជាគុណសម្បត្តិដ៏ប្រពៃនៃអ្នកអប់រំ »

(L'autorité morale est la qualité maîtresse de l'éducateur) E. Durkheim [២]

* * *

**គណៈកម្មាធិការនាយកនៃ ស.ប.ស.ខ នឹងជូនរង្វាន់ចំពោះកិច្ចការល្អត្រឹមត្រូវ ។**

---

(១)- វចនានុក្រមខ្មែរ ទំព័រ ១៤០៩

(២)- E. Durkheim ជាសង្គមវិទូបារាំង (១៨៥៨ - ១៩១៧)

## <u>ចំលើយសំនួរទី ២</u> : - ពន្យល់ពាក្យ អត្តសញ្ញាណវប្បធម៌ និង បេតិកភណ្ឌវប្បធម៌

**១- <u>អត្តសញ្ញាណវប្បធម៌</u> : ( Identité culturelle )**

មុននឹងផ្ដល់ចំលើយ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូ អានអត្ថបទក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ១ ចាប់ពីទំព័រ ២៣ រហូតដល់ ២៨ ។

បញ្ញត្តិអត្តសញ្ញាណជាតិ ត្រូវបានពន្យល់រួចហើយ ។ ក៏ប៉ុន្តែ សំនួរអត្តសញ្ញាណវប្បធម៌ រកចំលើយមិនឃើញ មិនហ៊ានសរសេរឆ្លើយតបមកគណៈកម្មាធិការនាយក ស.ប.ស.ខ ។

ខ្ញុំសូមជំរាបថា មនុស្ស សត្វ តែងតែមានលក្ខណៈសំគាល់ប្លែកៗគ្នា ខុសពីមនុស្សម្នាក់ទៅមនុស្សម្នាក់ រឺ ពីសត្វមួយទៅសត្វមួយ ។ ឧ : សត្វក្របីមួយហ្វូង បើមើលមួយភ្លែតឃើញដូចគ្នាទាំងអស់ ។ ប៉ុន្តែ ម្ចាស់ក្របីសំគាល់សញ្ញាណត្រង់នេះ ត្រង់នោះ ដែលគេបានចំនាំបាន ។ រីឯមនុស្សវិញ ក៏មានលក្ខណៈសំគាល់ខុសៗគ្នាទាំងអស់ដែរ ។ ចំណែកឯប្រទេសជាតិ រឺ ប្រជាជាតិ ក៏មានលក្ខណៈសំគាល់ពិសេសរបស់វាដែរ ។ សញ្ញាណអ្វីខ្លះដែលជាគ្រឿងសំគាល់នៃប្រទេសនីមួយៗ ។ ឧ : ប្រទេសកម្ពុជា, អត្តសញ្ញាណប្រទេសនេះ មានអ្វីខ្លះជាគ្រឿងសំគាល់ថា ជាកម្ពុជរដ្ឋ រឺ ស្រុកខ្មែរ ។ និយាយមួយបែបទៀតថា គេស្គាល់ប្រទេសកម្ពុជាដោយសារអ្វី ? អ្វីជាសញ្ញាណ រឺ លក្ខណៈសំគាល់ ? **<u>ចំលើយ</u>** : អត្តសញ្ញាណប្រទេសមួយ រឺ ជាតិមួយ មានជាអាទិ គឺដែនដី, រឺ ទឹកដី, ប្រវត្តិ រឺ អតីតកាល និង វប្បធម៌ ។ ចុះវប្បធម៌មានគ្រឿងសំគាល់អ្វីខ្លះ ? រឺអ្វីជាអត្តសញ្ញាណនៃវប្បធម៌ ។ **<u>ចំលើយ</u>** : ចំនុចនេះ ដែលត្រូវចេះ ត្រូវដឹង ពីព្រោះ មិនសូវមានអ្នកយល់ ក៏ប៉ុន្តែ មានអ្នកចេះតែថាតាមគេ ។ ម្យ៉ាងទៀត វប្បធម៌ជាព្រលឹង រីឯរឹតតែឥតយល់ច្បាស់ទៅទៀត ។ ខ្ញុំសូមជំរាបថា បញ្ញត្តិវប្បធម៌មានន័យច្រើនណាស់ ។ លោកព្រឹទ្ធាចារ្យ **ឆេង ផុន** មានប្រសាសន៍ថា វប្បធម៌មានន័យជាង ២០០ ឯណោះ ។ ខ្លួនខ្ញុំផ្ទាល់ ក៏មិនបានស្គាល់ន័យទាំងអស់នោះដែរ ។ ខ្ញុំចេះបានតែពីរន័យគត់ ។

ឥឡូវនេះ យើងនាំគ្នាដោះស្រាយអំពីអត្តសញ្ញាណនៃវប្បធម៌ ។ យើងគួរចែកអត្តសញ្ញាណវប្បធម៌ជាពីរផ្នែក :

- គឺ ១ : គ្រឿងសំគាល់
- ២ : ការជឿជាក់

ក្នុងផ្នែកទី ១ នេះ យើងលើកយកវត្ថុ រឺ ការសំដែងសិល្បៈដែលយើងធ្លាប់ស្គាល់ ធ្លាប់ទស្សនាមកបង្ហាញ ដូចជា ទ្រ, គង, រនាត, ចំលាក់, គំនូរ, ល្ខោន, តន្ត្រី, ប្រាសាទ, អក្សរ, ភាសា, ទំនៀមទំលាប់ ។ល។

ក្នុងផ្នែកទី ២ យើងជឿជាក់ថាជាខ្មែរ ដោយឧបករណ៍នោះ វាបញ្ចេញ រឺ សំដែងអោយដឹងថាជាខ្មែរ ។ ឧ : សំពត់ហូល, ផាមួង, ផាដើម ។ ម្យ៉ាងទៀត បើគេកូតទ្រ រឺ ផ្លុំខ្លុយ នៅពេលយប់អាធ្រាត្រនៅក្នុងទីស្ថានមួយឆ្ងាយ បើលឺសំលេងយើងអាចដឹងថា បទនេះជាបទខ្មែរ ។ ចំលាក់នៅគ្រប់ប្រាសាទខ្មែរ ជាពិសេស ចំលាក់នៅប្រាសាទបន្ទាយស្រី ទាក់ទាញចិត្តគំនិតខ្មែរ និង ទេសចរបរទេស អោយស្គាល់ខ្មែរ និងភាពរុងរឿងនៃវប្បធម៌ខ្មែរ ។

សរុបសេចក្ដីមកវិញ អត្តសញ្ញាណនៃវប្បធម៌ គឺ ១ : ឧបករណ៍តន្ត្រី ក្បូរក្បាច់រចនា ។ល។ ដែលឃើញដោយផ្ទាល់ភ្នែក ។ ២ : អាកប្បកិរិយា ដែលសំដែងចេញអោយឃើញចិត្តគំនិត និង ទំនៀមទំលាប់ ដែលជាឥទ្ធិពលនៃវប្បធម៌របស់ប្រទេសនីមួយៗ ។

**២- <u>បេតិកភណ្ឌវប្បធម៌</u>** : ( Patrimoine culturel )

**<u>និយមន័យ</u>** : (បេតិក + ភណ្ឌ) ទ្រព្យសម្បត្តិ រឺកេរមរតក ដែលជាប់តមកពីខាងឪពុក ។ ឧ: ស្រែទាំងអស់នេះ ជាបេតិកភណ្ឌរបស់ខ្ញុំ[១] ។ តាមអត្ថបដិរូបវិញ បេតិកភណ្ឌ ប្រែថា កេរដំណែលរួមរបស់សហគមន៍ជាតិ រឺ របស់មនុស្សជាតិទាំងមូល ដែល

(១)- វចនានុក្រមខ្មែរ ទំព័រ ៦៥៧

ជាកេរមរតកទុកអោយដោយបុព្វបុរស ។ ឧ : ស្នាដៃអក្សរសាស្ត្រ ជាបេតិកភណ្ឌមនុស្សជាតិ ។ ប្រាសាទអង្គរ ចាត់ទុកជាបេតិកភណ្ឌជាតិ ។ ចុះបេតិកភណ្ឌវប្បធម៌ ប្រែថាដូចម្តេច ? មុននឹងឆ្លើយសំនួរនេះ ខ្ញុំសូមសំរួលអត្ថន័យនៃពាក្យវប្បធម៌ ទៅតាមទស្សនវិស័យនៃការអនុវត្តអប់រំ ( Perspective de la pratique éducative) ជាមុនសិន ។ ដូចនេះ វប្បធម៌អាចកំនត់ន័យថា ជាចង្កោម (ensemble) សិល្បៈ ជំនឿ របៀបបញ្ចេញអាកប្បកិរិយា និងកាយវិការ និង ស្ថាប័នសង្គម[1] ដែលចង្អុលចរិកលក្ខណៈនៃសហគមន៍ជាតិមួយ រឺ មនុស្សមួយក្រុម ។

បេតិកភណ្ឌវប្បធម៌ ចាត់ទុកជាកេរមរតកផ្នែកគំនិត (patrimoine spirituel) ។ ឧ: ប្រាសាទអង្គរវត្ត ទាក់ទាញអារម្មណ៍អ្នកបានទស្សនាការប្រាសាទនេះយ៉ាងដូចម្តេច ទៅលើស្នាដៃស្ថាបត្យកម្ម គំនូរ ចំលាក់ ជាដើម ។

តើចំលើយប៉ុននេះ ល្មមយល់បានដែរទេ ? សូមលោក-អ្នកអាន មេត្តាសរសេរមកសួរ ប្រសិនបើមានចំងល់ ។

យ៉ន់ ធី



« វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន »

(១)- ស្ថាប័នសង្គមជាទំរង់ និង ការចាត់តាំងសង្គម

# តើការបង្រៀន និង រៀន គឺជាអ្វី ?

* * * * *

មនុស្សយើងក្នុងសង្គមណាក៏ដូចជាសង្គមណាដែរ សុទ្ធតែបានទទួលការបង្រៀន និង រៀន ។ តាមរយៈនេះ បញ្ហាសំខាន់បំផុតនោះគឺ ការឆ្លងកាត់សាលារៀន ដែលជាកន្លែងដ៏សំខាន់បំផុត សំរាប់អោយមនុស្សទាំងអស់នោះទទួលនូវសកម្មភាពពីរ គឺសកម្មភាពបង្រៀនរបស់គ្រូ និងសកម្មភាពរៀនរបស់សិស្ស ហើយសកម្មភាពទាំងពីរនេះ ត្រូវតែមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកយ៉ាងល្អប្រសើរបំផុត ដែលមិនអាចខ្វះបានឡើយ ។

កាលណាយើងគិតដល់សកម្មភាពបង្រៀន និង រៀន គឺយើងគិតដល់លំនាំនៃការបង្រៀនរបស់គ្រូ និងលំនាំនៃការរៀនរបស់សិស្ស ។ ក្នុងលំនាំនៃសកម្មភាពទាំងពីរនេះ ដែលមានគ្រូ និង សិស្សជាអ្នកទទួលបន្ទុកដាច់ដោយឡែកពីគ្នា ប៉ុន្តែ ផ្សារភ្ជាប់គ្នាយ៉ាងស្អិតល្មួត ក្នុងនោះ ភាគីគ្រូ ត្រូវតែស្គាល់ និង យល់អំពីភារកិច្ច និង តួនាទីរបស់ខ្លួនអោយបានត្រឹមត្រូវ និងអនុវត្តដោយហ្មត់ចត់ ។ ចំនែកឯសិស្សវិញ ក៏ត្រូវតែស្គាល់ចំណុចសំខាន់ៗ ដែលទាក់ទងដល់តួនាទី និង ភារកិច្ចរបស់ខ្លួនដូចគ្រូដែរ តាមរយៈអប់រំទូន្មានរបស់គ្រូ និង ការស្វែងយល់ដោយផ្ទាល់ ។

កត្តាបង្រៀន គឺជាការផ្តល់ចំនេះដឹងទាំងឡាយអោយដល់សិស្ស ដោយមានលក្ខណៈជាប្រព័ន្ធទៅតាមកំរិត និងវ័យរបស់សិស្ស ។ ការងារនេះ គ្រូត្រូវតែមានចំនេះដឹងទូលំទូលាយ ជាពិសេស ចំនេះដឹងទៅលើមុខជំនាញឯកទេស នៃមុខវិជ្ជានីមួយៗ ដែលគ្រូទទួលបន្ទុកដើម្បីបង្រៀន ។ ការយល់ដឹងរបស់គ្រូលើមុខវិជ្ជា ដែលគ្រូទទួលខុសត្រូវនេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ គ្រូត្រូវតែមានចំនេះដឹងអំពីសង្គមអោយបានទូលំទូលាយថែមទៀត ដោយធ្វើការសិក្សាស្រាវជ្រាវជាប្រចាំ ដែលជាកាតព្វកិច្ចបន្ថែមទៀតរបស់គ្រូ ។

ម្យ៉ាងវិញទៀត ដើម្បីអោយការបង្រៀនទទួលបានជោគជ័យ បន្ទាប់ពីគ្រូបង្រៀនមានចំនេះដឹងទៅលើផ្នែកចិត្តសាស្ត្រ និងគរុកោសល្យ គ្រូត្រូវមានល្បិចបង្រៀន ដើម្បីធ្វើអោយសិស្សមានចំណង់ចំណូលចិត្តជាមួយគ្រូ នៅក្នុងលំនាំនៃការបង្រៀន ក្នុងនោះ បើយើងនិយាយអោយងាយយល់ទៅ គឺយើងសង្ខេបនូវ ៤ ចំនុច ដែលសុទ្ធសឹងចាប់ផ្តើមឡើងដោយអក្សរ «ច» បើនិយាយអោយកាន់តែងាយយល់ទៅទៀត គឺការប្រើរូបមន្ត «ច» ៤ ។

រូបមន្ត «ច» ៤ នេះ សង្ខេបយ៉ាងខ្លីមានអត្ថន័យដូចតទៅ ៖

«ច» ទី ១ : «ចង់» គឺជាការរៀបចំផ្លូវចិត្ត ដែលជាទេពកោសល្យរបស់គ្រូក្នុងការប្រើចិត្តសាស្ត្រ អោយសិស្សមូលអារម្មណ៍មកលើការសិក្សារបស់គេ ដោយគ្មានការបង្ខិតបង្ខំ ។

«ច» ទី ២ : «ចូល» មានន័យថា ក្រោយពីសិស្សចង់ដោយចិត្តរបស់គេផ្ទាល់ គេនឹងចូលរួមយ៉ាងសកម្ម ក្នុងការស្តាប់គ្រូដោយយកចិត្តទុកដាក់ ។

«ច» ទី ៣ : «ចាំ» បន្ទាប់ពីការចង់ចូលរួមដោយផ្ទាល់ខ្លួនរបស់សិស្ស ក្នុងការមើល, ស្តាប់, គិត, ពិចារណា និង សួរគ្រូ ទៅលើចំនុចសំខាន់ៗដែលគេមិនសូវយល់ រួចហើយការងារនេះធ្វើអោយគេចាំបានល្អ ។

«ច» ទី ៤ : «ចេះ» នៅពេលដែលគេចាំទៅលើចំនុចសំខាន់ៗនៃមេរៀន បន្ទាប់ពីបានពិចារណាដោយល្អិតល្អន់និងយល់ច្បាស់ទៅលើចំនុចទាំងនោះ ដែលធ្វើអោយគេទទួលបានលទ្ធផលល្អ ដ៏ល្អបំផុតមួយនោះគឺ ជាការចេះ ។

**ចង់ + ចូល + ចាំ → ចេះ**

ដូចនេះ គ្រូបង្រៀនមានតួនាទីសំខាន់ណាស់ នៅក្នុងសកម្មភាពខាងលើ ដោយគ្រូបង្រៀនជាអ្នកទទួលខុសត្រូវទាំងស្រុង ទាំងនៅក្នុងថ្នាក់រៀន ជាពិសេស ក្នុងម៉ោងបង្រៀន ។ ម្យ៉ាងទៀត ការទទួលខុសត្រូវនៅក្នុងសង្គម ក៏ជាផ្នែកមួយយ៉ាងសំខាន់របស់គ្រូបង្រៀនដែរ ពីព្រោះមជ្ឈដ្ឋានសង្គមមានឥទ្ធិពលខ្លាំងណាស់ ទៅលើសកម្មភាពនៃការសិក្សារបស់សិស្ស ដើម្បីរួមចំណែកជំរុញអោយសិស្សយល់ឃើញថា ការសិក្សាគឺជាការងារសួលយ៉ាងសំខាន់សំរាប់គេផ្ទាល់ ។ ការងារទាំងអស់ខាងលើនេះគឺជាកិត្តិយសដ៏ឧត្តុង្គឧត្តម ពីព្រោះ ការងារនេះ នឹងធ្វើអោយមនុស្សជាតិរបស់យើងស្គាល់ ចេះ ដឹង និងពិចារណាអ្វីដែលល្អមានប្រយោជន៍ដល់ខ្លួនគេផ្ទាល់ និងដល់សង្គមជាតិទាំងមូល ដែលជាចំនុចសំខាន់បំផុតសំរាប់ការអភិវឌ្ឍន៍របស់ប្រទេសជាតិយើងទាំងអស់គ្នា ។

សាស្ត្រាចារ្យ **កខ ខ្មិម**

-----------------------------------------

## <u>**មតិបន្ថែម**</u>

ខ្ញុំសូមចាត់ទុកអត្ថបទរបស់លោក **កខ ខ្មិម** ស្ដីពីការបង្រៀន-រៀនខាងលើនេះ ជាចំលើយ-សំនួរក្នុងទស្សនាវដ្ដីលេខ ៨ ទំព័រ ៤៩ ។ អត្ថបទនេះ ជាមតិផ្ទាល់របស់លោក និងមានអត្ថន័យដ៏ជ្រាលជ្រៅ គួរទុកជាគោលគំនិតដ៏ល្អសំរាប់លោកគ្រូ-អ្នកគ្រូ ។

ខ្ញុំសូមបន្ថែមមតិខ្ញុំខ្លះចំពោះពាក្យនេះ ។ ពាក្យបង្រៀន-រៀនជាពាក្យថ្មី ជាពាក្យបកមកពីពាក្យបារាំង «apprendre» ពីព្រោះកិរិយាសព្ទ apprendre មានន័យពីរ គឺ បង្រៀនផង (សកម្មកិរិយា) និងរៀនខ្លួនឯងផង (អកម្មកិរិយា) ។ ហេតុនេះ អ្នកបកប្រែភាសា ប្រើពាក្យបង្រៀន-រៀនតែម្ដង ។ នេះជាមតិខ្ញុំផ្ទាល់ ។

ខ្ញុំសូមផ្ដិតជាប់មកនេះ នូវនិយមន័យរបស់ពាក្យ «apprendre» ៖

> Apprendre, c'est d'abord *élever* et s'élever puisque, en français, apprendre a toujours le sens passif (s'instruire) et actif (instruire).
>
> Apprendre, c'est ensuite *enseigner* : il s'agit d'une éducation, intentionnelle, méthodique, programmée.
>
> Apprendre, c'est aussi *former*. Ce verbe correspond avant tout à l'apprentissage d'un métier.
>
> Apprendre, c'est enfin échanger, imiter, s'initier, apprendre à être.
>
> Tels sont les enjeux de cette réflexion sur les valeurs de l'éducation conçue comme apprentissage de l'humanité.
>
> <u>Olivier Reboul</u>

**យ៉េន ធី**




**បទកាកគតិ**

# វប្បធម៌ទូទៅ និង សីលធម៌វិជ្ជាជីវៈ

វប្បធម៌ទូទៅ
សីលធម៌គោលដៅ
វិជ្ជាជីវៈ
ល្អិតល្អផូរផង់
ខំផ្ចង់ឥតអាក់
យើងឥតស្ទើរស្ទាក់
រៀនសូត្រជាក់ស្តែង ។

វិជ្ជាទាំងពីរ
គ្រូយើងមូលមីរ
ត្រូវប្រឹងស្វះស្វែង
ដកស្រង់ពិសោធន៍
កុំកោតខ្លាចក្រែង
ឧស្សាហ៍ខ្នះខ្នែង
នឹងចេះសន្ទឹក ។

គ្រូដែលខ្ជិលរៀន
ឥតចេះខ្មាស់អៀន
គ្រូបរាជិក
ខ្ជិលគិតខ្ជិលគូរ
ជាគ្រូដែលស្ពឹក
គ្មានគិតគ្មានទឹក
អាណិតសិស្សា ។

លោកគ្រូឃើញទេ
ខ្លួនឯងជាមេ
ខ្លួនឯងជាចា
គេទុកចិត្តលើ
វាទើរត្រង់ថា
ទំពែកនោះណា
លក់ថ្នាំដុះសក់ ។

កាក គ តិកាព្យ
ប្រឹងឈ្លូសប្រឹងឆាប
មានទាលិមានតក់
អាណិតជាតិពេក
សង្វេគថ្នាល្អក់
អោយជៀសអាក្រក់
ឈានត្រើយប្រិមប្រិយ ។

សង្ខេបមួយម៉ាត់
ពាក្យខ្ចីពាក្យសត្យ
មិនចាស់មិនថ្មី
ថាយើងជាគ្រូ
គំរូនោះអី
ភក្ត្រស្រស់ប្រិមប្រិយ
រៀនរៀនជានិច្ច ។

គគីរធំ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៨៣

ដោយលោក **ចាំង សុត**

# សៀវភៅសិក្សាថ្មី

* * * * * *

ក្នុងនាមយើងខ្ញុំអ្នកនិពន្ធ　　កិច្ចការស្រាលធ្ងន់ខំសិក្សា
សរសេររិះគិតពិចារណា　　ស្វែងយល់បញ្ហាច្រើនត្រាត្រៀប ។
សៀវភៅសិក្សាយើងចងក្រង　　ដើរតាមគន្លងតាមរបៀប
តាមកម្មវិធីថ្មីបានរៀប　　សំភីប្រៀបធៀបខ្លឹមសារក្ដី ។
គុណភាពអប់រំយើងត្រូវលើក　　ស្ទួយឡើងហើយបើកសិក្សាថ្មី
ទោះមានកម្មវិធីចាស់ក្ដី　　យើងត្រូវកែច្នៃអោយប្រសើរ ។
តំរូវអោយមានការផ្លាស់ប្ដូរ　　វិធីថ្មីគ្រូគួរតែប្រើ
ក្រសួងអប់រំយើងបានស្នើ　　អោយយើងខំដើរខំអនុវត្ត ។
វិធីសិស្សមជ្ឈមណ្ឌល　　សិស្សខំខ្វាយខ្វល់ដោយទៀងទាត់
ស្មារតីក្លាហានចេះចាំស្ទាត់　　មិនខ្លាចនឹងមាត់ហ៊ាននិយាយ ។
សិស្សរៀនខ្លួនឯងរៀនរិះគិត　　ស្រាវជ្រាវគំនិតគិតវែងឆ្ងាយ
ចំនេះខ្លួនមានពីចំងាយ　　ខិតខំគ្រួសត្រាយល្បិចតំរេះ ។
កម្មវិធីថ្មីបានធានា　　ករិតស្មើគ្នានឹងបរទេស
ក្នុងពិភពលោកជាពិសេស　　ក្នុងតំបន់នេះដោយសមសួន ។
សៀវភៅសិក្សាខ្មែរបញ្ចូល　　ប្រមែប្រមូលបំនិនប្អូន
ដែលបានតាក់តែងចេញជាក្បួន　　ប្រយោជន៍មាំមួនទុកជាទុន ។
និយាយ សរសេរ ស្ដាប់ និង អាន　　បំនិនប៉ុន្មានរៀបក្រោយមុន
ពង្រីកចំនេះដឹងជាទុន　　អោយមានទ្រព្យធនទៅអនាគត ។
ខ្លឹមសារមេរៀនមានហូរហែ　　អោយត្រូវផងដែរប្រធានបទ
ផ្សារភ្ជាប់ជីវិតពិតប្រាកដ　　សិស្សចេះអំនត់អត់ធនឡើង ។
បើមានចំនេះប្រាជ្ញាវៃ　　រិះគិតលកលៃលើកដំកើង
ជ្រោមជ្រែងវិស័យអប់រំយើង　　អោយបានឈានឡើងភាពខ្ពង់ខ្ពស់ ។
កម្មវិធីថ្មីបានធានា　　កសាងប្រជាអោយបានរស់
ប្រកបដោយសមត្ថភាពខ្ពស់　　ប្រាជ្ញាគ្មានទាស់ចេះប្រាកដ ។
ទាំងអានសរសេរ និង និយាយ　　ស្ដាប់ល្អឥតបីតាមកំនត់
ចេះធ្វើចេះច្នៃពិតប្រាកដ　　ស្មារតីម៉ត់ចត់នឹងការងារ ។
ធានាអភិវឌ្ឍសង្គម　　ទំនើបឧត្ដមតាមត្រូវការ
សំរាប់កសាងជាតិខេមរា　　អោយបានថ្ងៃថ្នារុងរឿងអើយ ។

ដោយលោកស្រី **ហង់ តារី**
មន្ត្រីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យក្រសួង អ.យ.ក